# វិធូរបណ្ឌិតជាតក



នេះកាលវិធូរបណ្ឌិតសត្វសម្ដែងធម៌នៅឋានកុជង្គនាគ

ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ
**ភូល ផេង**

**ព.ស. ២៥៦៣**

# **វិធុរជាតកពិស្តារ**

## **អធិបតីក្នុងការរៀបរៀង**
## **បណ្ឌិត កុល ផេង**

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## **អ្នកបកប្រែពីអដ្ឋកថាភាសាបាលី**

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## **ក្រុមជំនុំពិនិត្យ**

*បណ្ឌិត* **កុល ផេង** *ប្រធាន*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា**

*ព្រះញាណកោសល* **យ៉ន សេងយៀត**

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ម៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*លោក* **លឹម លឿម**

*លោក* **ដុង សុភឿន**

*លោក* **ទិព្វ សៅ**

*លោក* **សំណាង សំណាក់**

*លោក* **ស៊ន់ គឹមឈន់**

*លោក* **ប៉ាល់ ចំរើន**

*លោក* **ហ៊ុន ពិសេស**

*លោក* **ហាន សុខេមនុ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ិន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **ម៉ម ម៉ានិត** *អនុប្រធាន*

*លោក* **ឃុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

## រចនាសម្ពន្ធពុទ្ធិកបណ្ឌិតសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សាម៉ៀន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សាវេន** *សមាជិក*

*សាស្ត្រាចារ្យ* **ឌិត ឌន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា គ្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុង សុវណ្ណា** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ គុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **ទ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **កុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **ទ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោក* **ហ៊ាត ណាហាំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមន្ទ** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **កុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **ចាន់ ហួរ** *សមាជិក*

*លោក* **ហួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **សំណាង សំណាក់** *សមាជិក*

*លោក* **ជុង សុភឿន** *សមាជិក*

*លោក* **ហ៊ុន ពិសេស** *សមាជិក*

*លោក* **ស៊ន់ គីមឈន់** *សមាជិក*

**សូមថ្វាយព្រះរាជកុសល**
**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង**
**ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**
**ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

***បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង***

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***វិធុរជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *សូម* **ព្រះករុណាជាអម្ចាស់** *អនុមោទនានូវមហា*

កុសល ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុងអនាគត និងដោយអំណាចគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលថែរក្សា **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោសដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,

ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨

**កុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមថ្វាយព្រះរាជកុសល
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## *បពិត្រសម្តេចព្រះមហាក្សត្រីជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***វិធុរជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសលដោយ ព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះ បារមីនៃព្រះសម្មាសម្ពុទ្ធ*

គ្រប់ព្រះអង្គដែលបានគ្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុង អនាគត និងដោយអំណាចគុណបុណ្យ ព្រះរតនត្រ័យ ទេវតាថែរក្សា ព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយ ក្នុងលោក សូមជួយអភិបាលថែរក្សា **សម្តេចព្រះមហាក្សត្រ នរោត្តម សីហមុនី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ ទ្រង់មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្ម យឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,

ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨

**គុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមគោរពជូនមហាកុសល
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## *សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាខ្ញុំបាទ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តីជយមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ* **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូនមហាកុសល ដែលខ្ញុំបាទបានដឹកនាំការរៀបរៀងចងក្រងនូវសៀវភៅ "***វិធុរជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនានេះ ។ សូម* **សម្តេច** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ។ ដោយតេជះគុណានុភាពនៃព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុសក្តិសិទ្ធិ ក្នុង លោកសូមជួយបីបាច់ថែរក្សានិងប្រសិទ្ធិពរជ័យជូន* **សម្តេច** *និង* **លោកជំទាវ** *ព្រមទាំង* **បុត្រាបុត្រី** *និង* **ចៅ** *ៗ ជាទីស្រឡាញ់របស់* **សម្តេច**

*សូមមានសុខភាព ល្អបរិបូណ៌ ជន្មាយុយឺនយូរ បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកត្រើយសុខសន្តិភាព និងការ អភិវឌ្ឍឲ្យសម្បូរសប្បាយ រុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្តនូវវីរិយភាពដ៏អង់អាច របស់* **សម្តេច** *ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែង រកសេចក្តីសុខជូនចំពោះប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុងព្រះរាជា-ណាចក្រកម្ពុជាយើង នាំមកនូវភាពចម្រើនរុងរឿង នាសម័យបច្ចុប្បន្ន នេះ និងក្នុងអនាគតកាល ។*

*សូម* **សម្តេចអគ្គមហាសេនាបតីតេជោ** *និង* **សម្តេចកិត្តិព្រឹទ្ធ-បណ្ឌិត** *ប្រកបដោយសិរីមង្គល វិបុលសុខមហាប្រសើរ ព្រមទាំងទទួល បាននូវធម៌ដ៏ប្រសើរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*រាជធានីភ្នំពេញ,*
*ថ្ងៃ ៩ កើត ខែ អស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**កុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# បុព្វកថា

រឿងវិធុរៈនេះ គឺជាជាតកមួយក្នុងមហាទសជាតក៏ ដែលមានប្រភពដើមជាភាសាបាលីនៃគម្ពីរអដ្ឋកថា ។ យើងដឹងហើយថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានអ្នកចេះភាសាបាលីជាស្ពានសម្រាប់ឆ្លងទៅស្វែងយល់នូវពុទ្ធោវាទជាភាសាបាលីនេះ មានចំនួនតិចតួច ។ បើទុករឿងក្នុងជាតកទាំងអស់ឲ្យនៅជាភាសាបាលី ដូច្នេះជាឧបសគ្គដ៏ធំសម្រាប់អ្នកសិក្សាភាគច្រើន រួមទាំងសិស្ស និស្សិត និងបញ្ញវន្តទាំងអស់ដែលមិនបានសិក្សាភាសាបាលី ។ ម្យ៉ាងវិញទៀតប្រទេសកម្ពុជាយើង ក៏ធ្លាប់មានសៀវភៅសង្ខេបទសជាតក ដែលប្រែនិងរៀបរៀងដោយលោក **ឈឹម ស៊ុម** កាលពីឆ្នាំ ១៩៥៩ មួយក្បាលគ្រប់ទាំង ១០ រឿងរួចមកហើយឃើញថា មានសេចក្ដីសមល្មមគ្រប់គ្រាន់សម្រាប់ពុទ្ធសាសនិកជនសម័យនោះសិក្សារៀនសូត្រ តែមកដល់សម័យបច្ចុប្បន្ននេះ រឿងសង្ខេបទសជាតកនោះ មិនទាន់ឆ្លួនល្មមដល់តម្រូវការនៃការស្រាវជ្រាវរបស់សិស្ស និស្សិត បញ្ញវន្ត និងពុទ្ធសាសនិកនៅឡើយ ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មើលឃើញពីតម្រូវការនេះថាជាការចាំបាច់បំផុតក្នុងការចូលរួមចំណែកជួយអប់រំសង្គម ទើបខ្ញុំខ្មែង ចាត់ចែង រៀបចំបកប្រែ និង រៀបរៀងវិធុរជាតកនេះ ម្ដងទៀត

ឲ្យមានសេចក្តីពិស្តារ តាមច្បាប់ដើមក្នុងអដ្ឋកថា ជា ភាសាបាលី ក្នុងគោលបំណងជួយបំពេញបន្ថែមដល់ការសិក្សា ស្រាវជ្រាវរបស់សិក្ខាកាមគ្រប់កម្រិតនិងដល់ពុទ្ធបរិស័ទគ្រប់រូប ។

ការរៀបរៀងសៀវភៅនេះ ដំបូងយើងប្រែពីភាសាបាលីមកជាភាសាខ្មែរ បន្ទាប់មក យើងចាប់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ដោយប្រើសំនួនវោហារតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ **ជួន-ណាត ជោតញ្ញាណោ** ជាគោល ។ ខ្លឹមសារសេចក្តី យើងប្រើពាក្យងាយសាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ដល់អ្នកសិក្សាគ្រប់កម្រិត ។ម្យ៉ាងទៀត ពាក្យពិបាកខ្លះដែលជាប់ដោយភាសាបាលី ដែលខ្មែរយកមកប្រើជារាជសព្ទ និងសង្ឃសព្ទ យើងមិនអាចចៀសវាងបាន ក៏ត្រូវរក្សាទុក ដោយដាក់លេខយោងពន្យល់នៅផ្នែកខាងក្រោមនៃទំព័រ ។

ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងខ្លឹមសារសេចក្តីក្នុងសៀវ-ភៅនេះ ទោះបីយើងខំប្រឹងប្រែងពិនិត្យកែជាច្រើនលើកច្រើនសាដោយផ្ចិតផ្ចង់ក៏ដោយ ក៏គង់មានចំណុចខ្វះចន្លោះផ្នែកអក្ខរាវិរុទ្ធ និងសេចក្តីនៅមានផ្តាំផ្គង់ខ្វះ ៗ មិនខាន ។ សូមអស់លោកអ្នកអានឃើញខុសត្រង់ណា មេត្តាជួយកែតម្រូវក្នុងលក្ខណៈស្ថាបនាឲ្យបានរីកចម្រើនដើម្បីបានជាក្បួនខ្នាតទុកសម្រាប់កុលបុត្រសិក្សាតទៅអនាគត ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមចែករំលែកនូវកងការមហាកុសលដែលកើតឡើងពីការបកប្រែរៀបរៀងសៀវភៅវិធុរជាតក

*ពិស្តារនេះ ថ្វាយ ប្រគេន ជូនដល់អស់លោកអ្នកដែលបានកាន់សៀវភៅនេះអាន និងដល់បុព្វការីជន ញាតិមិត្រ សាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ត សូមឲ្យលោកអ្នកមានគុណទាំងនោះ បានសម្រេចនូវសម្បត្តិ ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេវតា និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមសត្វលោកទាំងពួងបានប្រកបដោយសេចក្តីសុខជានិរន្តរ៍តទៅ ។*

*រាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**គុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី១


វិធុរបណ្ឌិតដោះប្រស្នាស្តេចទាំង៤អង្គ..................................១

វិធុរៈធ្វើជាទីប្រឹក្សាស្តេចធនញ្ជយកោរព្យ...............................៤

ឥសី ៤ រូប ផ្តល់ដំណឹងដល់ក្ខត្តិ ៤ នាក់...............................៤

ក្ខត្តិទាំង ៤ កើតក្នុងភពតាមប្រាថ្នា......................................៦

ស្តេចទាំង ៤ បង្ហួតអានិសង្សឧបោសថគ្នា.............................៧

វិធុរបណ្ឌិតដោះចម្ងល់ស្តេចទាំង ៤...................................១៣

ស្តេចទាំង ៤ បូជាវិធុរបណ្ឌិត............................................១៨


## ជំពូកទី២

## ជំងឺចាញ់កូនឃ្លានបេះដូងវិធុរៈ


វិមលាទេវីធ្វើពុតចាញ់កូន..................................................២១

ស្តេចនាគប្រើកូនក្រមុំឈ្មោះឥរន្ទតីរកប្រុសខ្លាំង..................២៤

ឥរន្ទតីច្រៀងចម្រៀងអំពាវនាវរកប្តី......................................២៧

បុណ្ណកសេនាបតីយក្សថៃចូវនាងឥរន្ទតី................................២៩

នាងឥរន្ទតីនាំបុណ្ណកយក្សទៅកពនាគ.................................៣១

បុណ្ណកយក្សជានាទៅចាប់វិធុរបណ្ឌិត................................៣៣

បុណ្ណកយក្សសូមសេចក្តីអនុញ្ញាតពីស្តេចវេស្សវ័ណ.............៣៥

បុណ្ណកយក្សភ្នាល់លេងល្បែងនឹងស្តេចធនញ្ជ័យ..................៤០

អានុភាពចិត្តនិងរូបនិម្មិតក្នុងកែវមណី.................................៤៧

ស្តេចលេងល្បែងចាញ់បុណ្ណកៈ...........................................៦០

ស្តេចនិងបុណ្ណកយក្សចូលទៅរកវិធុរបណ្ឌិត........................៦៨

## ជំពូកទី៣

## វិធុរបណ្ឌិតគោចកន្លុយសេះ

ព្រះរាជាអញ្ជើញវិធុរបណ្ឌិតសម្តែងយរាវាសធម៌................៧៣

ភាពក្រៀមក្រំនៃគ្រួសារវិធុរបណ្ឌិត.....................................៧៨

វិធុរបណ្ឌិតសម្ដែងរាជសេវកធម៌..........................................៨៤

វិធុរបណ្ឌិតលាព្រះមហាក្សត្រជាគ្រាចុងក្រោយ................១០០

ស្ដេចធនញ្ជ័យលួងលោមមហាជន....................................១០៩

កំណត់សម្គាល់...................................................................១១០

## ជំពូកទី៤

## វិធុរបណ្ឌិតសម្ដែងសាធុនរធម៌

បុណ្ណកយក្សបន្ទាចវិធុរៈដោយវិធីផ្សេង ៗ ..........................១១២

វិធុរបណ្ឌិតសម្ដែងសាធុនរធម៌.....................................................១១៨

បុណ្ណកយក្សដោះលែងវិធុរៈ...............................................១២៤

## ជំពូកទី៥

## វិធុរបណ្ឌិតធ្វើមាតុគ្គាមិនិវត្តន៍

វិធុរបណ្ឌិតទៅកពនាគ......................................................១២៦

អ្នកទោសមិនថ្វាយបង្គំពេជ្ឈឃាត......................................១៣១

សេចក្ដីសន្ទនារវាងវិធុរៈនិងព្រះនាងវិមលា.........................១៤០

បុណ្ណកយក្សបាននាងឥរន្ទតី................................................១៤៦

បុណ្ណកៈដឹកវិធុរៈទៅមនុស្សលោកវិញ................................១៤៨

វិធុរៈក្រាបទូលប្រវត្តិដំណើរទៅកពនាគ..............................១៥១

ពិធីអបអរសាទរចំពោះវិធុរបណ្ឌិត.....................................១៥៦

ព្រះសាស្តាប្រជុំជាតក........................................................១៦០

# ជំពូកទី ១

## វិធុរបណ្ឌិតដោះប្រស្នាស្តេចទាំង ៤ អង្គ

### និទានខាងដើម

*កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់បានប្រារព្ធនូវបញ្ញាបារមីរបស់ព្រះអង្គ ទ្រង់សម្តែងនូវធម្មទេសនា ដោយផ្តើមពាក្យថា "បណ្ឌុ កិសិយាសិ ទុព្វលា" ដូច្នេះជាដើម ។*

*មានដំណើររឿងទាក់ទងនឹងពុទ្ធតម្រាស់នោះថា ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា ៖*

*"ហៃលោកមានអាយុទាំងឡាយអើយ ព្រះសាស្តាទ្រង់មានបញ្ញាធំ បញ្ញាក្រាស់ បញ្ញាជ្រាលជ្រៅ បញ្ញាលឿន បញ្ញារហ័ស បញ្ញាស្រួច បញ្ញាមុត សម្រាប់ឈ្វេចឈ្វីបរប្បវាទ[១], ព្រះអង្គបានបំបែកប្រស្នាដ៏ល្អិតសុខុម ដែលនិពន្ធដោយខត្តិយបណ្ឌិតជាដើម ដោយអានុភាពនៃបញ្ញារបស់ព្រះអង្គ ទ្រង់បានទូន្មានជនទាំងនោះឲ្យលែងមានសេចក្តីរឹងត្អឹងប្រកាន់មាំ ញ៉ាំងពួកគេឲ្យតាំងនៅស៊ប់ក្នុងព្រះត្រៃសរណៈនិងសីលទាំងឡាយ ឲ្យដើរផ្លូវទៅ*

*[១] ពាក្យត្មះតិះដៀលរបស់ពួកអ្នកមិច្ឆាទិដ្ឋិ ។*

បំអមតៈ[២]”។

ព្រះសាស្ដាយាងមកហើយ ទ្រង់ត្រាស់សួរថា ៖

“ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ[៣] អ្នកទាំងឡាយប្រជុំគ្នានិយាយ អំពីរឿងអ្វី ?”

ក្រោយពេលដែលភិក្ខុទាំងឡាយក្រាបទូលសាច់រឿងដែលខ្លួនជជែក ហើយ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ៖

“រឿងនេះមិនមែនអស្ចារ្យទេ ភិក្ខុទាំងឡាយ ត្រង់ដែលតថាគត បំបែកបរប្បវាទ ទូន្មានបាននូវខត្តិយៈជាដើម ក្នុងពេលដែល

[២] (គុ.) (បា.),(សំ.) (អៈម៉ៈតៈ) (អមត; អម្ឫត) ដែលមិនស្លាប់, មិនចេះស្លាប់; ដែលមិនដាច់, មិនស្រោក (ដែលមានជានិច្ច) ។ ន. ដំណើរមិនស្លាប់; ព្រះនិញ្វាន; ទឹកទិព្វ; សុធាភោជន (ប្រើជា អម្ឫត ឬ អម្រឹត ក៏បាន)

[៣] (និ.) មួយរំពេចមុននេះ, ភ្លាម ៗ មុននេះ : គេទើបនឹងចេញទៅអម្បាញ់មិញ ។

ដល់សព្វញ្ញុតញ្ញាណ[៤]នេះ សូម្បីក្នុងជាតិកន្លងទៅហើយ កាលតថាគត កំពុងតែស្វែងរកពោធិញ្ញាណ[៥]នៅឡើយ ក៏ធ្លាប់ជាអ្នកមានបញ្ញាឈ្វេចឈ្វីនូវបរប្បវាទដែរ ដូចកាលមួយនោះ តថាគតមានកំណើតជាមនុស្សឈ្មោះថា **វិធុរៈ** បានទូន្មានដោយកម្លាំងប្រាជ្ញានៃខ្លួនពិត ៗ នូវនាយសេនាបតីយក្សឈ្មោះថា **បុណ្ណកៈ** លើកំពូលភ្នំកាឡៈ ដែលមានកម្ពស់ ៦០ យោជន៍ តថាគតបានអប់រំគេឲ្យលែងរឹងត្អឹង ទូន្មានគេឲ្យតាំងនៅស៊ប់ ក្នុងបញ្ចសីល[៦] និងញុំាំងគេឲ្យប្រទាននូវជីវិតរបស់ខ្លួន” ។

ត្រាស់ត្រឹមប៉ុណ្ណោះ ទ្រង់ក៏ត្រូវភិក្ខុទាំងឡាយនោះអារាធនាឲ្យសម្ដែងរឿងនោះ ព្រះអង្គក៏លើកយកអតីតនិទានមកបរិយាយដូចតទៅនេះ ៖

---

[៤] (កិ. វិ.), (គុ.) (បា.),(សំ.) (សប់) សព្វញ្ញុតញ្ញាណ (សប់-ព័ញ-ញុ-ត័ញ-ញាន) ញាណ ឬប្រាជ្ញាដែលដឹងសព្វ (ញាណរបស់ព្រះសព្វញ្ញុពុទ្ធ) ។ សព្វញ្ញុពុទ្ធ ឬ សព្វញ្ញូ-- (សប់-ព័ញ-ញុ ឬ--ញូ-ពុត) លោកអ្នកត្រាស់ដឹងសព្វ (ព្រះសម្មាសម្ពុទ្ធ); ហៅត្រឹមតែ សព្វញ្ញូ ក៏បាន : ព្រះសព្វញ្ញូ ។

[៥] (ន.) (បា.),(សំ.) (--ធិញាណ) (ពោធិញ្ញាណ; --ដ្ឋាន) ប្រាជ្ញាជាគ្រឿងត្រាស់ដឹង : ព្រះសិទ្ធត្ថគោតមទ្រង់បានសម្រេចពោធិញាណ (ព. ពុ.) ។

[៦] សីល ៥ ។

## **វិធុរៈធ្វើជាទីប្រឹក្សាស្តេចធនញ្ជយកោរព្យ**

*ក្នុងកាលកន្លងទៅហើយ មានព្រះរាជាមួយអង្គ ព្រះនាមថា **ធនញ្ជយកោរព្យ** ទ្រង់បានសោយរាជ្យក្នុងនគរឥន្ទបត្ត ដែនកុរុ ។ មានអាមាត្យម្នាក់ ឈ្មោះថា **វិធុរបណ្ឌិត** ជាទីប្រឹក្សារបស់ព្រះអង្គ ។ វិធុរៈបណ្ឌិតនោះ មានសម្តីថ្វីមាត់ពីរោះពិសាក្បោះក្បាយ ជាធម្មកថិក[៧]ដ៏ឆ្នើម តែងប្រឹក្សាកិច្ចការតូចធំជាមួយនឹងព្រះរាជាទាំងឡាយទូទៅក្នុងជម្ពូទ្វីប ។ ដោយហេតុតែលោកចេះសម្តែងធម្មទេសនាពីរោះយ៉ាងនេះហើយ ទើបពុំអាចលៃពេលធ្វើដំណើរទៅកាន់រាជាណាចក្រផ្សេង ៗ របស់ស្តេចដទៃ ដោយដាច់មុខបានឡើយ លោកបានស្នាក់អាស្រ័យនៅក្នុងឥន្ទបត្តនគរនោះ ទាំងមានយសសក្តិធំដុំ ជួយសម្តែងធម៌ដល់មហាជន ដោយលំនាំលម្អាននៃអង្គព្រះសម្ពុទ្ធ ។*

## **ឥសី ៤ រូប ផ្តល់ដំណឹងដល់គ្រហ្ម្ហ៊ី[៨] ៤ នាក់**

*គ្រានោះឯង មានបុរសជាសម្លាញ់នឹងគ្នា ៤ នាក់ សុទ្ធតែជាព្រាហ្មណ៍មហាសាល ពេលចាស់ទៅ ពួកគាត់បានឃើញទោសក្នុង*

---

[៧] (ន.) (បា.),(សំ.) (ធ័ម-ម:ក: ថិក) (ធម៌កថិក) *អ្នកសម្តែងធម៌ ។ ខ្មែរប្រើពាក្យនេះជាងារនៃភិក្ខុអ្នកចេះសម្តែងធម៌ ថ្នាក់ជាឋានានុក្រម ជាសហការីនៃព្រះរាជាគណៈជាចៅអធិការវត្តធំ ៗ ក្នុងព្រះរាជធានី ឬជាសហការីនៃមេគណ កាលបើត្រូវការឲ្យមាន : ព្រះធម្មកថិក សហការីនៃ...។*

[៨] (ន.) *អ្នកមានសម្បត្តិដោយផលប្រយោជន៍កើតអំពីស្រែចម្ការច្បារដំណាំ ។*

កាមទាំងឡាយ ហើយនាំគ្នាសម្រេចចិត្តចូលទៅព្រៃហិមពាន្ត បួសជាឥសី ញុំាងអភិញ្ញានិងសមាបត្តិឲ្យកើត ។ ឥសីទាំងនោះ រស់នៅទីនោះយូរអង្វែង បរិភោគតែមើមឈើនិងផ្លែឈើ ។ ដោយសារតែមានបំណងចង់ឆាន់រសជាតិប្រៃនិងជូរ ឥសីទាំងនោះចារិក[៩] ទៅរៀងរាបដល់ចម្ប៉ានគរ ក្នុងដែនកុរុ ហើយចូលទៅសម្រាកក្នុងរាជុយ្យាន[១០] លុះដល់ព្រឹកឡើង ចូលទៅកាន់នគរដើម្បីបិណ្ឌបាត ។ កុម្ពី ៤ នាក់ ជាសម្លាញ់នឹងគ្នាក្នុងនគរនោះ ជ្រះថ្លាចំពោះឥរិយាបថទាំងឡាយរបស់តាបសទាំងនោះ នាំគ្នាថ្វាយបង្គំ ហើយទទួលភាជន៍[១១] ចង្ហាន់ និមន្តតាបសម្នាក់មួយអង្គ ៗ ឲ្យគង់ក្នុងនិវេសន៍របស់ខ្លួន អង្គាសដោយអាហារដ៏ប្រណីតរួចសូមនិមន្តតាបសទាំងអស់អង្គឲ្យទទួលនូវសេចក្ដីប្ដេជ្ញា ហើយនិមន្តតាបសទាំងអស់អង្គ ឲ្យគង់នៅក្នុងឧទ្យាននោះតែម្ដង ។ តាបសទាំង ៤ អង្គនោះ តែងឆាន់ជាប់មិនដាច់ក្នុងផ្ទះរបស់កុម្ពីទាំង ៤ នាក់ ។ ដើម្បីប្រយោជន៍សម្រាកក្នុងពេលថ្ងៃ តាបសមួយអង្គបានទៅសម្រាកនៅឯភពតាវត្តិង្ស, មួយអង្គឯភពនាគ, មួយអង្គឯភពគ្រុឌ, ឯមួយអង្គទៀត

[៩] (ន.) (សំ.),(បា.) ទីដែលជាទីត្រាច់ទៅឬជាទីត្រាច់មក : ទៅកាន់ចារិកនៃខេត្រ ។ ពុទ្ធចារិក (ពុត-ធៈ--) ទីដែលព្រះពុទ្ធទ្រង់ស្ដេចទៅឬស្ដេចមក ។ល។

[១០] ឧទ្យានរបស់ព្រះរាជា ។

[១១] (ន.) (ភាច) (ភាជន) ប្រដាប់សម្រាប់ដាក់ភោជនាអាហារមានបាយជាដើម : ភោជនមួយភាជន៍, ភាជន៍មាស ។

ឯឧទ្យានឈ្មោះមិគាជិនរបស់ព្រះបាទកោរព្យរាជ ។ បណ្តាតាបសទាំងនោះ តាបសដែលទៅកាន់ទេវលោកដើម្បីសម្រាកក្នុងពេលថ្ងៃ តែងគយគន់មើលនូវយសរបស់សក្កទេវរាជ លុះត្រឡប់មកវិញ លោកតែងពោលសរសើរយសសក្តិរបស់សក្កទេវរាជនុ៎ះឯង ដល់គ្រហស្ថជាឧបដ្ឋាករបស់ខ្លួន ។ តាបសដែលទៅភពនាគដើម្បីសម្រាកវេលាថ្ងៃ តែងគន់មើលនូវសម្បត្តិរបស់នាគរាជ លុះត្រឡប់មកវិញ តែងពោលសរសើរនូវសម្បត្តិនោះឯង ដល់ឧបដ្ឋាករបស់ខ្លួន ។ តាបសដែលទៅកាន់ភពគ្រុឌ ដើម្បីសម្រាកវេលាថ្ងៃ លោកតែងគយគន់មើលនូវភាពរុងរឿងរបស់ស្តេចគ្រុឌ លុះត្រឡប់មកវិញតែងពណ៌នានូវភាពរុងរឿងនុ៎ះឯងដល់គ្រហស្ថជាឧបដ្ឋាករបស់ខ្លួន ។ រីឯតាបសដែលទៅគង់នៅឯឧទ្យានរបស់ព្រះបាទធនញ្ជយកោរព្យរាជ ដើម្បីសម្រាកក្នុងពេលថ្ងៃ តែងគន់មើលនូវសម្បត្តិដ៏ច្រើនលើសលុបរបស់ព្រះបាទធនញ្ជយកោរព្យរាជ លុះត្រឡប់មកវិញតែងពោលសរសើរនូវសម្បត្តិនុ៎ះឯង ដល់គ្រហស្ថជាឧបដ្ឋាករបស់ខ្លួន ។

## គ្រហស្ថទាំង ៤ កើតក្នុងភពតាមប្រាថ្នា

គ្រហស្ថទាំង ៤ នាក់នោះ ប្រាថ្នានូវឋានទាំងឡាយដែលតាបសបានប្រាប់ ហើយធ្វើបុណ្យទាំងឡាយ មានទានជាដើម លុះដល់ទីបំផុតនៃអាយុ គ្រហស្ថម្នាក់ កើតជាសក្កទេវរាជ, ម្នាក់ទៀត កើតជានាគរាជក្នុង

ភពនាគ រួមទាំងកូនប្រពន្ធ, ម្នាក់ទៀតកើតជាស្តេចគ្រុឌក្នុងសិម្ពលិ-វិមានក្នុងភពគ្រុឌ, ម្នាក់ទៀត បានកើតក្នុងផ្ទៃរបស់អគ្គមហេសីរបស់ព្រះបាទធនញ្ជយកោរព្យរាជ ។ ចំណែកខាងតាបសទាំងនោះវិញ មានឈានមិនសាបសូន្យ ធ្វើមរណកាលហើយ បានកើតនៅព្រហ្ម-លោក ។ កោរព្យកុមារ ចម្រើនវ័យវឌ្ឍនាការឡើង បានឋិតក្នុងរាជ-សម្បត្តិ បន្ទាប់ពីព្រះរាជបិតាសោយទិវង្គត ទ្រង់សោយរាជ្យដោយសមធម៌ ។ ប៉ុន្តែព្រះរាជាអង្គនោះ មានទ្រព្យសម្បត្តិច្រើន ដោយសារលេងល្បែង ។ យ៉ាងណាក៏ដោយចុះ ព្រះអង្គតែងឋិតក្នុងឱវាទរបស់វិធុរបណ្ឌិត តែងឲ្យទាន រក្សាសីល ៥ និងចាំសីល ៨ ។

## ស្តេចទាំង ៤ បង្ហាញអានិសង្សឧបោសថគ្នា

ក្នុងថ្ងៃមួយ ព្រះបាទកោរព្យរាជ សមាទានឧបោសថហើយទ្រង់យាងទៅកាន់ឧទ្យាន ប៉ងនឹងចម្រើនវិវេក[១២] ទ្រង់គង់ក្នុងទីគួរជាទីគាប់ចិត្ត ហើយធ្វើនូវសមណធម៌[១៣] ។ ចំណែកសក្កទេវរាជ

---

[១២] (ន.) (សំ.),(បា.) សេចក្តីស្ងាត់; ការស្ងាត់ចាកអារម្មណ៍សៅហ្មង; ការពិចារណាឃើញសេចក្តីពិត ។ គុ. ស្ងាត់ ។ វិវេកដ្ឋាន ឬ--ស្ថាន ឋានស្ងាត់ ។ វិវេកភាព (--ក:-ភាប) ភាវៈស្ងាត់ ។

[១៣] សមណធម៌ ធម៌សម្រាប់សមណៈ, សមថធម៌ ។ សមណបរិក្ខារ គ្រឿងប្រដាប់សម្រាប់សមណៈប្រើប្រាស់ ។

សមាទានឧបោសថ ហើយទ្រង់គិតថា "ក្នុងទេវលោកនេះ មានកង្វល់" ដូច្នេះ ទ្រង់ក៏យាងមកក្នុងមនុស្សលោក ចុះចំត្រង់ឧទ្យាននោះដែរ គង់ក្នុងទីគួរឲ្យគាប់ចិត្ត រួចធ្វើសមណធម៌ ។ ចំណែកវរុណនាគរាជ សមាទានឧបោសថហើយ គិតថា "ក្នុងភពនាគនេះ មានកង្វល់" ដែរ ហើយក៏មកទីនោះដែរ លុះបានអង្គុយក្នុងទីគួរឲ្យគាប់ចិត្តមួយកន្លែងហើយ ក៏ធ្វើនូវសមណធម៌ ។ រីឯស្តេចគ្រុឌវិញ សមាទានឧបោសថ ហើយ គិតថា "ក្នុងភពគ្រុឌនេះ មានកង្វល់" ដែរ ហើយក៏មកទីនោះ លុះបានអង្គុយក្នុងទីគួរឲ្យគាប់ចិត្តមួយកន្លែងហើយ ក៏ធ្វើនូវសមណ-ធម៌ ។ ក្នុងវេលារសៀល ជនទាំង ៤ នាក់នោះ ចេញអំពីកន្លែងរៀង ៗ ខ្លួន មកព្រមគ្នាទៀបឆ្នេរស្រះមង្គលបោក្ខរណី ក៏អើតមើលមុខគ្នាទៅវិញទៅមក ស្រុះស្រួលរាក់ទាក់រួសរាយ ដោយអំណាចនៃសេចក្តីស្រឡាញ់គ្នាពីមុនមក ជនទាំង ៤ នាក់នោះ តាំងមេត្តាចិត្តចំពោះគ្នាទៅវិញទៅមក ធ្វើបដិសណ្ឋារៈដ៏ផ្អែមពីរោះជាទីគាប់ចិត្ត ។ បណ្តាជន ៤ រូបនោះ សក្កទេវរាជ គង់លើផ្ទាំងសិលាមង្គល, ចំណែកឯអ្នកដទៃទៀត គង់លើអាសនៈដ៏សមគួររៀង ៗ ខ្លួន ។ គ្រានោះ សក្កទេវរាជ ត្រាស់នឹងជនទាំង ៣ ថា ៖

"យើងទាំង ៤ នាក់ សោតសឹងតែជាស្តេច ចុះបណ្តាពួកយើង
តើសីលរបស់នរណា ប្រសើរលើសលន់ជាងគេ ?"

គ្រានោះ វរុណនាគរាជ និយាយនឹងសក្កៈថា ៖

"សីលរបស់ទូលបង្គំ ប្រសើរជាងពួកព្រះអង្គទាំង ៣" ។

សក្កៈសួរ ៖

"តើហេតុផលក្នុងរឿងនោះ ដូចម្តេចទៅ?"

វរុណនាគរាជថា ៖

"ស្តេចគ្រុឌនេះ គឺជាបច្ចាមិត្រ[១៤]ពិតរបស់ពួកទូលបង្គំ ទោះអ្នកទាំងនោះកើតហើយក្តី មិនទាន់កើតក្តី ទូលបង្គំ ទោះបានឃើញបច្ចាមិត្រអ្នកធ្វើអន្តរាយដល់ជីវិតរបស់ពួកទូលបង្គំបែបនេះ ម៉្លឹងហើយ ក៏មិនធ្វើសេចក្តីក្រោធឲ្យកើតឡើងឡើយ, សីលរបស់ទូលបង្គំ ដែលប្រសើរគឺដោយហេតុនេះឯង" ។

លុះពោលដូច្នេះហើយ ក៏បន្តពោលថា ៖

"យោ កោបនេយ្យេ ន ករោតិ កោបំ,
ន កុជ្ឈតិ សប្បុរិសោ កទាចិ;
កុទ្ធោបិ សោ នាវិករោតិ កោបំ,
តំ វេ នរំ សមណមាហុ លោកេ" ។

---

[១៤] (ន.) (បា.),(សំ.) (ប៉ុច-ចាមិត ឬ ប្រ័ត-ត្យា មិត) (បច្ចាមិត; ប្រត្យមិត្រ ឬ ប្រត្យានិត្រ) អមិត្ត, សត្រូវ : បច្ចាមិត្តតូចតាច អាចនឹងបង្កឲ្យកើតជាទោសសត្រូវធំបាន, ដូចជាបួសទ្រនិចតូចមួយ ឬដូចជារលកកែវតូចមួយ អាចនឹងក្លាយទៅជាជំងឺធ្ងន់បាន ដូច្នោះដែរ ។

"បុគ្គលណាជាសប្បុរស មិនធ្វើនូវសេចក្ដីក្រោធ ចំពោះបុគ្គលដែលគួរក្រោធ នឹងមិនក្រោធក្នុងកាលណាមួយ បុគ្គលជាសប្បុរសនោះ បើទុកជាក្រោធ ក៏មិនធ្វើសេចក្ដីក្រោធឲ្យប្រាកដឡើងបណ្ឌិតទាំងឡាយហៅជននោះឯងថាជាសមណៈ[១៥]ក្នុងលោក" ។

ស្ដេចគ្រុឌឮដូច្នោះ ក៏និយាយដែរថា ៖

"នាគនេះ ជាចំណីកំពូលឆ្ងាញ់មហាសែនឆ្ងាញ់របស់ទូលបង្គំ ប៉ុន្តែដោយសារទូលបង្គំជាអ្នករក្សាឧបោសថសីល បើទោះបីឃើញចំណីដ៏កំពូលគួរឲ្យស្រក់ទឹកមាត់បែបនេះក៏ដោយ ក៏ខំអត់សង្កត់នូវសេក្ដីស្រេកឃ្លាននោះដែរ មិនធ្វើនូវបាបព្រោះតែអាហារ ដូច្នោះ សីលរបស់ទូលបង្គំតែមួយគត់ ទើបប្រសើរជាងជាងគេ" ។

ហើយក៏បន្តពោលនូវគាថានេះ ៖

"ឱរេន យោ សហតេ ជិឃច្ឆំ,
ទន្តោ តបស្សី មិតបានភោជនោ;
អាហារហេតុ ន ករោតិ បាបំ,

---

[១៥] (ន.) (បា.),(សំ.) (សៈម៉ៈណៈ) (សមណ; ស្រមណ) អ្នកមានព្យាយាមដុតកម្ដៅបាប, អ្នកខំប្រឹងប្រព្រឹត្តធម៌ធ្វើកាយវាចាចិត្តឲ្យស្ងប់ចាកបាប, អ្នកស្ងប់, អ្នករម្ងាប់បាប (អ្នកបួស) ។

តំ វេ នរំ សមណមាហុ លោកេ" ។

"ជនណាមានពោះធូរ[១៦] អត់ទ្រាំនូវសេចក្តីស្រេកឃ្លានបាន ទូន្មាននូវឥន្ទ្រិយ ជាអ្នកមានតបធម៌[១៧] មានទឹកនិងភោជនល្មមប្រមាណ មិនធ្វើនូវបាប ព្រោះហេតុនៃអាហារ បណ្ឌិតទាំងឡាយ ហៅជននោះឯងថាជាសមណៈ ក្នុងលោក" ។

បន្ទាប់ពីនោះ សក្កទេវរាជថា ៖

"ទូលបង្គំបានលះបង់សម្បត្តិទេវលោកដែលជាបទដ្ឋាន[១៨]នៃសុខមានប្រការផ្សេង ៗ មកកាន់មនុស្សលោកប្រយោជន៍ដើម្បី រក្សាសីល ព្រោះហេតុនោះ សីលរបស់ទូលបង្គំតែម្នាក់ប៉ុណ្ណោះ ទើបប្រសើរជាងគេ" ។

រួចទ្រង់ពោលនូវគាថានេះ ៖

"ខិឌ្ឌំ រតឹ វិប្បជហិត្វាន សព្វំ,
ន ចាលិកំ ភាសតិ កិញ្ចិ លោកេ;

---

[១៦] ពោះធូរ គឺពោះអត់មានអាហារ ។

[១៧] (ន.) (បា.),(សំ.) (តៈ ប៉ៈ ធ័រ) (តបធម្ម ឬ តបោធម្ម) ធម៌សម្រាប់ប្រព្រឹត្តដើម្បីដុតបំផ្លាញគ្រឿងសៅហ្មងចិត្ត ។

[១៨] (ន.) (បា.) (ប៉ៈ-ទ័ត-ឋាន) ទីតាំង, ហេតុជាទីតម្កល់, ដើមទ្រផ្ចាល់; អាសន្នហេតុ គឺហេតុជិតកៀកផ្ចាល់ : សីលមានហិរិនិងឱត្តប្បៈជាបទដ្ឋាន ឬថា ហិរិ និង ឱត្តប្បៈ ជាបទដ្ឋានរបស់សីល ។

វិភូសដ្ឋានា វិរតោ មេថុនស្មា,
តំ វេ នរំ សមណមាហុ លោកេ" ។

"ជនណាលះបង់នូវល្បែងដោយកាយនិងវាចា និងសេចក្ដីត្រេកអរក្នុងកាមគុណទាំងពួង ទាំងមិនពោលនូវពាក្យឡេះឡោះ តិចតួចក្នុងលោក វៀរចាកហេតុជាទីតាំងនៃការស្អិតស្អាងនិងមេថុនធម្ម បណ្ឌិតទាំងឡាយហៅជននោះឯងថាសមណៈក្នុងលោក"។

ព្រះបាទធនញ្ជយរាជ ព្រះដូច្នោះហើយ ទ្រង់ត្រាស់ថា ៖

"ក្នុងថ្ងៃនេះ ទូលបង្គំលះបង់បុរីខាងក្នុង ដែលពោរពេញដោយស្រីរបាំ ១៦.០០០ ដែលជាទីរីករាយក្រៃលែង ហើយមកធ្វើសមណធម៌ក្នុងឧទ្យាន ដោយហេតុនោះ សីលរបស់ទូលបង្គំតែមួយប៉ុណ្ណោះ ទើបប្រសើរជាងអស់លោក" ។

រួចទ្រង់ពោលនូវគាថានេះ ៖

"បរិគ្គហំ លោភធម្មញ្ច សព្វំ,
យោ វេ បរិញ្ញាយ បរិច្ចជេតិ;
ទន្តំ ឋិតត្តំ អមមំ និរាសំ,
តំ វេ នរំ សមណមាហុ លោកេ" ។

"ជនណា កំណត់ដឹង ហើយលះបង់នូវទ្រព្យសម្បត្តិផង លោភៈទាំងពួងផង បណ្ឌិតទាំងឡាយហៅជនដែលមានខ្លួនទូន្មាន មាន

*សភាពខ្ជាប់ខ្ជួន មិនមានសេចក្ដីប្រកាន់ថា អញ មិនមានសេចក្ដីប្រាថ្នានោះឯងថាជាសមណៈក្នុងលោក" ។*

## វិធុរបណ្ឌិតដោះចម្ងល់ស្ដេចទាំង ៤

*សរុបសេចក្ដីមកថា ស្ដេចទាំងអស់នោះ ប្រកាន់អួតសរសើរថាសីលខ្លួនប្រសើរជាងនរណាទាំងអស់តែរៀង ៗ ខ្លួន ។ សក្កៈជាដើមសួរធនញ្ជ័យថា ៖*

*"បពិត្រមហារាជ ចុះនៅក្នុងសម្នាក់របស់ព្រះអង្គ មានបណ្ឌិតណាមួយដែលអាចបន្ទោបង់[១៩]នូវសេចក្ដីសង្ស័យរបស់យើងនេះបានទេ ?"*

*ធនញ្ជ័យថា ៖*

*"មហារាជទាំងឡាយ ព្រះករុណាថ្លៃវិសេស ! ទីប្រឹក្សារបស់ទូលបង្គំម្នាក់ គេមានបញ្ញាច្រើន មិនដែលមានធុរៈដាក់ចុះ គេឈ្មោះថា **វិធុរបណ្ឌិត** គេនឹងអាចបន្ទោបង់នូវសេចក្ដីសង្ស័យរបស់យើងនេះបាន តោះពួកយើងទៅកាន់សម្នាក់របស់គេ" ។*

*ទើបស្ដេចទាំងអស់នោះ យល់ព្រមថា "ល្អណាស់" ។ គ្រានោះ ស្ដេចទាំងអស់ចេញអំពីឧទ្យាន ទៅកាន់ធម្មសភា បង្គាប់ឲ្យគេតុបតែងនូវបល្ល័ង្ក រួចក៏អញ្ជើញវិធុរបណ្ឌិតពោធិសត្វឲ្យឡើងអង្គុយលើកណ្ដាល*

---

[១៩] *(កិ.) នាំបង់, បន្ថយចេញ : បន្ទោបង់ឧច្ចារៈ, បន្ទោបង់សេចក្ដីព្រួយ ។*

បល្ល័ង្កដ៏បវរ ធ្វើនូវបដិសណ្ឋារៈហើយ ពួកទ្រង់ប្រថាប់ក្នុងទីសមគួរ ពោលថា ៖

"បពិត្រលោកបណ្ឌិត សេចក្តីសង្ស័យបានកើតឡើងដល់ពួកយើង សូមលោកមេត្តាជួយបន្ទោបង់សេចក្តីសង្ស័យរបស់យើងនោះ" ។

ហើយបានពោលដូច្នេះ ៖

"បុច្ឆាម កត្តារមនោមបញ្ញំ,
កថាសុ នោ វិគ្គហោ អត្ថិ ជាតោ;
ឆិន្ទជ្ជ កង្ខំ វិចិកិច្ឆិតានិ,
តទជ្ជ កង្ខំ វិតរេមុ សព្វេ" ។

"ម្នាលអ្នកមានប្រាជ្ញាមិនថមថយ យើងទាំងឡាយ សូមសួរចំពោះអ្នកជាអ្នកធ្វើហេតុដែលគួរធ្វើ ការជជែកចំពោះពាក្យទាំងឡាយ កើតមានដល់យើង សូមអ្នកកាត់នូវសេចក្តីងឿងឆ្ងល់ និងសេចក្តីសង្ស័យចេញ ក្នុងថ្ងៃនេះយើងទាំងអស់គ្នាគប្បីឆ្លងសេចក្តីសង្ស័យនោះឲ្យខាងតែបាន" ។

បណ្ឌិតកាលបានស្តាប់ពំនោលរបស់ជនទាំងនោះហើយតបថា ៖

"បពិត្រមហារាជទាំងឡាយ សម្តីប្រទាំងប្រទើសគ្នាកើតឡើង ដោយអាស្រ័យសីលរបស់ពួកព្រះអង្គ ទូលបង្គំនឹងដឹងសម្តីខាងណាត្រឹមត្រូវ ឬមិនត្រឹមត្រូវបាន" ។

ហើយវិធុរបណ្ឌិតបានបន្តពោលថា ៖

"យេ បណ្ឌិតា អត្ថទសា ភវន្តិ,
ភាសន្តិ តេ យោនិសោ តត្ថ កាលេ;
កថំ នុ កថានំ អភាសិតានំ,
អត្ថំ នយេយ្យុំ កុសលា ជនិន្ទា" ។

"បណ្ឌិតណាជាអ្នកយល់សេចក្តី បណ្ឌិតនោះតែងពោលដោយឧបាយនៃប្រាជ្ញាក្នុងកាលគួរ ក្នុងពាក្យជជែកនោះ បពិត្រព្រះអង្គជាធំជាងជនទាំងឡាយ ពួកជនអ្នកឈ្លាសគប្បីយល់នូវសេចក្តីនៃពាក្យពោលដែលគេមិនទាន់និយាយ ដោយប្រការដូចម្តេចបាន ? លុះណាតែពួកព្រះអង្គមានព្រះរាជឱង្ការប្រាប់អ្វីដែលព្រះអង្គបានជជែក ដល់ទូលបង្គំមុនសិន" ។

វិធុរបណ្ឌិតសួរស្តេចមួយអង្គ ៗ ដូច្នេះ ៖

"កថំ ហវេ ភាសតិ នាគរាជា,
គរុឡោ បន វេនតេយ្យោ កិមាហ;

គន្ធព្វរាជា បន កិំ វទេតិ,
កថំ បន កុរូនំ រាជសេដ្ឋោ" ។

"ស្តេចនាគពោលដូចម្តេច ? ស្តេចគ្រុឌវេនតេយ្យពោលដូចម្តេច ? ស្តេចគន្ធព្វ (ព្រះឥន្ទ្រ) ពោលដូចម្តេច ? ស្តេចដ៏ប្រសើររបស់អ្នកដែនកុរុ ពោលដូចម្តេច ?"

គ្រានោះ ស្តេចទាំងឡាយបានឆ្លើយចំពោះវិធុរបណ្ឌិតថា ៖

"ខន្តិំ ហវេ ភាសតិ នាគរាជា,
អប្បាហារំ គរុឡោ វេនតេយ្យោ;
គន្ធព្វរាជា រតិវិប្បហានំ,
អកិញ្ចនំ កុរូនំ រាជសេដ្ឋោ" ។

"ស្តេចនាគពោលចំពោះខន្តិធម៌តែម្យ៉ាង ស្តេចគ្រុឌវេនតេយ្យពោលចំពោះអាហារតិច ស្តេចគន្ធព្វពោលចំពោះការលះបង់សេចក្តីត្រេកអរ ស្តេចដ៏ប្រសើររបស់អ្នកដែនកុរុ ពោលចំពោះការមិនមានកង្វល់" ។

គ្រានោះ មហាសត្តស្តាប់ពាក្យរបស់ពួកទ្រង់ហើយ លោកបានពោលតបថា ៖

"សព្វានិ ឯតានិ សុភាសិតានិ,

ន ហោតុ ទុព្ភាសិតមត្ថិ កិញ្ចិ;
យស្មិញ្ច ឯតានិ បតិដ្ឋិតានិ,
អការ ឆាក្យា សុសមោហិតានិ;
ចតុព្ភិ ធម្មេហិ សមង្គិភូតំ,
តំ វេ នរំ សមណមាហុ លោកេ" ។

*"ពាក្យទាំងអស់នេះ ជាសុភាសិត[២០], ពាក្យជាទុព្ភាសិត[២១] សូម្បីបន្តិចបន្តួច ក៏មិនមានក្នុងប្រស្នានេះទេ ។ ម្យ៉ាងទៀត ពាក្យទាំងនេះ តាំងនៅស៊ប់ប្រជុំចុះដោយល្អ ក្នុងបុគ្គលណា ដូចជាកាំរទេះដែលគេបញ្ចុះស៊ប់ក្នុងដុំ បណ្ឌិតទាំងឡាយហៅបុគ្គលដែលដល់ព្រមដោយធម៌ ៤ យ៉ាងនោះឯង ថាជាសមណៈ ក្នុងលោក" ។*

---

[២០] (គុ.) (បា.),(សំ.) (សុភាសិត) ដែលពោលពីរោះ, ដែលនិយាយត្រូវ, ដែលថាត្រូវ (នាំឲ្យសម្រេចប្រយោជន៍បានដោយប្រពៃ) : ពាក្យសុភាសិត, កាព្យសុភាសិត ។ ន. ពាក្យពីរោះ, ពាក្យត្រូវ, ឱវាទត្រឹមត្រូវ (ដែលមានប្រយោជន៍គួររៀនគួរស្ដាប់) : មានសុភាសិតបុរាណថា អូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក ធ្វើអ្វី ៗ កុំឲ្យមានមោះហ្មង ហើយឲ្យកើតការដោយស្រួលផង ។ល។

[២១] (គុ.), (ន.) (បា.),(សំ.) (ទុប-ភា--) (ទុភ៌ាសិត) សម្ដីអាក្រក់, ពាក្យគំរោះគំរើយ : កុំគប្បីពោលនូវទុព្ភាសិត; កុំថាឡើយដល់មនុស្ស សូម្បីតែតិរច្ឆានក៏រមែងមិនគាប់ចិត្តចំពោះទុព្ភាសិតដែរ ។ ឈ្មោះអាបត្តិពួកមួយ (ក្នុងអាបត្តិ ៧ កង) ជាទោសសម្រាប់បព្វជិតក្នុងព្រះពុទ្ធសាសនា : អាបត្តិទុព្ភាសិត ឬ ទុព្ភាសិតាបត្តិ ។

## ស្តេចទាំង ៤ បូជាវិធុរបណ្ឌិត

*នេះបង្ហាញឲ្យឃើញថា មហាសត្តបានធ្វើសីលរបស់ស្តេចទាំង ៤ ជាត្រឹមត្រូវមួយផ្នែក ៗ ។ ទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ព្រះរាជាទាំង ៤ ព្រះអង្គត្រេកអរចំពោះវិធុរបណ្ឌិតនោះ ពួកទ្រង់ធ្វើការសរសើរថា ៖*

"តុវញ្ហិ សេដ្ឋោ ត្វមនុត្តរោសិ, ត្វំ ធម្មគូ ធម្មវិទូ សុមេធោ;
បញ្ញាយ បញ្ហំ សមធិគ្គហេត្វា, អច្ឆេច្ឆិ ធីរោ វិចិកិច្ឆិតានិ;
អច្ឆេច្ឆិ កង្ខំ វិចិកិច្ឆិតានិ, ចុន្ទោ យថា នាគទន្តំ ខរេន" ។

*"អ្នកជាបុគ្គលប្រសើរ អ្នកជាបុគ្គលមិនមានអ្នកណាវិសេសជាង អ្នកជាបុគ្គលដល់នូវត្រើយនៃធម៌ ចេះដឹងនូវធម៌ មានយោបល់ដ៏ល្អ កំណត់ដឹងនូវប្រស្នាដោយប្រាជ្ញា អ្នកជាអ្នកប្រាជ្ញ បានផ្តាច់សេចក្តីសង្ស័យចេញហើយ អ្នកបានកាត់នូវសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ ដូចជាគេកាត់នូវភ្លុកនៃដំរីដោយរណារ" ។*

*ស្តេចទាំង ៤ នោះសប្បាយព្រះទ័យជាពន់ពេកជាមួយនឹងដំណោះស្រាយ របស់វិធុរបណ្ឌិតនោះ ។ គ្រានោះ សក្កទេវរាជបូជាវិធុរបណ្ឌិតដោយសំពត់ទិព្វ ៖*

"នីលុប្បលាភំ វិមលំ អនគ្ឃំ, វត្ថំ ឥទំ ធូមសមានវណ្ណំ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ, ទទាមិ តេ ធម្មបូជាយ ធីរ។

"បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះប្រស្នារបស់អ្នក ខ្ញុំបូជាសំពត់នេះមានពន្នឺដូចផ្កាឧប្បលខៀវ មិនមានមន្ទិល ជាសំពត់កាត់ថ្លៃមិនបាន មានពណ៌ស្មើផ្សែង បូជានូវធម៌របស់អ្នក" ។

សុបណ្ណរាជ ដែលជាស្ដេចគ្រុឌបូជាដោយសុវណ្ណមាលា ៖

"សុវណ្ណមាលំ សតបត្តផុល្លិតំ, សកេសរំ រត្នសហស្សមណ្ឌិតំ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ, ទទាមិ តេ ធម្មបូជាយ ធីរ។

"បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះប្រស្នារបស់អ្នក ខ្ញុំបូជានូវកម្រងផ្កាមាស ដែលរីកសំពោងដោយត្របកច្រើនស្រទាប់ ប្រកបដោយលម្អង ដ៏ប្រដាប់ដោយកែវដ៏ច្រើន ដើម្បីបូជានូវធម៌របស់អ្នក" ។

វរុណនាគរាជ បូជាដោយកែវមណី ៖

"មណឹ អនគ្ឃំ រុចិរំ បភស្សរំ, កណ្ឋាវសត្តំ មណិភូសិតំ មេ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ, ទទាមិ តេ ធម្មបូជាយ ធីរ។

"បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះប្រស្នារបស់អ្នក ខ្ញុំជូននូវកែវមណីដែលកាត់ថ្លៃមិនបាន ជាកែវដ៏រុងរឿងមានពន្លឺផ្លេក ៗ សម្រាប់ពាក់ពួដ័កដែលស្អិតស្អាងដោយកែវមណីដើម្បីបូជានូវធម៌របស់អ្នក" ។

ស្តេចដែនកុរុ ធនញ្ជយរាជ បូជាដោយគោ ១.០០០ ជាដើម ៖

"គវំ សហស្សំ ឧសភញ្ច នាគំ,
អាជញ្ញយុត្តេ ច រថេ ទស ឥមេ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ,
ទទាមិ តេ គាមវរានិ សោឡស" ។

"បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះប្រស្នារបស់អ្នក ខ្ញុំបូជានូវគោ ១.០០០ ទាំងគោឧសភៈផង ដំរីផង រថ ១០ ដែលទឹមដោយសេះអាជានេយ្យនេះផង ស្រុកសួយ ១៦ ផង ដល់អ្នក" ។

សក្កទេវរាជជាដើម បានបូជាមហាសត្វយ៉ាងនេះ ហើយបានទៅកាន់លំនៅឋានរៀង ៗ ខ្លួនវិញ ។

ចតុបោសថកណ្ឌ ចប់ ។

# ជំពូកទី ២

## ជំងឺចង់បានបេះដូងវិធុរៈ

### វិមលាទេវីធ្វើពុតចង់បាន

*បណ្ដាស្ដេចទាំង ៤ អង្គនោះ ភរិយារបស់ស្ដេចនាគ ព្រះនាមថា **វិមលាទេវី** ។ វិមលាទេវីនោះ កាលមិនឃើញកែវមណីជាគ្រឿងប្រដាប់ ព្វង់ករបស់ព្រះស្វាមី បានសួរថា ៖*

*"បពិត្រព្រះសម្មតិទេព ចុះឯណាកែវមណីរបស់ព្រះអង្គ ?"*

*នាគរាជ ៖*

*"ហៃអូនសម្លាញ់ បងស្ដាប់ធម្មកថារបស់វិធុរបណ្ឌិត ជាកូនរបស់ចន្ទព្រាហ្មណ៍ កើតចិត្តជ្រះថ្លា ខ្ញុំក៏បូជាបណ្ឌិតនោះ ដោយកែវមណីនោះទៅ, មិនមែនតែខ្ញុំម្នាក់ឯងទេ សូម្បីសក្កៈក៏លោកបូជាបណ្ឌិតនោះ ដោយសំពត់ទិព្វដែរ, ឯសុបណ្ណរាជ បូជាដោយកម្រងផ្កាមាស, ស្ដេចធនញ្ជ័យបូជាដោយគោ ១.០០០ ជាដើម" ។*

*វិមលា ៖*

*"ចុះបណ្ឌិតនោះ ជាធម្មកថិកឬ ព្រះសម្មតិទេព ?"*

នាគរាជ ពណ៌នាគុណរបស់វិធុរបណ្ឌិតយ៉ាងនេះ ៖

"អូននិយាយអីអ៊ីចឹង, បណ្ឌិតនោះប្រព្រឹត្តទៅបីដូចពុទ្ធុប្បាទ[២២] ក្នុងផ្ទៃជម្ពូទ្វីប ព្រះរាជា ១០១ អង្គ ក្នុងសកលជម្ពូទ្វីប ភ្ញាក់ស្មារតីដោយធម្មកថាដ៏ពីរោះរបស់បណ្ឌិតនោះ ពួកទ្រង់មិនប្រាថ្នាទៅកាន់រាជាណាចក្ររបស់ខ្លួនវិញឡើយ ហាក់ដូចជាដំរីស្រវឹងដែលត្រូវគេល្បួងដោយសំឡេងពិណឈ្មោះហត្ថិកន្តៈ, បណ្ឌិតនោះជាធម្មកថិកសម្ដែងធម៌ពីរោះ បែបនេះផង បែបនោះផង" ។

វិមលាទេវីស្ដាប់គុណកថា របស់វិធុរបណ្ឌិតហើយ មានបំណងចង់ស្ដាប់ធម្មកថារបស់វិធុរបណ្ឌិតដែរ ព្រះនាងបានគិតថា "ប្រសិនបើអញប្រាប់ថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មានបំណងស្ដាប់ធម្មកថារបស់វិធុរបណ្ឌិតនោះ សូមព្រះអង្គនាំគេមកទីនេះ, ដូច្នេះ ទ្រង់នឹងពុំនាំគេមកឡើយ បើដូច្នោះ មានតែអញប្រើល្បិចរបស់អ្នកឈឺ គឺធ្វើជាកើតចំណង់ចាញ់កូន ចង់បានបេះដូងរបស់បណ្ឌិតនោះ" ។ ព្រះនាងវិមលាទេវី ធ្វើយ៉ាងនោះហើយ ចូលកាន់បន្ទប់ផ្ទុំ ឲ្យសញ្ញាដល់ពួកនាងបរិចារិកា[២៣]នៃខ្លួន ហើយសំងំដេកលើក្រឡាបន្ទំ ។ នាគរាជជាស្វាមី

---

[២២] (ន.) (បា.) (ពុត-ធុប-បាត) កាល ឬសម័យដែលកើតមានព្រះពុទ្ធ គឺកាលដែលមានព្រះពុទ្ធបានត្រាស់ : កើតទាន់ពុទ្ធុប្បាទ, ក្នុងពុទ្ធុប្បាទនេះ ។

[២៣] (ន.) (សំ.),(បា.) (ប៉ៈរ៉ិចារ៉ិកា) ស្រីអ្នកបម្រើ គឺស្រីដែលសម្រាប់ប្រើប្រាស់ឲ្យធ្វើការងារផ្សេង ៗ ។

មិនឃើញព្រះនាង ក្នុងពេលតើនឡើង ទ្រង់សួរពួកនាងបរិចារិកាថា ៖

"ឯណា ព្រះនាងវិមលា អគ្គមហេសីយើង ?"

ពួកបរិចារិកា ៖

"ព្រះនាងប្រឈួនហើយ ព្រះសម្មតិទេព" ។

នាគរាជ ស្ទុះក្រោកអំពីអាសនៈ យាងទៅកាន់សម្នាក់របស់ព្រះនាង ទ្រង់ប្រថាប់ចុងគ្រែ ច្របាច់សរីរៈសួរដូច្នេះ ៖

"នាងមានសម្បុរលឿង ស្គាំងស្គម មានកម្លាំងតិច ពីដើមរូបសម្បុររបស់នាង មិនមែនបែបនេះទេ ម្នាលនាងវិមលា បងសួរហើយ នាងចូរប្រាប់ តើវេទនា[២៤]ក្នុងសរីរៈរបស់នាងដូចម្តេច ?"

គ្រានោះ នាងវិមលា ប្រាប់ដល់នាគរាជថា ៖

"ធម្មោ មនុជេសុ មាតីធំ, ទោហឡោ នាម ជនិន្ទ វុច្ចតិ;

---

[២៤] (ន.) (សំ.),(បា.) (--ទ:--) ការទទួលអារម្មណ៍, ការសោយឬការរងអារម្មណ៍, ការដឹងអារម្មណ៍ជាសុខឬជាទុក្ខ... ។ ច្រើនសំដៅចំពោះការទទួលអារម្មណ៍ជាទុក្ខ : គួរឲ្យមានវេទនាណាស់ ! ។ ពោលតាមគម្ពីរពុទ្ធសាសនា វេទនា មាន ៥ យ៉ាងគឺ ១-សុខវេទនា ការទទួលអារម្មណ៍ជាសុខ; ២-ទុក្ខវេទនា... ជាទុក្ខ; ៣-ឧបេក្ខាវេទនា... ជាឧបេក្ខា; ៤-សោមនស្សវេទនា...ជាសោមនស្ស; ៥-ទោមនស្សវេទនា... ជាទោមនស្ស។

ធម្មាហដំ ឆាគកុញ្ជរ, វិធុរស្ស ហទយាភិបត្ថយេ" ។

*"បពិត្រព្រះអង្គជាធំជាងនាគជន ទំនៀមរបស់ស្ត្រីទាំងឡាយក្នុងពួកមនុស្សដែលមានគភ៌ គេហៅថាចំណង់ប្លែក បពិត្រព្រះអង្គជាកុញ្ជរ[២៥]របស់នាគ ខ្ញុំម្ចាស់ចង់បានបេះដូងរបស់វិធុរបណ្ឌិតដែលត្រូវនាំយកមកដោយធម៌" ។*

*ទ្រង់ព្រះសណ្ដាប់ដូច្នោះ នាគរាជត្រាស់ថា ៖*

*"ម្នាលនាងវិមលា នាងចង់បានបេះដូងរបស់វិធុរបណ្ឌិតនោះ ដូចបុគ្គលប្រាថ្នាព្រះចន្ទ ព្រះអាទិត្យ ឬព្រះពាយ ព្រោះថា ការជួបប្រទះនឹងវិធុរបណ្ឌិត គេគប្បីបានដោយកម្រ នរណានឹងនាំព្រះវិធុរបណ្ឌិតមកក្នុងពិភពនាគនេះបាន ?"*

## ស្ដេចនាគប្រើកូនក្រមុំឈ្មោះឥរន្ធតីរកប្រុសខ្លាំង

*ព្រះនាងវិមលា គ្រាន់តែឮពាក្យរបស់ស្វាមីនោះហើយ ក៏តបថា ៖ "កាលបើខ្ញុំមិនបានហឫទ័យរបស់វិធុរបណ្ឌិត ខ្ញុំមុខតែស្លាប់នៅទីនេះឯង" ។*

---

[២៥] (ន.) (សំ.),(បា.) *សត្វចតុប្បាទមានប្រមោយ (ដំរី) ។ គុ. ប្រសើរ, ខ្ពង់ខ្ពស់ ។*

ហើយព្រះនាងបែរខ្នងឲ្យខ្នងទៅស្វាមី ខ្ទប់មុខដោយជាយកន្សែងផ្ទំទៅវិញ ។ នាគរាជ មិនសប្បាយព្រះទ័យ ចូលទៅកាន់បន្ទប់ផ្ទំរបស់ខ្លួន គង់លើគ្រែ គិតសញ្ជប់សញ្ជឹងថា ៖

"វិមលាសូមឲ្យនាំយកបេះដូងរបស់វិធុរបណ្ឌិត កាលបើវិមលាមិនបានបេះដូងរបស់វិធុរបណ្ឌិតទេ ជីវិតរបស់នាងនឹងមិនមាន តើអាត្មាអញ នឹងបានបេះដូងរបស់វិធុរបណ្ឌិតនោះដោយឧបាយដូចម្ដេចហ្ន៎ ?"

គាប់ចួនពេលនោះ ធីតារបស់នាគរាជ ឈ្មោះ **ឥរន្ទតី** នាងជានាគកញ្ញាប្រដាប់ដោយអលង្ការទាំងពួង បានមកកាន់ទីបម្រើរបស់ព្រះបិតា ដោយដំណើរល្វាសល្វន់[២៦]អស្ចារ្យ ថ្វាយបង្គំព្រះបិតា រួចឈរក្នុងទីសមគួរ ។ រាជធីតាឃើញនូវវិការៈ[២៧]នៃឥន្ទ្រិយរបស់ព្រះបិតានោះក៏ទូលសួរថា ៖

"បពិត្រព្រះបិតា ព្រះអង្គកើតទោមនស្សខ្លាំង ព្រោះហេតុអ្វី ?

---

[២៦] (គុ.) ទន់ភ្ជន់ល្វត : ល្វានរាំចាក់ក្បាច់ល្វាសល្វន់ ។

[២៧] (ន.) (សំ.),(បា.) (--ការៈ ឬ--កា) ការធ្វើប្លែកចាកប្រក្រតីដើម; ការផ្លាស់ប្រែ; ការផ្លាស់រូប, ផ្លាស់ទំនង; ការប្រែប្រួលចាកភាពប្រក្រតី, ការប្រែប្រួលខុសធម្មតា; ដំណើរពិការ; រោគ ។ វិការរូប រូបដែលប្រែប្រួលខុសប្រក្រតី, រូបពិការ ។ កាយវិការ ការប្រែប្រួលកាយ; ការកម្រើកកាយ (មានលើកដៃ, លើកជើងជាដើម) ។ល។

"បពិត្របិតា ហេតុអ្វីហ្ន៎ ព្រះអង្គសញ្ជប់សញ្ជឹង ព្រះកក្រ្តរបស់ព្រះអង្គ ដូចជាផ្កាឈូកដែលគេឈ្លីដោយដៃ បពិត្រព្រះអង្គជាឥស្សរៈ[២៨] ព្រះអង្គតូចព្រះហឫទ័យដូចម្តេច បពិត្រព្រះអង្គអ្នកញាំងសត្រូវឲ្យក្តៅ សូមព្រះអង្គកុំទ្រង់សោយសោកឡើយ" ។

ឮពាក្យបុត្រីហើយ នាគរាជប្រាប់នូវសេចក្តីនោះថា ៖

"ម្នាលនាងឥរន្ទតី មាតារបស់នាងចង់បានហឫទ័យរបស់វិធុរបណ្ឌិត តែការជួបនឹងវិធុរបណ្ឌិត គេគប្បីបានដោយក្រ នរណានឹងនាំវិធុរបណ្ឌិតមកក្នុងពិភពនាគនេះបាន" ។

គ្រានោះ នាគរាជបង្គាប់កូនស្រីថា ៖

"ហៃកូនស្រី បុគ្គលអ្នកមានសមត្ថភាពនាំវិធុរមកក្នុងសម្នាក់របស់បិតា មិនមានទេ, នាងចូរឲ្យជីវិតដល់ព្រះមាតាផង, នាងចូរស្វែង

---

[២៨] (គុ.), (ន.) (បា.),(សំ.) (អ៊ិស-សៈរ៉ៈ) (ឥស្សរ; ឦឝ្វរ) ឥសូរ ។ ឥស្សរចិត្ត (បា. ស.) ដំណើរស្រេចនឹងចិត្ត ។ ឥស្សរជន ឬ--បុគ្គល ជនឬបុគ្គលជាឥស្សរៈ (អ្នកធំ) ។ ឥស្សរភាព ភាពនៃអ្នកធំ; ភាវៈជាឥស្សរៈ ។ ឥស្សរសព្ទ សព្ទឬពាក្យសម្រាប់និយាយទៅរកឥស្សរជន (ដូចជា ខ្ញុំប្របាទ, ប្របាទម្ចាស់ ជាដើម) ។ ឥស្សរាធិបតី អធិបតីនៃពួកឥស្សរជន ។ ឥស្សរានុភាព អានុភាពនៃអ្នកធំ ។ល។

រកនូវភស្តា[២៩] ដែលមានសមត្ថភាពនាំវិធុរបណ្ឌិតមកទីនេះ ។ ភស្តាណានាំវិធុរបណ្ឌិតមកក្នុងទីនេះបាន នាងចូរត្រាច់ទៅស្វែងរកភស្តានោះចុះ" ។

## ឥរន្ទតីច្រៀងចម្រៀងអំពាវនាវរកប្តី

តាមប្រការដូចដែលពោលមកនេះ នាគរាជនោះបាននិយាយនូវសម្តីមិនសមគួរ ដល់កូនស្រីបង្ហាញពីភាពនៃខ្លួនជាអ្នកជ្រប់[៣០] ក្នុងកិលេស ។ នាងឥរន្ទតីនោះ លុះបានស្តាប់បន្ទូលព្រះបិតាហើយ លួងលោមបិតា រួចក៏ទៅកាន់សម្នាក់ព្រះមាតា ក៏លួងលោមមាតានោះទៀត ហើយចូលទៅកាន់ទីផ្ទះរបស់ខ្លួន តុបតែងខ្លួនដោយអលង្ការទាំងពួង ស្លៀកសំពត់ក្រហមដូចផ្កាដកគាំ[៣១] មួយផ្ទាំង ពាក់ធៀងស្មាមួយផ្ទាំង ជ្រែកទឹកចេញទៅស្វែងរកប្តីក្នុងរាត្រីនោះតែម្តង ។ ក្នុងរាត្រីនោះ នាងឥរន្ទតី ដោកដាំដោយរាគៈ[៣២] ក្នុងការត្រាច់ស្វែងរកស្វាមី នាងចេញ

---

២៩ (ន.) (បា.),(សំ.) (ដើម ដ, អ. ថ. ភ័ស-ស្តា) (ភត្តា < ភត្តុ; ភត៌ា < ភត្ត៌ុ) ស្វាមី (ប្តី); ខ្មែរប្រើជារាជសព្ទ: ព្រះភស្តា, សម្តេចព្រះភស្តា (ច្រើនប្រើក្នុងកាព្យទេស្នា ឬកាព្យ) ។

៣០ (កិ.), (កិ. វិ.) ឱនងប់ដោយកើតទុក្ខខ្លាំងឬដោយឈឺក្បាល : វាចេះតែជ្រប់ ឥតងើបមុខសោះ, អង្គុយជ្រប់, ឈរជ្រប់រាល់តែថ្ងៃ ។

៣១ (ន.) (ស.) (ដកគាំ អ. ថ. ដកខាំ) ឈ្មោះផ្កាពណ៌ក្រហមស្រគាំប្រើជាគ្រឿងជ្រលក់ : សំពត់ជ្រលក់ដកគាំ ។ មានមួយប្រភេទផ្សេងទៀតជាគ្រាប់ : គ្រាប់ដកគាំ ។

៣២ (ន.) (សំ.),(បា.) (រាគ) តម្រេក, សេចក្តីរីករាយ, ត្រេកត្រអាល ចំពោះកាម : ត្រូវរាគៈគ្របសង្កត់ ។

អំពីភពនាគ ទៅកាន់អញ្ជនគិរីឈ្មោះថា **កាឡបព៌ត** ដែលមានរាងជាដុំមួយកម្ពស់ ៦០ យោជន៍ ឋិតនៅលើឆ្នេរសមុទ្រ ក្នុងហិមវន្តប្បទេស ។ ក្នុងពេលកំពុងធ្វើដំណើរ នាងតែងបេះប្រឡេះនូវបុប្ផាទាំងឡាយដែលបរិបូរដោយពណ៌និងក្លិនក្នុងព្រៃហិមពាន្ត មកតុបតែងលម្អភ្នំទាំងអស់ឲ្យដូចជា កែវមណីដ៏មានតម្លៃ រួចនាងធ្វើនូវកម្រាលផ្កាលើផ្ទៃជាន់លើ រាំរែកដោយអាការៈគួរឲ្យរីករាយ ទាំងច្រៀងនូវចម្រៀងដ៏ពីរោះល្វេងល្វើយ[៣៣] ដូច្នេះ ៖

"កោ គន្ធព្វេ រក្ខសេ ច នាគេ, កោ កិម្បុរិសេ ចាបិ មានុសេ;
កោ បណ្ឌិតេ សព្វកាមទទេ, ទីឃរត្តំ ភត្តា មេ ភវិស្សតិ" ។

"នរណាទោះជាគន្ធព្វក្តី ជាអារក្សទឹកក្តី ជានាគក្តី ជាកិន្នរក្តី ជាមនុស្សក្តី ជាបណ្ឌិតដែលឲ្យសម្រេចសេចក្តីប្រាថ្នាទាំងពួងក្តី នរៈនោះ នឹងជាភស្តារបស់ខ្ញុំ អស់កាលដ៏យូរអង្វែង" ។

[៣៣] (គុ.) ដែលមានសូរលាន់ឮរងំ ឬដែលផ្សាយក្លិនក្រអូបល្វើយៗ គួរឲ្យស្រណោះ, គួរឲ្យចាប់ចិត្ត : សូរភ្លេងល្វេងល្វើយ; ផ្កាក្នុងព្រៃក្រអូបល្វេងល្វើយ, ពិដោរល្វេងល្វើយ ។

## បុណ្ណកសេនាបតីយក្សចែចូវនាងឥរន្ទតី

ក្នុងខណៈនោះ នាយសេនាបតីយក្ស ឈ្មោះបុណ្ណកៈ ដែលត្រូវជាក្មួយរបស់វេស្សវ័ណ[៣៤]មហារាជ កំពុងជិះសេះសិន្ធពដែលសម្រេចអំពីចិត្តប្រមាណ ៣ គាវុត កាត់តាមកំពូលភ្នំកាឡៈទៅកាន់សមាគមយក្ស ក៏បានឮនូវសូរចម្រៀង របស់នាគមាណវិកានោះ ។ សំឡេងចម្រៀងរបស់ស្ត្រីដែលធ្លាប់រួមរសជាមួយគ្នា ក្នុងអត្តភាពមុនបន្ទាប់ពីជាតិនេះ វាបានផ្សាយជ្រួតជ្រាបទៅកាត់តាមសម្បុរថ្ងៃជាដើម ចាក់ចូលដល់ទៅខួរក្នុងឆ្អឹងរបស់បុណ្ណកយក្សសេនាបតីនោះ ។ បុណ្ណកយក្សសេនាបតី មានចិត្តប្រតិព័ទ្ធចំពោះនាគមាណវិកានោះ ទោះកំពុងជិះលើខ្នងសេះសិន្ធពយ៉ាងលឿនស្ទេរទៅមុខក៏ដោយ ក៏សុខចិត្តទាញបង្ហៀរសេះឲ្យ ត្រឡប់ក្រោយវិញ មកលួងលោមនាងថា ៖

"ឱកែវកនិដ្ឋា បងមានបញ្ញា អង់អាចក្លាហាន
អាចយកបេះដូង នៃវិធុរបាន ដោយធម៌សមាន
កុំកែវបារម្ភ។

[៣៤] (ន.) (បា.),(សំ.) (វេស-សៈ--) (វេស្សវណ; វៃគ្រវណ) ព្រះនាមលោកបាលមហារាជមួយអង្គ ជាអ្នកគ្រប់គ្រងរក្សាទិសឧត្តរ ជាអធិបតីលើពួកយក្ស : ព្រះបាទវេស្សវ័ណ; ព្រះនាមដើមហៅ កុវេរៈ, តែដោយហេតុដែលទ្រង់គង់នៅក្នុងរាជធានីឈ្មោះ វិសាណា ទើបមានព្រះនាមថា វេស្សវ័ណ ផង, គេច្រើនប្រើពាក្យថា ព្រះបាទវេស្សវ័ណកុវេររាជ ។

លុះពោលដូច្នេះហើយ បុណ្ណកយក្សសេនាបតីបានបន្តពោលដូច្នេះ ៖

"ភ្នែកស្អាតឥតខ្ចោះ ទាំងរូបសម្រស់ អូនកុំសោកា
អូនជាភរិយា បងជាភស្តា ដោយសារបញ្ញា
យ៉ាងដូច្នោះឯង ។

គ្រានោះ នាងឥរន្ទតី មានចិត្តក្ដួចប្រតិព័ទ្ធបុណ្ណកយក្ស ព្រោះទាំងពីរនាក់ ធ្លាប់រួមរសជាប្ដីប្រពន្ធក្នុងជាតិមុនបន្ទាប់ពីជាតិនេះ ហើយនាងក៏បបួលបុណ្ណកយក្សថា ៖

"បើដូច្នោះ តោះយើងទៅកាន់សម្នាក់ព្រះបិតារបស់ខ្ញុំ បិតាខ្ញុំនឹងប្រាប់សេចក្ដីនុ៎ះដល់អ្នក" ។

បុណ្ណកសេនាបតិយក្ស ឮនាងនិយាយយ៉ាងនេះ គិតថា "អញនឹងលើកនាងដាក់លើខ្នងសេះនាំទៅធ្វើប្រពន្ធតែម្ដង" ក៏ចុះពីលើកំពូលភ្នំ លាដៃរបស់ខ្លួនដើម្បីចាប់បីត្រកងនាង ។ នាងឥរន្ទតីនោះ មិនឲ្យនូវការចាប់ដៃរបស់ខ្លួនដល់បុណ្ណកៈទេ តែនាងបែរជាឈោងដៃខ្លួនទៅចាប់ដៃបុណ្ណកយក្សដែលកំពុងលានោះវិញ រួចពោលថា ៖

ឱ! បងសម្លាញ់ រូបអូននេះវិញ ឥតអនាថា
គឺខ្ញុំមានឪ ជានាគរាជា ទ្រង់ព្រះនាមថា
ព្រះបាទវរុណ ។

រីព្រះមាតា ជាក្សត្រិយា- នីល្អវរសុន្ទរ៍
ព្រះនាមទេវី វិមលាគុណធ្ងន់ ពួកទ្រង់មានជន្ម
គង់ធរមានទៅ ។

តោះពួកយើងឆាប់ ទៅជាប្រញាប់ ជួបបិតាពៅ
គង់តែទ្រង់ប្រាប់ ឧបាយត្រឹមត្រូវ មង្គលស្រីពៅ
ហើយនឹងរៀមរ៉ា ។

## នាងឥរន្ទតីនាំបុណ្ណកយក្សទៅភពនាគ

លុះពោលយ៉ាងនេះហើយ នាងឥរន្ទតី ដែលតាក់តែងខ្លួន ស្លៀកដណ្ដប់ល្អ ទ្រទ្រង់កម្រងផ្កា ប្រោះព្រំដោយខ្លឹមចន្ទន៍ ចាប់ដៃបុណ្ណកយក្ស នាំចូលទៅកាន់សម្នាក់ព្រះបិតារបស់នាង ។ ចំណែកបុណ្ណកយក្សសេនាបតី ព្រមទៅតាមលុះដល់ទៅសម្នាក់របស់នាគរាជ ក៏ពោលសូមនាងឥរន្ទតីថា ៖

"នាគវរ វចោ សុណោហិ មេ, បតិរូបំ បដិបជ្ជ សុង្កិយំ;
បត្ថេមិ អហំ ឥរន្ធតិំ, តាយ សមង្គិំ ករោហិ មំ តុវំ ។
សតំ ហត្ថី សតំ អស្សា, សតំ អស្សតរីរថា;
សតំ វលភិយោ បុណ្ណា, នានារត្នស្ស កេវលា;
តេ នាគ បដិបជ្ជស្សុ, ធីតរំ ទេហិរន្ធតិំ" ។

"បពិត្រព្រះអង្គដ៏ប្រសើរជាងពួកនាគ សូមព្រះអង្គ ទ្រង់ព្រះសណ្ដាប់ពាក្យរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គទ្រង់ទទួលសួយ[៣៥]ដ៏សមគួរដល់ត្រកូលនិងប្រទេសរបស់ព្រះអង្គ ខ្ញុំព្រះអង្គចង់បាននាងឥរន្ទតី សូមព្រះអង្គព្រះមេត្តាផ្សំផ្គុំទូលព្រះបង្គំជាមួយនឹងនាងឥរន្ទតីនោះ" ។ បពិត្រព្រះអង្គដ៏ប្រសើរ សូមព្រះអង្គទ្រង់ទទួលនូវសួយទាំងនោះ គឺដំរី ១០០ សេះ ១០០ រថទឹមដោយសេះអស្សតរ ១០០ នឹងរទេះ ដែលផ្ទុកពេញដោយរតនវត្ថុផ្សេង ៗ ទាំងអស់ ១០០ សូមព្រះអង្គទ្រង់ព្រះរាជទានធីតាឈ្មោះឥរន្ទតីដល់ទូលបង្គំ ក្រាបទូល" ។

គ្រានោះ នាគរាជនិយាយនឹងបុណ្ណកយក្សសេនាបតីថា ៖

"ឱ! អ្នកអើយ អ្នកចូរចាំយើងទៅពិភាក្សារក្សាជាមួយនឹងពួកញាតិមិត្រ ឬសម្លាញ់ដ៏ស្និទ្ធស្នាលសិន អំពើណាដែលយើងធ្វើដោយមិនបានប្រឹក្សា អំពើនោះ រមែងបណ្ដាលឲ្យកើតជាសេចក្ដីក្ដៅក្រហាយក្នុងកាលខាងក្រោយ" ។

---

[៣៥] (ន.) អាករ, មុខអាករ; ពន្ធខ្លួន; ពន្ធដែលត្រូវហូតយកក្នុងទីតំបន់មួយ ៗ, មុខគយ, មុខភាសី ។ សួយរ៉ៃ អាករដែលរ៉ៃគ្នាយកទៅជូនឥស្សរជន (ក្នុងសម័យបុរាណ) ។

លុះនិយាយយ៉ាងនេះហើយនាគរាជនោះទៅកាន់សម្នាក់ភរិយា ហើយបានប្រឹក្សាជាមួយនឹងនាងថា ៖

"ម្នាលអូន បុណ្ណកយក្សនេះ បានមកសុំស្ដីដណ្ដឹងនាងឥរន្ទតីបុត្រីយើង យើងនឹងឲ្យនាងឥរន្ទតី ជាទីស្រឡាញ់របស់យើងដល់បុណ្ណកយក្សនោះ ហើយយើងនឹងបានវត្ថុជាទីត្រេកអរច្រើនជាថ្នូរមកវិញ" ។

ព្រះនាងវិមលា ពោលថា ៖

"បុណ្ណកយក្សមិនត្រូវបាននាងឥរន្ទតី ជាធីតារបស់យើងដោយទ្រព្យ មិនត្រូវបានដោយវត្ថុជាទីត្រេកអរទេ បើបុណ្ណកយក្សបានហឫទ័យរបស់វិធុរបណ្ឌិតដោយធម៌ ហើយនាំមកក្នុងពិភពនាគនេះ ទើបត្រូវបាននាងកុមារី ដោយសារវត្ថុជាទីត្រេកអរនុ៎ះ យើងមិនចង់បានទ្រព្យដទៃតទៅទៀតទេ" ។

## បុណ្ណកយក្សធានាទៅចាប់វិធុរបណ្ឌិត

លុះបានប្រឹក្សាជាមួយនឹងព្រះនាងវិមលាហើយ ក៏បានចេញអំពីលំនៅព្រះនាង ហៅបុណ្ណកយក្សមកប្រឹក្សាម្ដងទៀត ភ្លាម ៗ នោះថា ៖

"ន ធនេន ន វិត្តេន, លព្ភា អម្ហំ ឥរន្ធតី;
សចេ ចតុរំ ហទយំ បណ្ឌិតស្ស, ធម្មេន លទ្ធា ឥធ មាហរេសិ;

ឯតេន វិត្តេន កុមារិ លព្ភា, ធាញ្ញំ ធនំ ឧត្តរិ បត្ថយាម" ។

"អ្នកមិនត្រូវបាននាងឥរន្ទតី ជាធីតារបស់យើងដោយទ្រព្យ មិនត្រូវបានដោយវត្ថុជាទីត្រេកអរ ជាថ្នូរទេ បើអ្នកយកបេះដូងរបស់បណ្ឌិតបានដោយធម៌ ហើយនាំមកក្នុងពិភពនាគនេះ ទើបអ្នកត្រូវបាននាងកុមារី ដោយសារវត្ថុជាទីត្រេកអរនុ៎ះ យើងមិនចង់បានទ្រព្យដទៃតទៅទៀតទេ" ។

បុណ្ណកយក្សសេនាបតី ពោលថា ៖

"យំ បណ្ឌិតោត្យេកេ វទន្តិ លោកេ,
តមេវ ពាលោតិ បុនាហុ អញ្ញេ;
អក្ខាហិ មេ វិប្បវទន្តិ ឯត្ថ,
កំ បណ្ឌិតំ នាគ តុវំ វទេសិ" ។

"បពិត្រព្រះអង្គដ៏ប្រសើរ បុគ្គលពួកខ្លះក្នុងលោកនេះ ហៅមនុស្សណាថាជាបណ្ឌិត បុគ្គលឯទៀតបែរជាហៅបុគ្គលនោះថាជាពាលវិញ ពួកជនតែងជជែកគ្នាក្នុងរឿងនេះ សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គមកចុះ បពិត្រនាគរាជ ព្រះអង្គត្រាស់ហៅ អ្នកណាថាជាបណ្ឌិត ?"

នាគរាជ ពោលថា ៖

"កោរព្យរាជស្ស ធនញ្ចយស្ស,
យទិ តេ សុតោ វិធុរោ នាម កត្តា;
អានេហិ តំ បណ្ឌិតំ ធម្មលទ្ធា,
ឥរន្ធតី បទចរា តេ ហោតុ" ។

*"អាមាត្យឈ្មោះវិធុរៈរបស់ធនញ្ជយកោរព្យរាជ អ្នកក៏ធ្លាប់បានឮហើយ បើអ្នកបានបណ្ឌិតនោះដោយធម៌នាំមកទីនេះ ឥរន្ធតីធីតារបស់យើង ចូរបានជាភរិយារបស់អ្នកចុះ" ។*

## បុណ្ណកយក្សសូមសេចក្ដីអនុញ្ញាតពីស្ដេចវេស្សវ័ណ

*បុណ្ណកយក្សសេនាបតី លុះបានស្ដាប់ព្រះបន្ទូលរបស់វរុណនាគហើយ ក៏ក្រោកឡើង មានសោមនស្សត្រេកអរក្រៃលែង បានបង្គាប់ឧបដ្ឋាក[៣៦]របស់ខ្លួនថា ៖*

---

[៣៦] (ន.) (បា.),(សំ.) (អ៊ុប៉័ត-ឋាក) (ឧបស្ថាយិន៑) អ្នកនៅជិតឲ្យហៅប្រើ, អ្នកនៅបង្គាញមុខឲ្យប្រើប្រាស់, អ្នកបម្រើ; អ្នកគាល់បម្រើ; កូនក្មួយ : នៅធ្វើជាឧបដ្ឋាកចៅហ្វាយនាយ ។ ភិក្ខុជាឧបដ្ឋាកគ្រូ ភិក្ខុជាអ្នកបម្រើព្រះថេរៈជាគ្រូ ។ អ្នកទំនុកបម្រុង, អ្នកផ្គត់ផ្គង់, អ្នកផ្គង់ចតុប្បច្ច័យឬផ្គង់ចង្ហាន់ ។ ញោមឧបដ្ឋាក ឧបាសកឬទាយកជាអ្នកផ្គត់ផ្គង់បព្វជិត (បើស្ត្រីជា ឧបដ្ឋាយិកា) ។ ខ្មែរប្រើជា កិ. ក៏មាន "បម្រើ" : បងអញ្ជើញចុះ ! ខ្ញុំនៅឧបដ្ឋាកម៉ែ ។ ប្រើរៀងភ្ជាប់ពីខាងចុងសព្ទដទៃ, ដូចជា គិលានុបដ្ឋាក អ្នកបម្រើជំងឺ, អ្នកថែទាំទ្រាំមនុស្សឈឺ (បើស្ត្រីជា គិលានុបដ្ឋាយិកា;បារ. Infirmier,

"អ្នកចូរនាំសេះអាជានេយ្យ[៣៧] ដែលជាសត្វដឹងនូវហេតុតូចហេតុធំ ដែលបានសម្រិតសម្រាំងយកមកក្នុងទីនេះ ។ សេះនោះត្រចៀកវាត្រូវប្រដាប់ដោយមាស ក្រចកប្រដាប់ដោយកែវមណីមានពណ៌ក្រហម គ្រឿងបិទបាំងឰដ៏ទ្រូង ត្រូវប្រដាប់ដោយមាសឆ្អិនឈ្មោះជម្ពោនទៈ" ។

---

Infirmière) ។ ចុល្លុបដ្ឋាក ឬ ចូឡុបដ្ឋាក អ្នកបម្រើបម្រាស់, កូនក្មួយអ្នកបង្ហាញមុខឬអ្នកដើរតាមឲ្យប្រើប្រាស់តាមការ ។ ពុទ្ធុបដ្ឋាក អ្នកបម្រើព្រះពុទ្ធ : ព្រះមហាអានន្ទជាពុទ្ធុបដ្ឋាក ។ មាតុបដ្ឋាក បុត្រអ្នកបម្រើឬអ្នកផ្គត់ផ្គង់មាតា (បើបុត្រីជា មាតុបដ្ឋាយិកា) ។ រាជុបដ្ឋាក អ្នកគាល់បម្រើព្រះរាជា (បើស្ត្រីជា រាជុបដ្ឋាយិកា (ប្រើជា រាជូ-- ក៏បាន) ។

[៣៧] (ន.) (បា.),(សំ.) (--នៃ) (អាជានីយ ក៏មាន; អាជានេយ) អ្នកដែលដឹងសេចក្ដីឆាប់រួសរាន់, អ្នកមានចិត្តរួស, អ្នករហ័សដឹង ។ សេះមានពូជល្អ, សេះមានពូជលឿន; សេះមានល្បឿនលឿនរួសរាន់ទាន់ចិត្ត; សេះល្អដែលបង្ហាត់បានបទ : សេះអាជា-នេយ្យ ។ សេះសិន្ធពអាជានេយ្យ សេះសិន្ធពមានល្បឿនលឿនរួសរាន់ទាន់ចិត្ត ។ គម្ពីរពុទ្ធសាសនាប្រាប់សេចក្ដីថា អាជានេយ្យ មាន ៤ ប្រភេទគឺ ១-បុរសអាជានេយ្យ ព្រះពុទ្ធ, ព្រះអរហន្ត (បា. បុរិសាជានេយ្យ); ២-ដំរីអាជានេយ្យ ដំរីមង្គលដែលហ្មបង្ហាត់បានបទឬដំរីសឹក (បា. ហត្ថាជានេយ្យ); ៣-សេះអាជានេយ្យ សេះលឿនវិសេសដែលបង្ហាត់បានបទ (បា. អស្សាជានេយ្យ); ៤-គោអាជានេយ្យ គោឧសភដែលបរិបូណ៌ដោយលក្ខណៈល្អហើយគេបង្ហាត់បានបទ (បា. គោអាជានេយ្យ ឬ គវាជានេយ្យ) ។

បម្រើនោះ បាននាំសេះសិន្ធពនោះមកក្នុងខណៈនោះភ្លាម ។ រីឯបុណ្ណកយក្សសេនាបតី គាត់តែងខ្លួន កាត់កោរសក់និងពុកមាត់ស្រេចហើយ ក៏ឡើងជិះសេះដែលជាយាន ដូចជាពាហនៈនៃទេវតាឡើងជិះសេះនោះ បំផាយហោះកាត់តាមវេហាស៍ ឈមមុខឆ្ពោះទៅឯសម្នាក់របស់ស្តេចវេស្សវ័ណ ដល់ហើយ ក៏សរសើរពិភពនាគហើយក៏ក្រាបទូលពត៌មាននោះថ្វាយស្តេចវេស្សវ័ណទ្រង់ជ្រាប ។

បុណ្ណកយក្សនោះ ជាប់ជំពាក់ដោយកាមរាគៈ ប្រាថ្នានាងឥរន្ទតីជាបុត្រីក្រមុះរបស់នាគ បានទៅក្រាប ទូលព្រះបាទវេស្សវណកុវេរៈដ៏ទ្រង់យស ជាម្ចាស់ពួកយក្សនោះដូច្នេះថា ៖

"មន្ទីរឈ្មោះភោគវតី គេហៅ វាសៈ ព្រោះជាលំនៅនៃស្តេចនាគ គេហៅថា ហិរញ្ញវតី ព្រោះជាទីដែលបិទបាំងដោយកំពែងប្រាក់ ជានគរសម្រេចអំពីមាសដែលសាងសម្រេចដល់នាគ មានមណ្ឌលនៃក្អែន ។ ប៉មមានសណ្ឋានដូចកឱដ្ឋ ធ្វើអំពីកែវមណីក្រហម និងកែវមរកត ប្រាសាទក្នុងពិភពនាគធ្វើអំពីកែវមណីប្រក់ដោយរតនៈគឺមាស ។ ដើមឈើទាំងឡាយ គឺដើមស្វាយ ដើមទ្រមូច[៣៨] ដើមព្រីង ដើមសត្តបណ្ណ (ឈើមានសន្ទឹក៧) ដើមរាំងអន្ទក់ ដើមកេតក៏ ដើមបិយង្គុ ដើមរាជព្រឹក្ស ព្រមទាំងដើម

---

[៣៨] (ន.) ឈ្មោះឈើមួយប្រភេទ ផ្លែល្អិតៗ ស្រដៀងនឹងផ្លែដង្កៀបក្តាមប្រើធ្វើម្ជូរ ។

បារិច្ឆត្តព្រឹក្ស ដើមឈើទាលខ្សាច់ មកក្នុងពិភពនាគនោះ ។ ដើមចម្ប៉ា ដើមខ្នឹង ម្ទិះ នួនស្រី និងដើមក្របៅ មានក្នុងក្រុងពិភពនាគនោះ ដើមឈើទាំងនោះទន់ទោរល្អរុងរឿងក្នុងមន្ទីរនៃនាគ ។ ព្រះបាទវរុណៈ ជាឧបបាតិក[៣៩] កំណើតមានឫទ្ធិច្រើន នៅក្នុងពិភពនាគ ជាកន្លែងដែលមានដើមផ្ការជាច្រើន ដ៏ដេរដាសហើយដោយកែវមណី មានផ្កាជានិច្ចកាលជាវិការៈនៃមាស ។ នាងវិមលា ជាភរិយារបស់ព្រះបាទវរុណនាគនោះ ជាស្រីនៅក្មេង មានរាងកាយភ្លឺផ្លេកដូចមាស មានព្រះថនា (ដោះ) ដូចផ្លែស្ដៅគួរជាទីពិតពិល[៤០] រមិលមើល ដោយសេចក្ដីពេញចិត្ត ឬដូចត្រួយវល្លិ៍ប្រេងខ្លី ។ នាងវិមលាមានសម្បុរថ្ងៃក្រហមដូចពណ៌ល័ខ ដូច

[៣៩] (គុ.), (ន.) (បា.) (អ៊ុប៉ៈប៉ាតិកៈ) ដែលកើតឯង; សត្វដែលចាប់កំណើតឯង ៗ : កំណើតឧបបាតិក (ហៅ ឧបបាតិកជាតិ ឬ ឧបបាតិកកំណើត ក៏បាន) ។ ឧបបាតិកសត្ត ឬ ឱប-- សត្វដែលឧប្បត្តិកកើតឯង ដោយអំណាចកម្លាំងកុសលឬអកុសលបណ្ដាលឲ្យកើត (ឥតមាតាបិតា, ឥតមេឥតបា) : ទេវតាពួកខ្លះនិងសត្វនរកជាដើម ជាឧបបាតិកសត្ត ។

[៤០] ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ រមិលមើល ថា: គួរពិតពិលរមិលមើល ។ និយាយថា ពេចពិល ក៏មាន ។

ផ្កាកណិការ[៤១]រីកក្នុងទីមិនមានខ្យល់ ឬដូចស្រីអប្សរនៅក្នុងឋាន ត្រៃត្រិង្ស ឬក៏ដូចផ្ទេកបន្ទោរ[៤២] ដាលច្រវាត់ចេញអំពីស្រទាប់ ពពក ។ នាងវិមលានោះ ជាស្រី មានចំណង់ប្លែកអស្ចារ្យក្រៃលែង ចង់បានទូវបេះដូងនៃវិធុរបណ្ឌិត ។ បពិត្រព្រះអង្គជាឥស្សរៈ ទូលព្រះបង្គំនឹងទៅយកបេះដូងវិធុរបណ្ឌិតនោះ ឲ្យដល់នាគ ទាំងឡាយនោះ នាគទាំងនោះនឹងឲ្យនាងឥរន្ទតីដល់ទូលព្រះបង្គំ ដោយហេតុនោះ" ។

តាមសេចក្ដីដូចដែលបានពោលមកនេះ ស្ដេចវេស្សវ័ណមិនអនុញ្ញាត ឲ្យបុណ្ណកយក្សសេនាបតីនោះទៅឡើយ បុណ្ណកយក្សគេក៏មិនហ៊ាន ទៅ ហើយក៏បានធ្វើសេចក្ដីពណ៌នាជាច្រើននៅខាងលើនោះ ដើម្បីធ្វើ ឲ្យទ្រង់អនុញ្ញាត ។ ចំណែកស្ដេចវេស្សវ័ណ ទ្រង់ព្រះសណ្ដាប់សម្ដី របស់គេមិនឮទេ ។ ព្រោះហេតុអ្វី ? ពីព្រោះទ្រង់កំពុងតែកំណត់រឿងក្ដី វិមានរបស់ទេវបុត្រពីររូប ។ រីឯបុណ្ណកយក្សនោះ ដឹងថាទ្រង់ស្ដាប់សម្ដី របស់ខ្លួនពុំបាន ក៏បានឈរក្នុងសម្នាក់របស់ទេវបុត្រអ្នកឈ្នះក្ដី ។ ស្ដេច វេស្សវ័ណវិនិច្ឆ័យរឿងក្ដីហើយ ទ្រង់មិនអនុញ្ញាតឲ្យទេវបុត្រអ្នកចាញ់

---

[៤១] (ន.) (បា.) ឈ្មោះឈើផ្កាមួយប្រភេទមានផ្កា-ស សណ្ឋានប្រហែលនឹងផ្កាម្ទិះក្លិន ក្រអូប ។

[៤២] (ន.) ពន្លឺផ្ទេកដែលចេញជាខ្សែភ្លេត ៗ ឬដាលច្រវាត់ឯអាកាស ។

ក្រោកឡើងឡើយ ទ្រង់អនុញ្ញាតឲ្យទេវបុត្រអ្នកឈ្នះក្រោក ដោយពោលពាក្យថា "**គច្ឆ ត្វំ, តវ វិមានេ វសាហិ** ។ ប្រែថា ចូរអ្នកទៅចុះ ទៅនៅក្នុងវិមានរបស់អ្នកវិញចុះ" ។ ក្នុងខណៈដែលទ្រង់ពោលថា "**គច្ឆ ត្វំ** (ចូរអ្នកទៅចុះ)" បុណ្ណកយក្សសេនាបតីបានលេសឲ្យទេវបុត្រពីរបីរូបធ្វើជាសាក្សីថា "អ្នកទាំងឡាយ ចូរជួយចាំជួយដឹងឮថា ខ្ញុំនេះត្រូវឪពុកមារបស់ខ្ញុំបញ្ជូនឲ្យទៅហើយ" រួចបុណ្ណកៈនោះបង្គាប់ឲ្យគេទឹមសេះសិន្ធព[៤៣]តាមន័យដូចពោលហើយខាងលើ លោតឡើងជិះរួចបំផាយចៀសចេញទៅឰដ៏អាកាសវេហាស៍ ។

## បុណ្ណកយក្សភ្នាល់លេងល្បែងនឹងស្តេចធនញ្ជ័យ

កាលបុណ្ណកយក្សនោះ កំពុងតែធ្វើដំណើរតាមវេហាស៍ គេបានគិតឃើញថា "វិធុរបណ្ឌិត មានបរិវារច្រើន, អញមិនអាចចាប់គេបានទេ ក៏ប៉ុន្តែស្តេចធនញ្ជយកោរព្យរាជ ទ្រង់រក់នឹងល្បែង អញនឹងយកឈ្នះស្តេចនោះដោយល្បែង ហើយចាប់យកវិធុរបណ្ឌិត ប៉ុន្តែក្នុង

---

[៤៣] (ន.) (បា.),(សំ.) (សិន-ធប់) (សិន្ធវ; សៃន្ធវ អានថា សៃន-ធៈវៈ "ដែលជាប់ទាក់ទងដោយទន្លេសិន្ធុ") សេះដែលកើតក្នុងដែនសិន្ធវៈ, សេះដែលមានពូជពីដែនសិន្ធវៈ (សេះទេស) : សេះសិន្ធព; ប្រើសំដៅសេចក្ដីត្រឹមតែ "សេះ" ក៏មាន ។ សិន្ធពពាជី ឬ សិន្ធពអស្សតរ (--អ័ស-សៈដ) សេះសិន្ធព ។ សិន្ធពមនោម័យ (--មៈនោមៃ) សេះសិន្ធពដែលមានល្បឿនឆាប់ទាន់ចិត្ត ។ សិន្ធពអាជានេយ្យ (--នៃ) ឬ --អាជានៃយ៍ សេះសិន្ធពយ៉ាងលឿន ។

រាជវាំងនៃស្តេចនោះ មានរតនៈជាច្រើន ទ្រង់នឹងមិនលេងល្បែងដោយខ្នាច់[៤៤]ដែលមានតម្លៃតិចទេ, ការដែលអញយករតនៈដ៏មានតម្លៃថ្លៃទៅទើបគួរ, ព្រះរាជាដាក់ជាទ្រង់មិនយករតនៈដទៃទេ, នៅចន្លោះភ្នំវេបុល្លៈជុំវិញក្រុងរាជគ្រឹះ មានកែវមណីជារបស់ប្រើប្រាស់នៃស្តេចចក្រពត្តិសឹងមានអានុភាពខ្លាំងណាស់, អញនឹងយកកែវមណីនោះទៅប្រើប្រាស់ប្រលោមស្តេច ហើយគង់តែឈ្នះមិនខាន" ។ គិតដូច្នេះហើយបុណ្ណកយក្សនោះ បានទៅកាន់នគររាជគ្រឹះ ជាទីរីករាយដ៏ក្រៃលែងជាក្រុងរបស់ព្រះបាទអង្គរាជ ដែលសត្រូវចូលមកបានដោយក្រ ជាក្រុងមានភក្សាហារ[៤៥]ច្រើន មានបាយទឹកច្រើន ដូចជាភពឈ្មោះមសក្កសារៈរបស់វាសវៈ ។ នគរនោះ គឹកកង់ដោយហ្វូងក្ងោកនិងក្រៀល គឹកកង់ដោយសត្វស្វាប ដែលពួកសត្វស្វាបអាស្រ័យនៅ មានសូរសំឡេងនៃពួកបក្សីផ្សេង ៗ មានព្រះលានដ៏ល្អ ដេរដាសដោយផ្កាដូចជាភ្នំហិមវន្ត ។ បុណ្ណកយក្សនោះឡើងទៅកាន់ភ្នំឈ្មោះវេបុល្លៈជាទី

---

[៤៤] (ន.) កំណាច់ឈើ ឬ ឫស្សី ផ្ដៅ ដែលកាច់មិនឲ្យដាច់ពីគ្នា ទុកចំណាំចំនួនដែលរាប់ : មួយខ្នាច់, ពីរខ្នាច់ ។

[៤៥] (ន.) (សំ.),(បា.) (ភ័ក-សាហា) (< ភក្ស + អាហារ; ភក្ខ--) ចំណីអាហារ ឬអាហារជាចំណី : ពួកម្រឹគបក្សីចេញស្វែងរកភក្សាហារ ។

អាស្រ័យនៅនៃពួកកិន្នរ[៤៦] ហើយស្វែងរកនូវកែវមណីដ៏ប្រសើរ ហើយបានឃើញកែវមណីនោះ ត្រង់កណ្ដាលកំពូលភ្នំ ។ បុណ្ណកយក្សឃើញកែវមណីមានជាតិផ្សេង ៗ ជាទីផ្សាយចេញនៃរស្មីរុងរឿង ជាកែវមណីដ៏ប្រសើរ អាចនាំមកនូវទ្រព្យ ជាកែវរុងរឿង ជាកែវកំពូលនៃយស ភ្លឺរុងរឿងដូចផ្កេកបន្ទោរឰដ៏អាកាស ក៏បានកាន់យកកែវមណី ឈ្មោះ **មនោហរៈ**នោះ ជាកែវពៃទូរ្យ[៤៧] មានតម្លៃច្រើន មានអានុភាពច្រើន ជាអ្នកមានភេទជាមនុស្សឡើងជិះសេះអាជានេយ្យ ហោះទៅឰដ៏អាកាសវេហាស៍ ។ បុណ្ណកយក្ស កាន់កែវមណីនោះហោះតាមអាកាស បានទៅដល់ក្រុងឥន្ទបត្ត ហើយចុះអំពីសេះ ក៏ចូលឆ្ពោះទៅទីប្រជុំនៃអ្នកដែនកុរុ ដោយមិនកោតញញើតចំពោះព្រះរាជា ១០១ អង្គ ដែលមកប្រជុំព្រមគ្នានៅក្នុងទីនោះ បបួលថា ៖

"បណ្ដាព្រះរាជាក្នុងរាជសមាគមនេះ ព្រះរាជាអង្គណាឈ្នះយើង សូមយកកែវដ៏ប្រសើររបស់យើងចុះ តែបើយើងឈ្នះព្រះរាជាអង្គណាវិញ យើងត្រូវយកទ្រព្យដ៏ប្រសើរ ឬយកកែវដ៏ប្រសើរថ្លៃថ្លាក៏បាន ចំណែកព្រះរាជាអង្គណាឈ្នះយើងវិញ នឹងយកទ្រព្យដ៏

[៤៦] (ន.) (សំ.),(បា.) (កិន-ណរៈ- ឬ កិ-ណរ) ឈ្មោះបក្សីមួយប្រភេទ ថាមានរូបដូចមនុស្ស មានស្លាបហើរបាន មាននិយាយតែក្នុងរឿងបុរាណ; ដែលហៅថា កេនរ ឬកែណរ នេះជាពាក្យក្លាយមកពីពាក្យថា កិន្នរ នេះឯង ។ ឥត្ថី. កិន្នរី ។

[៤៧] (ន.) (សំ.),(បា.) (-ទូ) (វៃទូយ៌; វេឡុរិយ) ពេជ្រភ្នែកឆ្មា : កែវពិទូរ្យ,ត្បូងពិទូរ្យ ។

ប្រសើរក៏បាន" ។

គ្រានោះ ព្រះរាជាទ្រង់ព្រះតម្រិះថា "មនុស្សដែលក្លាហានពោលយ៉ាងនេះ គឺអញមិនដែលធ្លាប់បានឃើញពីមុនមកសោះ តើគេជានរណា ?" រួចទ្រង់ត្រាស់សួរថា ៖

"កុហឹ នុ រដ្ឋេ តវ ជាតិភូមិ,
ន កោរព្យស្សេវ វចោ តវេទំ;
អភីតោសិ នោ វណ្ណនិភាយ សព្ពេ,
អក្ខាហិ មេ នាមញ្ច ពន្ធវេ ច" ។

"ជាតិភូមិរបស់អ្នកនៅក្នុងដែនណា ? វាចារបស់អ្នកនេះ មិនមែនជាវាចារបស់អ្នកដែនកុរុទេ អ្នកមានវាចាអង់អាច មិនកោតខ្លាចយើងទាំងអស់គ្នាសោះ អ្នកចូរប្រាប់ឈ្មោះនិងផៅពង្សដល់យើងមកមើល" ។

ឮដូច្នោះ បុណ្ណកៈគិតថា "ព្រះរាជាអង្គនេះ សួរឈ្មោះរបស់អញ, ចំណែកឈ្មោះរបស់អញប្រែមកថាជាទាសៈ ។ ប្រសិនបើអញប្រាប់ថាអញឈ្មោះបុណ្ណកៈ នុ៎ះគឺជាទាសៈពិត ដូច្នោះ ស្ដេចនឹងមើលងាយអញថាអាទាសៈ វានិយាយយ៉ាងនេះ ព្រោះវាឡប់ធ្លួត ហេតុដូច្នេះ អញនឹងប្រាប់ឈ្មោះក្នុងជាតិមុនបន្ទាប់ពីជាតិនេះដល់ព្រះអង្គវិញ" គិតដូច្នេះហើយ បុណ្ណកយក្សប្រាប់ថា ៖

"កច្ចាយនោ មាណវកោស្មិ រាជ,
អនូនណាមោ ឥតិ មវ្ហយន្តិ;
អង្គេសុ មេ ញាតយោ ពន្ធវា ច,
អក្ខេន ទេវស្មិ ឥធានុបត្តោ" ។

"បពិត្រព្រះរាជា ទូលព្រះបង្គំជាមាណពកច្ចាយនគោត្រ ក្នុងកាលចម្បាកនគរនៃដែនអង្គៈ ពួកញាតិនិងផៅពង្សរបស់ទូលព្រះបង្គំតែងហៅទូលព្រះបង្គំថា មាណព ជាអ្នកមានឈ្មោះមិនថោកទាប បពិត្រព្រះសម្មតិទេព បំណងរបស់ទូលព្រះបង្គំមកក្នុងទីនេះ ដើម្បីលេងល្បែងភ្នាល់ក្រាបទូល" ។

គ្រានោះ ព្រះរាជាត្រាស់សួរថា ៖

"នែ៎មាណព ចុះបើអ្នកចាញ់ល្បែងយើង អ្នកនឹងឲ្យអ្វីដល់យើង ? តើអ្នកមានអ្វី ?"

រួចទ្រង់បន្តពោលថា ៖

"កិំ មាណវស្ស រតនានិ អត្ថិ, យេ តំ ជិនន្តោ ហរេ អក្ខធុត្តោ;
ពហូនិ រញ្ញោ រតនានិ អត្ថិ, តេ ត្វំ ទលិទ្ទោ កថមវ្ហយេសិ" ។

"អ្នកឯងពោលថាបើខាងយើងលេងល្បែងភ្នាល់ឈ្នះ អ្នកនឹងឲ្យ

*កែវមណីដល់យើង តើអ្នកបានកែវមណីនោះមកពីណា កាលបើយើងមើលទៅអ្នកមានសភាពជាមនុស្សទាល់ក្រយ៉ាងនេះ តើអ្នកមានកែវមណីដែរឬ ? ចំណែកឯកែវរបស់ព្រះរាជា មានចំនួនច្រើន អ្នកជាមនុស្សទាល់ក្រ នឹងបបួលព្រះរាជាទាំងនោះដូចម្ដេចបាន ?"*

*គ្រានោះ បុណ្ណកៈឆ្លើយថា ៖*

"មនោហរោ នាម មណី មមាយំ,
មនោហរំ មណិរតនំ ឧឡារំ;
ឥមញ្ច អាជញ្ញមមិត្តតាបនំ,
ឯតំ មេ ជិនិត្វា ហរេ អក្ខធុត្តោ" ។

*"កែវមណីរបស់ទូលព្រះបង្គំនេះអាចនាំមកនូវទ្រព្យបាន បើព្រះអង្គលេងល្បែងភ្នាល់ឈ្នះទូលព្រះបង្គំហើយ គប្បីយកកែវមណីដ៏ប្រសើរ ជាកែវអាចនាំមកនូវទ្រព្យនេះ ១ និងសេះអាជានេយ្យអាចបង្ក្រាបសត្រូវនេះ ១ របស់ទូលព្រះបង្គំចុះ" ។*

*ទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះរាជាត្រាស់ថា ៖*

"ឯកោ មណី មាណវ កឹ ករិស្សតិ,
អាជានិយេកោ បន កឹ ករិស្សតិ;

ពហូនិ រញ្ញោ មណិរតនានិ អត្ថិ,
អាជានិយា វាតជវា អនប្បកា" ។

"ម្នាលមាណព កែវមណីមួយ ទាំងសេះអាជានេយ្យមួយប៉ុណ្ណឹង នឹងធ្វើអ្វីបាន ព្រោះកែវរបស់ព្រះរាជាទាំងឡាយមានចំនួនច្រើន សេះអាជានេយ្យរបស់ព្រះរាជា មានសន្ទុះលឿនដូចខ្យល់ក៏មានចំនួនមិនតិចដែរ" ។

ទោហឡកណ្ឌ ចប់ ។

## **អានុភាពចិត្តនិងរូបនិម្មិតក្នុងកែវមណី**

*បុណ្ណកៈ ឮព្រះរាជតម្រាស់ហើយ បាននិយាយតបថា "បពិត្រមហារាជ ព្រះអង្គត្រាស់ពាក្យនោះដូចម្ដេច? សេះអាជានេយ្យរបស់ទូលព្រះបង្គំ ១ ប្រសើរជាងសេះ ១.០០០ កែវមណីរបស់ទូលព្រះបង្គំ ១ ប្រសើរជាងកែវមណី ១.០០០ ។ មិនមែនសេះទាំងអស់ប្រាកដជាងសេះ ១ នេះទេ សូមព្រះអង្គទតសន្ទុះនៃសេះនេះជាមុន" ថាដូច្នេះហើយ បុណ្ណកៈឡើងជិះសេះ បំផាយទៅតាមចុងកំពែង ។ នគរដែលមានទំហំ ៧ យោជន៍ ហាក់ដូចជាមានសេះនៅជុំជិតចង្អៀតកគ្នា ។ គ្រានោះសូម្បីសេះក៏មិនប្រាកដតាមលំដាប់ យក្សក៏មិនប្រាកដ មើលទៅដូចជាផ្ទាំងបដាពណ៌ក្រហមចងត្រង់ពោះតែប៉ុណ្ណោះ ។ បុណ្ណកៈចុះអំពីសេះពិតទូលថា ៖*

*"បពិត្រមហារាជ ទ្រង់ទតឃើញហើយឬ សន្ទុះសេះទូលបង្គំ?"*

*"អើ យើងឃើញហើយ" ស្ដេចតប ។*

*"ឥឡូវ សូមព្រះអង្គទតម្ដងទៀត មហារាជ" បុណ្ណកៈពោល ។*

*និយាយដូច្នេះហើយ បុណ្ណកៈបំផាយសេះឲ្យរត់លើទឹកស្រះបោក្ខរណីក្នុងឧទ្យានខាងក្នុងនគរពុំបានឲ្យសើមចុងក្រចកសេះ សូម្បីតែបន្តិច ។ បន្ទាប់មក បុណ្ណកៈបំផាយសេះឲ្យរត់លេងលើស្លឹកឈូក*

ទាំងឡាយ ទះដៃផ្ទង់ លាដៃមួយសន្ទុះ ស្រាប់តែសេះមកឋិតនៅលើបាតដៃ ។ គ្រានោះ គេនិយាយថា "គួរហើយឬ សេះកែវបែបនេះព្រះនរិន្ទ[៤៨] ?"

"គួរហើយ" ស្តេចតប ។

"បពិត្រមហារាជ សេះកែវសូមឈប់ត្រឹមប៉ុណ្ណឹងចុះ ឥឡូវសូមព្រះអង្គទត នូវអានុភាពដ៏ខ្លាំងនៃកែវមណីម្តង" ។

ថាដូច្នេះហើយ បុណ្ណកៈប្រកាសនូវអានុភាពកែវមណីដូច្នេះ ៖

"ឥទញ្ច មេ មណិរតនំ, បស្ស ត្វំ ទ្វិបទុត្តម;
ឥត្ថីនំ វិគ្គហា ចេត្ថ, បុរិសានញ្ច វិគ្គហា ។
មិគានំ វិគ្គហា ចេត្ថ, សកុណានញ្ច វិគ្គហា;
នាគរាជា សុបណ្ណា ច, មណិម្ហិ បស្ស និម្មិតំ" ។

"បពិត្រព្រះអង្គប្រសើរជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ទតកែវមណីរបស់ទូលព្រះបង្គំនេះចុះ ក្នុងកែវមណីនេះ មានរាងកាយរបស់ស្ត្រី មានរាងកាយរបស់បុរស មានរាងកាយរបស់ម្រឹគ

[៤៨] (ន.) (បា.),(សំ.) (នៈរិន) (នរេន្ទ្រ) អ្នកដែលជាធំលើអស់ជន, ដែលជាម្ចាស់នៃមនុស្ស (ក្សត្រទ្រង់រាជ្យ) ។

*មានរាងកាយរបស់បក្សី ប្រាកដក្នុងកែវមណី សូមព្រះអង្គទ្រង់ទតនាគរាជ និងគ្រុឌ ជារូបនិម្មិតក្នុងកែវមណីនេះ" ។*

*បុណ្ណកសូមឲ្យព្រះរាជាទ្រង់ទតមើលរបស់ផ្សេង ៗ ទៀត រួចបង្ហាញទ្រង់ថា ៖*

"ហត្ថានីកំ រថានីកំ, អស្សេ បត្តី ច វម្មិនេ;
ចតុរង្គិនិមំ សេនំ, មណិម្ហិ បស្ស និម្មិតំ។
ហត្ថារោហេ អនីកដ្ឋេ, រថិកេ បត្តិការកេ;
ពលគ្គានិ វិយូឡ្ហានិ, មណិម្ហិ បស្ស និម្មិតំ" ។

*"សូមព្រះអង្គទ្រង់ទតនូវសេនាមាន ៤ ប្រភេទគឺ ពលដំរី ១ ពលរថ ១ ពលសេះ ១ ពលថ្មើរជើងមានគ្រឿងក្រោះ ១ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពលដំរីនិងពលសេនា ពលរថ និងពលថ្មើរជើង គឺពួកពលដែលរៀបជាព្យុហៈ ជារូបនិម្មិតក្នុងកែវមណី ។*

"បុរំ ឧទ្ធាបសម្បន្នំ, ពហុបាការតោរណំ;
សិង្ឃាដកេ សុភូមិយោ, មណិម្ហិ បស្ស និម្មិតំ។
ឯសិកា បរិខាយោ ច, បលិខំ អគ្គឡានិ ច;
អដ្ដាលកេ ច ទ្វារេ ច, មណិម្ហិ បស្ស និម្មិតំ" ។

សូមព្រះអង្គទ្រង់ទត នគរដ៏បរិបូណ៌ដោយប៉ម មានកំពែងនិង
ខ្លោងទ្វារដ៏ច្រើនជាន់ មានផ្លូវបែកជា ៤ និងផែនដីដ៏ល្អ ជារូប
និម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត សសរខឿនគូ រនុក
ទ្វារ គន្លឹះទ្វារ ប៉ម និងទ្វារប៉ម ជារូបនិម្មិតក្នុងកែវមណី ។

"បស្ស តោរណមគ្គេសុ, នានាទិជគណា ពហូ;
ហំសា កោញ្ចា មយូរា ច, ចក្កវាកា ច កុក្កុហា ។
កុណាលកា ពហូ ចិត្រា, សិខណ្ឌី ជីវជីវកា;
នានាទិជគណាកិណ្ណំ, មណិម្ហិ បស្ស និម្មិតំ" ។

សូមព្រះអង្គទ្រង់ទតពួកបក្សីផ្សេង ៗ ជាច្រើន ទៀបខ្លោងទ្វារនិង
ផ្លូវ គឺហ្វូងហង្ស ក្រៀល ក្ងោក ចាក្រពាក អក សូមព្រះអង្គទ្រង់
ទតទីក្រុង ដ៏ដេរដាសដោយបក្សីផ្សេង ៗ  គឺតាវៅខ្មៅ តាវៅ
ពព្រុស ក្ងោក និងប៉ោលតោកជាច្រើន ជារូបនិម្មិតក្នុងកែវមណី ។

"បស្ស នគរំ សុចាការំ, អព្ភុតំ លោមហំសនំ;
សមុស្សិតធជំ រម្មំ, សោណ្ណវាលុកសន្ថតំ ។
បស្សេត្ថ បណ្ណសាលាយោ, វិភត្តា ភាគសោ មិតា;
និវេសនេ និវេសេ ច, សន្ធិព្យូហេ បថទ្ធិយោ" ។

សូមព្រះអង្គទ្រង់ទត ទីក្រុងមានកំពែងល្អអស្ចារ្យចម្លែកគួរព្រឺ
រោម មានទង់ជ័យលើកឡើង ក្រាលដោយដីខ្សាច់ដែលមាន

*សម្បុរដូចមាស គួរជាទីរីករាយ ។ សូមព្រះអង្គទ្រង់ទតពានផ្សារ ដ៏បរិបូណ៌ដោយទំនិញ ដែលគេចែកជាជួរ ជាសង្កាត់ តាមចំណែក មានផ្ទះនិងទីផ្ទះ តំណនៃផ្ទះ ច្រកទាល់ និងផ្លូវទាំងឡាយ ។*

"ចានាគារេ ច សោណ្ឌេ ច, សូនា ឱទនិយា ឃរា;
វេសី ច គណិកាយោ ច, មណិម្ហិ បស្ស និម្មិតំ។
មាលាការេ ច រជកេ, គន្ធិកេ អថ ទុស្សិកេ;
សុវណ្ណការេ មណិការេ, មណិម្ហិ បស្ស និម្មិតំ។
អាឡារិកេ ច សូទេ ច, នដនាដកគាយិនោ;
បាណិស្សរេ កុម្ភថូនិកេ, មណិម្ហិ បស្ស និម្មិតំ" ។

*សូមព្រះអង្គទ្រង់ទត រោងសុរា អ្នកសេពសុរា អ្នកគ្រួ[៤៩] ផ្ទះបាយ ពួកឈ្មួញ និងពួកស្រីពេស្យា ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គ ទ្រង់ទត ពួកជនអ្នកធ្វើផ្កាកម្រង ជាងជ្រលក់ អ្នកធ្វើគ្រឿងក្រអូប អ្នកត្បាញសំពត់ ជាងមាស និងជាងកែវមណី ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកជនអ្នកធ្វើសម្ល ជនធ្វើបាយ អ្នករបាំ នាយរបាំ អ្នកច្រៀង អ្នកច្រៀងទះដៃ និងអ្នកវាយស្គរ ជារូបនិម្មិតក្នុងកែវមណី ។*

---

[៤៩] (កិ) *អ្នកចម្អិនបាយ*

“បស្ស ភេរី មុទិង្គា ច, សង្ខា បណវទិន្ទិមា;
សព្វញ្ច តាឡាវចរំ, មណិម្ហិ បស្ស និម្មិតំ ។
សម្មតាលញ្ច វីណញ្ច, នច្ចគីតំ សុវាទិតំ;
តូរិយតាឡិតសង្ឃុដ្ឋំ, មណិម្ហិ បស្ស និម្មិតំ ។
លង្ឃិកា មុដ្ឋិកា ចេត្ថ, មាយាការា ច សោភិយា;
វេតាលិកេ ច ជល្លេ ច, មណិម្ហិ បស្ស និម្មិតំ” ។

*សូមព្រះអង្គទ្រង់ទត ស្គរ សម្ភោរ សង្ខ ខ្លុយ ស្គរជ័យ និង គ្រឿងភ្លេងទាំងអស់ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ក្រាប់ ឈិង ពិណ របាំ ចម្រៀង ប្រគំ ដែលគឹកកងដោយតូរ្យតន្ត្រី ដ៏រងំ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកជនអ្នកលោត អ្នកប្រដាល់ អ្នកធ្វើខាងកលមាយា និងស្រីប្រុសដ៏ល្អ ក្នុងកែវមណីនេះ ទាំងពួកជនអ្នកដាស់តឿនគេ និងអ្នកកាត់កោរសក់ ជារូបនិម្មិតក្នុងកែវមណី ។*

“សមជ្ជា ចេត្ថ វត្តន្តិ, អាកិណ្ណា នរនារិភិ;
មញ្ចាតិមញ្ចេ ភូមិយោ, មណិម្ហិ បស្ស និម្មិតំ” ។

*មហោស្រពទាំងឡាយដ៏មីរដេរដាសដោយបុរសនិងស្ត្រី ក៏មានក្នុងកែវមណីនេះ សូមព្រះអង្គទ្រង់ទត គ្រែតូចនិងគ្រែធំ និងទីនៃមហោស្រព ជារូបនិម្មិតក្នុងកែវមណី ។*

“បស្ស មល្លេ សមជ្ជស្មិំ, ជោដេន្តេ ធិតុណំ កុជំ;
និហតេ និហតមានេ ច, មណិម្ហិ បស្ស និម្មិតំ” ។

*សូមព្រះអង្គទ្រង់ទតពួកអ្នកចំបាច់ ដែលច្របាច់គ្នាដោយដៃទាំងពីរ ក្នុងទីមហោស្រព សូមព្រះអង្គទ្រង់ទត ពួកអ្នកឈ្នះនិងអ្នកចាញ់ ជារូបនិម្មិតក្នុងកែវមណី ។*

“បស្ស បព្វតបាទេសុ, នានាមិគគណា ពហូ;
សីហា ព្យគ្ឃា វរាហា ច, អច្ឆកោកតរច្ឆយោ ។
បលាសាទា គវជា ច, មហឹសា រោហិតា រុរូ;
ឯណេយ្យា ច វរាហា ច, គណិនោ នីកសូករា ។
កទលិមិគា ពហូ ចិត្រា, ពិឡារា សសកណ្ណកា;
នានាមិគគណាកិណ្ណំ, មណិម្ហិ បស្ស និម្មិតំ” ។

*សូមព្រះអង្គទ្រង់ទត ពួកម្រឹគផ្សេង ៗ ជាច្រើនទៀបជើងភ្នំ គឺរាជសីហ៍ ខ្លាធំ ជ្រូកព្រៃ ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន សត្វរមាស គោក្របី រមាំង ប្រើស ទ្រាយ សរកម្រឹគ ក្តាន់ ជ្រូកស្រុក ឈ្លូស ពួកមិត្រ ម្រឹគជាច្រើន ខ្លាត្រី ទន្សាយ និងកង្កែន សូមព្រះអង្គទ្រង់ទតជើងភ្នំដ៏ដេរដាសដោយពួកម្រឹគផ្សេង ៗ ជារូបនិម្មិតក្នុងកែវមណី ។*

“នជ្ជាយោ សុប្បតិត្ថាយោ, សោណ្ណវាលុកសន្ថតា;

អច្ឆា សវន្តិ អម្ពូនិ, មច្ឆគុម្ពនិសេវិតា ។
កុម្ភីលា មករា ចេត្ថ, សុសុមារា ច កច្ឆបា;
ចាបីនា ចាវុសា មច្ឆា, ពលជា មុញ្ជរោហិតា” ។

*ស្ទឹងទាំងឡាយ មានកំពង់រាបទាបល្អ ដែលក្រាលដោយខ្សាច់មាស មានទឹកថ្លា មានពួកត្រីអាស្រ័យ តែងហូរទៅ ។ ពួកធ្លាម មករ ក្រពើ អណ្តើក ត្រីស្វាត ត្រីសណ្តាយ ត្រីឆ្តោ ត្រីឆ្ពិនមានក្នុងកែវមណីនេះ ។*

“នានាទិជគណាកិណ្ណា, នានាទុមគណាយុតា;
វេឡុរិយករោទាយោ, មណិម្ហិ បស្ស និម្មិតំ” ។

*សូមព្រះអង្គទ្រង់ទត ស្រះបោក្ខរណីដែលធ្វើដោយផែនថ្ម ជាវិការៈនៃកែវពៃទូរ្យ ដ៏ដេរដាសដោយពួកសត្វស្លាបផ្សេង ៗ មានពួកឈើផ្សេង ៗ ជាជួរ ជារូបនិម្មិតក្នុងកែវមណី ។*

“បស្សេត្ថ បោក្ខរណិយោ, សុវិភត្តា ចតុទ្ទិសា;
នានាទិជគណាកិណ្ណា, បុថុលោមនិសេវិតា ។
សមន្តោទកសម្បន្នំ, មហិំ សាគរកុណ្ឌលំ;
ឧបេតំ វនរាជេហិ, មណិម្ហិ បស្ស និម្មិតំ” ។

*សូមព្រះអង្គទ្រង់ទតស្រះបោក្ខរណីក្នុងកែវមណីនេះ ដែលចាត់ចែងដោយល្អទាំង ៤ ទិស ដ៏ដេរដាសដោយពួកសត្វស្លាបផ្សេង ៗ ដែលត្រីធំអាស្រ័យនៅ សូមព្រះអង្គទត ផែនដីដ៏បរិបូណ៌ដោយទឹកពទ្ធជុំវិញ ជាកុណ្ឌលនៃសាគរ ប្រកបដោយជួរដង់ព្រៃទាំងឡាយ ជារូបនិម្មិតក្នុងកែវមណី ។*

"បុរតោ វិទេហេ បស្ស, គោយានិយេ ច បច្ឆតោ;
កុរុយោ ជម្ពុទីបញ្ច, មណិម្ហិ បស្ស និម្មិតំ។

*សូមព្រះអង្គទ្រង់ទតមើលទ្វីបទាំង ៤ គឺបុព្វវិទេហទ្វីប ខាងកើត អបរគោយានទ្វីប ខាងលិច ឧត្តរកុរុទ្វីប និងជម្ពូទ្វីប ជារូបនិម្មិតក្នុងកែវមណី ។*

"បស្ស ចន្ទំ សូរិយញ្ច, ឱភាសន្តេ ចតុទ្ទិសា;
សិនេរុំ អនុបរិយន្តេ, មណិម្ហិ បស្ស និម្មិតំ ។

*សូមព្រះអង្គទ្រង់ទត ព្រះចន្ទនិងព្រះអាទិត្យ កំពុងបំភ្លឺទិសទាំង ៤ សូមព្រះអង្គទ្រង់ទត ព្រះចន្ទនិងព្រះអាទិត្យនោះ កំពុងដើរក្រឡឹង ភ្នំសិនេរុ ជារូបនិម្មិតក្នុងកែវមណី ។*

"សិនេរុំ ហិមវន្តញ្ច, សាគរញ្ច មហីតលំ;
ចត្តារោ ច មហារាជេ, មណិម្ហិ បស្ស និម្មិតំ។

*សូមព្រះអង្គទ្រង់ទត ភ្នំសិនេរុ ភ្នំហិមពាន្ត សមុទ្ទសាគរដែលមាន ឫទ្ធិច្រើន និងមហារាជទាំង ៤ អង្គ ជារូបនិម្មិតក្នុងកែវមណី ។*

"អាកាសេ វ នក្ខត្តេ ច, ចាតុទិសេ ច សិលុច្ចយេ;
រម្មេ កិម្បុរិសាកិណ្ណេ, មណិម្ហិ បស្ស និម្មិតំ។

*សូមព្រះអង្គទ្រង់ទតសួនច្បារ ព្រៃ គុម្ពឈើ ខ្ទង់ថ្មភ្នំ ហាក់ដូច ជាក្រាលតម្កល់ទុក ដ៏ដេរដាសដោយ ពួកកិន្នរ គួរជាទីរីករាយ ជារូបនិម្មិត ក្នុងកែវមណី ។*

"ផារុសកំ ចិត្តលតំ, មិស្សកំ នន្ទនំ វនំ;
វេជយន្តញ្ច បាសាទំ, មណិម្ហិ បស្ស និម្មិតំ ។

*សូមព្រះអង្គទ្រង់ទត បារុសកវ័ន ចិត្តលតាវ័ន មិស្សកវ័ន នន្ទនវ័ន និងវេជយន្តប្រាសាទ ជារូបនិម្មិត ក្នុងកែវមណី ។*

"សុធម្មំ តាវតិំសញ្ច, ចារិជត្តញ្ច បុប្ផិតំ;
ឯរាវណំ នាគរាជំ, មណិម្ហិ បស្ស និម្មិតំ។

*សូមព្រះអង្គទ្រង់ទត សុធម្មសភា ឋានតាវត្តិង្ស ដើមបារិច្ឆត្រព្រឹក្ស មានផ្ការីក ស្តេចដំរីឈ្មោះឯរាវ័ណ ជារូបនិម្មិត ក្នុងកែវមណី ។*

"បស្សេត្ថ ទេវកញ្ញាយោ, នភា វិជ្ជុរិវុគ្គតា;
នន្ទនេ វិចរន្តិយោ, មណិម្ហិ បស្ស និម្មិតំ។

*សូមព្រះអង្គទ្រង់ទតពួកស្រីទេពកញ្ញា ដែលភ្លឺផ្ទេកដូចជាផ្ទេកបន្ទោរចេញចាកពពក កំពុងត្រាច់ទៅក្នុងនន្ទនវ័ន ជារូបនិម្មិតក្នុងកែវមណី ។*

“បស្សេត្ថ ទេវកញ្ញាយោ, ទេវបុត្តបលោភិនី;
ទេវបុត្តេ រមមានេ, មណិម្ហិ បស្ស និម្មិតំ” ។

*សូមព្រះអង្គទ្រង់ទត ពួកទេពកញ្ញាប្រលោមទេវបុត្រ និងពួកទេវបុត្រកំពុងរីករាយក្នុងនន្ទនវ័ន ជារូបនិម្មិត ក្នុងកែវមណី ។*

“បរោសហស្សបាសាទេ, វេឡុរិយផលសន្ថតេ;
បជ្ជលន្តេ ច វណ្ណេន, មណិម្ហិ បស្ស និម្មិតំ ។

*សូមព្រះអង្គទ្រង់ទតប្រាសាទច្រើនជាងពាន់ ដែលក្រាលដោយផែនក្តារកែវពៃទូរ្យមានសម្បុររុងរឿង ជារូបនិម្មិតក្នុងកែវមណី ។*

“តាវតិំសេ ច យាមេ ច, តុសិតេ ចាបិ និម្មិតេ;
បរនិម្មិតវសវត្តិនោ, មណិម្ហិ បស្ស និម្មិតំ ។

*សូមព្រះអង្គទ្រង់ទត ឋានតាវត្តិង្ស យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី ជារូបនិម្មិតក្នុងកែវមណី ។*

“បស្សេត្ថ បោក្ខរណិយោ, វិប្បសន្នោទិកា សុចី;
មន្ទាលកេហិ សញ្ឆន្នា, បទុមុប្បលកេហិ ច” ។

*សូមព្រះអង្គទ្រង់ទត ស្រះបោក្ខរណីក្នុងជាន់នោះ ៗ មានទឹកថ្លាស្អាត ដ៏ដេរដាសដោយផ្កាចង្កុលណី ផ្កាឈូក និងផ្កាឧប្បល ក្នុងឋានសួគ៌នុ៎ះ ។*

"ទសេត្ថ រាជិយោ សេតា, ទស នីលា មនោរមា;
ឆ បិង្គលា បន្នរស, ហលិទ្ទា ច ចតុទ្ទស ។
វីសតិ តត្ថ សោវណ្ណា, វីសតិ រជតាមយា;
ឥន្ទគោបកវណ្ណាភា, តាវ ទិស្សន្តិ តឹសតិ ។
ទសេត្ថ កាឡិយោ ឆច្ច, មញ្ជេដ្ឋា បន្នវីសតិ;
មិស្សា ពន្ធុកបុប្ផេហិ, នីលុប្បលវិចិត្តិកា ។
ឯវំ សព្ពង្គសម្បន្នំ, អច្ចិមន្តំ បភស្សរំ;
ឱធិសុង្កំ មហារាជ, បស្ស ត្វំ ទ្វិបទុត្តម" ។

*ក្នុងកែវមណីនេះ មានឆ្នូតស ១០ ឆ្នូតក្រហម ៦ និង ១៥ (ជា ៣១) ឆ្នូតលឿង ១៤ គួរជាទីរមិលមើល ជាទីរីករាយនៃចិត្ត ។ ឆ្នូតមាស ២០ ឆ្នូតប្រាក់ ២០ ឆ្នូតមានពន្លឺដូចជាពណ៌នៃអណ្តើកមាស ៣០ ប្រាកដនៅក្នុងកែវមណីនេះ ។ ឆ្នូតខ្មៅ ១៦ ឆ្នូតហង្សបាទ ២៥ ឆ្នូតលាយដោយផ្កាច្បា[៥០] វិចិត្រដោយផ្កាឧប្បលខៀវ មានក្នុងកែវមណីនេះ ។ បពិត្រមហារាជប្រសើរជាងសត្វជើងពីរ សូមព្រះ*

[៥០] (ន.) (សំ.),(បា.) (ជបា "កុលាបច្បា") *ឈ្មោះឈើផ្កាមួយប្រភេទ ផ្កាឥតក្លិន ។*

អង្គទ្រង់ទតកែវមណីមានរស្មីជាទីផ្សាយចេញនៃពន្លឺ ដ៏ប្រកប
ដោយអង្គទាំងពួងយ៉ាងនេះ ព្រះរាជាអង្គណាលេងភ្នាល់ឈ្នះ
ទូលព្រះបង្គំ ចំណែកនៃសួយ ចូរបានទៅព្រះរាជាអង្គនោះចុះ" ។

មណិកណ្ឌ ចប់ ។

## ស្តេចលេងល្បែងចាញ់បុណ្ណកៈ

លុះពោលយ៉ាងនេះហើយ បុណ្ណកៈបានក្រាបទូលស្តេចថា ៖

"បពិត្រមហារាជ កាលបើទូលបង្គំចាញ់ល្បែង ទូលបង្គំនឹងថ្វាយកែវមណីនេះដល់ព្រះអង្គ ចុះព្រះអង្គនឹងឲ្យអ្វីដល់ទូលបង្គំ ?"

"នែអ្នក លើកលែងតែខ្លួនយើង ព្រះទេវី និងព្រះមហាស្វេតច្ឆត្រចេញ ក្រៅពីនេះសុទ្ធតែជាសួយផ្ទាល់ខ្លួនយើង" ស្តេចត្រាស់ ។

"បពិត្រព្រះសម្មតិទេព បើអ៊ីចឹង កុំទ្រង់យឺតយូរឡើយ ទូលបង្គំមកពីឆ្ងាយផង សូមទ្រង់ឲ្យគេចាត់ចែងរោងល្បែងឲ្យឆាប់ទៅ" បុណ្ណកៈពោល ។

ព្រះរាជាបានបង្គាប់អាមាត្យទាំងឡាយ ។ ពួកគេបានចាត់ចែងរោងល្បែងយ៉ាងរហ័ស ក្រាលកម្រាលសំពត់ដ៏ល្អបម្រុងព្រះរាជារៀបចំរាជាសនៈទាំងឡាយ បម្រុងព្រះរាជាទាំងឡាយផ្សេង ៗ ផងនិងរៀបចំអាសនៈដ៏សមគួរដល់បុណ្ណកៈផង រួចរាល់ហើយ ពួកគេបានទៅក្រាបទូលនូវកាលដល់ព្រះមហាក្សត្រ ។ គ្រានោះ បុណ្ណកៈក្រាបទូលព្រះរាជាថា ៖

"ឧចាគតំ រាជ មុបេហិ លក្ខំ, នេតាទិសំ មណិរតនំ តវត្ថិ;

ធម្មេន ជិស្សាម អសាហសេន, ជិតោ ច នោ ទិប្បមវាករោហិ”។

*“បពិត្រព្រះរាជា ពេលល្បែងរៀបចំរួចរាល់ហើយ សូមព្រះអង្គស្តេចចូលមកកាន់ទីក្រសាលល្បែង កែវមណីប្រាកដដូច្នេះរបស់ព្រះអង្គមិនមានទេ យើងគប្បីឈ្នះគ្នាដោយធម៌ មិនបាច់គំរាមកំហែងទេ មួយទៀត ព្រះអង្គ បើទូលព្រះបង្គំឈ្នះព្រះអង្គហើយ សូមទ្រង់សងឲ្យឆាប់” ។*

*គ្រានោះ ព្រះរាជាត្រាស់នឹងបុណ្ណកៈថា ៖*

*“ម្នាលមាណព អ្នកកុំខ្លាចយើងដោយគិតថា យើងនេះជាស្តេចឲ្យសោះ ទោះបីជោគជ័យឬបរាជ័យក៏ដោយ យើងនឹងប្រព្រឹត្តទៅដោយសមត្ថភាពរបស់យើង មិនមែនដោយការប្រើអំណាចនោះទេ” ។*

*ឮដូច្នោះ បុណ្ណកៈថា ៖*

*“សូមព្រះអង្គដឹងភាពជោគជ័យឬបរាជ័យ ដោយធម៌តែម៉្យាងរបស់យើង”*

*ថាដូច្នេះហើយ បុណ្ណកៈបានសូមស្តេចទាំងនោះឲ្យជួយធ្វើជាសាក្សី ៖*

“បញ្ចាល បច្ចុគ្គត សូរសេន, មច្ឆា ច មទ្ទា សហ កេកកេភិ;

បស្សន្តុ នោតេ អសឋេន យុទ្ធំ, ន នោ សភាយំ ន ករោន្តិ កិញ្ចិ" ។

"បពិត្រព្រះបាទបញ្ចាលដ៏ល្បីល្បាញ សូមព្រះបាទសុរសេន ព្រះបាទមច្ឆៈ ព្រះបាទមទ្ទៈ ព្រមទាំងព្រះបាទកេកកៈទាំងនោះ ទ្រង់ទតចម្បាំងល្បែង ដោយការមិនអួតអាងរបស់យើងចុះ ក្សត្រទាំងឡាយ សុទ្ធតែធ្វើជាសាក្សីរបស់យើងក្នុងរោង" ។

បុណ្ណកយក្សសេនាបតី បានសូមឲ្យព្រះរាជាទាំងឡាយជួយធ្វើជាសាក្សីយ៉ាងនេះ ។ ចំណែកព្រះរាជា ទ្រង់មានស្តេច ១០១ អង្គចោមរោមធ្វើជាបរិវារ ហើយទ្រង់នាំបុណ្ណកៈចូលទៅកាន់រោងល្បែង ។ ពួកគេទាំងអស់ អង្គុយលើអាសនៈដ៏សមគួរនិងដាក់កូនបាស្កាមាស លើផែនក្តារប្រាក់ ។ បុណ្ណកៈក្រាបទូលយ៉ាងលឿនដូច្នេះថា ៖

"បពិត្រមហារាជ កូនបាស្កាទាំងឡាយ មានឈ្មោះថា អាយៈផង មាលិកៈផង សាវដ្តៈផង ពហុលៈផង សន្តិភទ្រៈជាដើមផង បណ្តាកូនបាស្កាទាំងអស់នោះ សូមព្រះអង្គកាន់យកនូវកូនបាស្កាណាមួយជាទីគាប់ព្រះទ័យរបស់ទ្រង់ចុះ" ។

"ប្រពៃណាស់" ព្រះរាជាត្រាស់ហើយទ្រង់កាន់កូនបាស្កាពហុលៈ។ ចំណែកបុណ្ណកៈ កាន់យកកូនបាស្កាសាវដ្តៈ ។ គ្រានោះ ព្រះរាជាត្រាស់នឹងបុណ្ណកៈនោះថា ៖

"ម្នាលមាណព បើដូច្នោះអ្នកចូរទម្លាក់បាស្កាមុនមក"។

"បពិត្រមហារាជ មិនមែនវារៈនៃទូលបង្គំដល់មុនទេ សូមព្រះអង្គទម្លាក់មុន" បុណ្ណកៈពោល ។

"ប្រពៃណាស់" ស្ដេចត្រាស់ ។

ធម្មតាមានអារក្ខទេវតាមួយ ដែលធ្លាប់ជាមាតារបស់ព្រះរាជាក្នុងអត្តភាពទី ៣ ។ ដោយអានុភាពនៃអារក្ខទេវតានោះ ទើបព្រះរាជាតែងលេងល្បែងឈ្នះគេ ។ ពេលនោះ អារក្ខទេវតានោះ កំពុងតែឈរនៅមិនឆ្ងាយប៉ុន្មានអំពីព្រះរាជាដែរ ។ ព្រះរាជារឭកនូវទេវធីតា ក៏ច្រៀងនូវចម្រៀងល្បែងមួយបទ ហើយពោលនូវគាថាទាំងនេះ ៖

"សព្វា នទី វង្កគតី, សព្វេ កដ្ឋមយា វនា;
សព្ពិត្ថិយោករេ បាបំ, លភមានេ និវាតកេ។

អថ បស្សតុ មំ អម្ម, វិជយំ មេ បទិស្សតុ;
អនុកម្បាហិ មេ អម្ម, មហន្តំ ជយមេស្សតុ។

ទេវតេ ត្វដ្ឋ រក្ខ ទេវិ, បស្ស មា មំ វិភាវេយ្យ;
អនុកម្បកា បតិដ្ឋា ច, បស្ស ភទ្រានិ រក្ខិតុំ។

ជម្ពោនទមយំ បាសំ, ចតុរំសមដ្ឋង្គុលិ;
វិភាតិ បរិសមជ្ឈេ, សព្វកាមទទោ ភវ។

នេវតេ មេ ជយំ នេហិ, បស្ស មំ អប្បភាគិនំ;
មាតានុកម្បកោ ចោសោ, សទា ភទ្រានិ បស្សតិ។

អដ្ឋកំ មាលិកំ វុត្តំ, សាវដ្ដញ្ច ឆកំ មតំ;
ចតុក្កំ ពហុលំ ញេយ្យំ, ទ្វិពិន្ទុសន្តិភទ្រកំ;
ចតុវីសតិ អាយា ច, មុនិន្ទេន បកាសិតា"។

*ព្រះរាជាទ្រង់ច្រៀងនូវចម្រៀងល្បែងយ៉ាងនេះហើយ ទ្រង់បាន បំបែរបាស្កាទាំងឡាយដោយព្រះហស្ត គ្រវាត់បោះទៅឰដ៏អាកាស ។ ដោយអានុភាពរបស់បុណ្ណកៈ បាស្កាធ្លាក់ទៅក្នុងទីបរាជ័យរបស់ព្រះ រាជា ។ ព្រះរាជា ហេតុតែទ្រង់ឈ្លាសវាងវៃខ្លាំងខាងសិល្បៈល្បែង ទ្រង់ ក៏ដឹងថាបាស្កាទាំងឡាយ កំពុងតែធ្លាក់ក្នុងទីបរាជ័យរបស់ព្រះអង្គ ទ្រង់ឈោងព្រះហស្តចាប់កូនបាស្កាលើអាកាស មិនឲ្យធ្លាក់ដល់ក្តារ ទាន់ ហើយបោះទៅអាកាសម្តងទៀត ។ កាលដែលដឹងថាបាស្កាធ្លាក់ ក្នុងទីបរាជ័យរបស់ទ្រង់ជាលើកទី ២ ព្រះអង្គក៏បានចាប់ធ្វើយ៉ាងដូច្នោះ ទៀត ។ គ្រានោះ បុណ្ណកៈគិតថា "ស្តេចអង្គនេះកំពុងលេងល្បែងជា មួយនឹងយក្សប្រហែលអញ តែអាចចាប់បាស្កាដែលធ្លាក់លើទីបរាជ័យ បាន ព្រោះហេតុអ្វី?" ។ កាលក្រឡេកមើលនាយអាយ បុណ្ណកៈនោះ ក៏ដឹងនូវអានុភាពរបស់អារក្ខទេវតានៃស្តេចអង្គនោះ គេបានបើកភ្នែក*

ធំ ៗ សម្ទឹងដាក់អារក្ខទេវតានោះ ធ្វើឫកហាក់ដូចជាក្រោធខ្លាំងណាស់ ។ រីឯអារក្ខទេវតានោះ ភ័យតក់ស្លុតរត់រហូតទៅដល់កំពូលភ្នំចក្កវាឡ ឈរបើកភ្នែកស្ងន់ស្ញោញ័រខ្លួនទទ្រើក ។ ព្រះរាជាបោះបាស្កាជាលើកទី ៣ ដឹងថា បាស្កាធ្លាក់ចំទីបរាជ័យរបស់ខ្លួនទៀត ទោះយ៉ាងណាក៏ដោយ ហេតុតែដោយអានុភាពនៃបុណ្ណកៈ លើកនេះ ទ្រង់មិនអាចឈោងដៃលាចាប់បានទេ ។ កូនបាស្កាទាំងនោះ ធ្លាក់ក្នុងទីបរាជ័យរបស់ព្រះរាជា ។ គ្រានោះ បុណ្ណកៈដឹងនូវភាពបរាជ័យរបស់ស្តេចហើយ គេក៏ទះដៃបន្លឺនូវសីហនាទដោយសំឡេងដ៏ខ្លាំង ៣ ដងថា "**ជិតំ មេ, ជិតំ មេ, ជិតំ មេ**, អញឈ្នះហើយ ៗ" ។ សំឡេងនោះ បានឮខ្ទរខ្ទាយពាសពេញសកលជម្ពូទ្វីប ។ បុណ្ណកយក្សឈ្នះព្រះរាជា ដោយមានព្រះរាជាដទៃជាសាក្សី សំឡេងគឹកកង សំឡេងហ៊ោកញ្ជ្រៀវក៏កើតមានក្នុងទីនោះ ។ ឯព្រះរាជា ទ្រង់បរាជ័យ មានព្រះហឫទ័យមិនរីករាយ ។ គ្រានោះ បុណ្ណកៈលួងលោមព្រះអង្គឲ្យធូរហឫទ័យថា ៖

"ជយោ មហារាជ បរាជយោ ច, អាយូហតំ អញ្ញតរស្ស ហោតិ;
ជនិន្ទ ជីនោសិ វរទ្ធនេន, ជិតោ ច មេ ខិប្បមវាករោហិ" ។

"បពិត្រមហារាជ បណ្តាពួកយើងដែលខំប្រឹងព្យាយាម ការឈ្នះនិងការចាញ់ គង់មានដល់អ្នកណាមួយ បពិត្រព្រះអង្គជាធំជាងជន ឥឡូវនេះ ខ្ញុំព្រះអង្គឈ្នះហើយ ទូលព្រះបង្គំត្រូវយកទ្រព្យ

ដ៏ប្រសើរ សូមព្រះអង្គប្រគល់ទ្រព្យនោះដល់ខ្ញុំមកកុំឃឹតយូរ ឡើយ" ។

គ្រានោះ ព្រះរាជាមានបន្ទូលនឹងបុណ្ណកៈថា ៖

"ចូរយកចុះ អ្នក" រួចទ្រង់ប្រាប់ថា ៖

"ហត្ថី គវាស្សា មណិកុណ្ឌលា ច, យញ្ចាបិ មយ្ហំ រតនំ បថព្យា;
គណ្ហាហិ កច្ចាន វរំ ធនានំ, អាទាយ យេនិច្ឆសិ តេន គច្ឆ" ។

"ម្នាលមាណពកច្ចាយនគោត្រ ដំរី គោ សេះ កែវមណី និង កុណ្ឌល ឬកែវណាមួយរបស់យើងលើផែនដីនេះ បណ្ដាទ្រព្យ ទាំងនោះ អ្នកចូរយកទ្រព្យណាដែលប្រសើរទាំងនោះ អ្នកចូរ កាន់យកទៅតាមសេចក្ដីពេញចិត្តចុះ" ។

បុណ្ណកៈក្រាបទូលថា ៖

"ហត្ថី គវាស្សា មណិកុណ្ឌលា ច, យញ្ចាបិ តុយ្ហំ រតនំ បថព្យា;
តេសំ វរោ វិធុរោ នាម កត្តា, សោ មេ ជិតោ តំ មេ អវាករោហិ" ។

"ដំរី គោ សេះ កែវមណី និងកុណ្ឌល ឬកែវណាមួយរបស់ព្រះអង្គ លើផែនដីនេះ មិនមានទ្រព្យណាប្រសើរដល់ខ្ញុំព្រះអង្គឡើយ ប៉ុន្តែ វិធុរបណ្ឌិតអាមាត្យ ទុកជាទ្រព្យប្រសើរជាងទ្រព្យទាំងនោះ

ព្រះអង្គខ្ញុំព្រះអង្គឈ្នះហើយ សូមព្រះរាជទានវិធុរបណ្ឌិតនោះមកទូលព្រះបង្គំ" ។

ព្រះរាជាថា ៖

"អត្តា ច មេ សោ សរណំ គតី ច,
ទីបោ ច លេណោ ច បរាយណោ ច;
អសន្តុលេយ្យោ មម សោ ធនេន,
បាណេន មេ សាទិសោ ឯស កត្តា" ។

"វិធុរបណ្ឌិតនោះ ទុកដូចជាខ្លួនយើង ទាំងជាទីពឹង ជាគតិ ជាប្រទីប ជាទីពំនាក់ ជាទីបង្អែករបស់យើហ វិធុរបណ្ឌិតនោះ គេមិនគប្បីប្រៀបផ្ទឹម ដោយទ្រព្យរបស់យើងបានទេ វិធុរបណ្ឌិតនុ៎ះជាអាមាត្យ ប្រាកដស្មើដោយជីវិតរបស់យើង" ។

បុណ្ណកៈថា ៖

"ចិរំ វិវាទោ មម តុយ្ហញ្ចស្ស, កាមញ្ច បុច្ឆាម តមេវ គន្ត្វា;
ឯសោវ នោ វិវរតុ ឯតមត្ថំ, យំ វក្ខតី ហោតុ កថា ឧភិន្នំ" ។

"ការជជែកគ្នារវាងទូលព្រះបង្គំនឹងព្រះអង្គ ពិតជាមិនអាចបញ្ចប់បានទេ មានតែយើងត្រូវទៅសួរសេចក្តីពិតនេះ នឹងវិធុរបណ្ឌិតនោះវិញ សូមឲ្យវិធុរបណ្ឌិតនុ៎ះ ញែកសេចក្តីនុ៎ះដល់យើង បើ

*វិធុរបណ្ឌិតសម្រេចសេចក្ដីយ៉ាងណា យើងនឹងគោរពតាមការសម្រេចរបស់វិធុរបណ្ឌិតនោះចុះ" ។*

"អត្ថា ហិ សច្ចំ ភណសិ, ន ច មាណវ សាហសំ;
តមេវ គន្ត្វា បុច្ឆាម, តេន តុស្សាមុភោ ជនា"តិ ។

*"ម្នាលមាណព យោបល់របស់អ្នកពិតជាត្រឹមត្រូវណាស់ មិនមែននិយាយដោយមានទោស គំនិតរបស់អ្នកគឺជាគំនិតរបស់ជនជាសប្បុរស យើងនឹងទៅសួរវិធុរបណ្ឌិតនោះចុះ យើងទាំង ២ នាក់នឹងត្រេកអរតាមវិធុរបណ្ឌិតនោះ" ស្ដេចត្រាស់។*

## ស្ដេចនិងបុណ្ណកយក្សចូលទៅរកវិធុរបណ្ឌិត

*លុះនិយាយយ៉ាងនេះហើយ ព្រះរាជាបាននាំស្ដេច ១០១ អង្គ និងបុណ្ណកៈ ទៅកាន់ធម្មសភាយ៉ាងរហ័ស ដោយមានចិត្តត្រេកអរ ។ ចំណែកវិធុរបណ្ឌិត គ្រាន់តែបានឃើញព្រះរាជាភ្លាម ក៏ចុះចាកអាសនៈ មកថ្វាយបង្គំព្រះរាជា រួចឈរនៅក្នុងទីដ៏សមគួរ ។ គ្រានោះបុណ្ណកៈ ហៅព្រះមហាសត្តហើយនិយាយថា ៖*

*"នែ៎បណ្ឌិត កិត្តិសព្ទរបស់អ្នកល្បីខ្ទរខ្ទាយពេញសកលលោកថាអ្នកឋិតនៅក្នុងធម៌ មិននិយាយនូវពាក្យកុហក បើទោះបីមានហេតុដល់អាយុជីវិត, ប៉ុន្តែខ្ញុំនឹងដឹងថា អ្នកឋិតនៅក្នុងធម៌មែន ឬមិនមែន ក្នុងថ្ងៃនេះហើយ"*

បុណ្ណកៈបន្តពោលថា ៖

"សច្ចំ នុ ទេវា វិទហូ កុរូនំ, ធម្មេ ឋិតំ វិធុរំ នាមមច្ចំ;
ទាសោសិ រញ្ញោ ឧទ វាសិ ញាតិ,
វិធុរោតិ សង្ខា កតមាសិ លោកេ" ។

"ពួកទេវតាសរសើរអ្នកឈ្មោះវិធុរៈ ថាជាអាមាត្យឋិតនៅក្នុងធម៌របស់អ្នកដែនកុរុ ពិតមែនឬ ឬក៏អ្នកជាទាសៈ ឬជាញាតិរបស់ព្រះរាជា ការរាប់អ្នកថាវិធុរៈ តើអ្នកជាអ្វីក្នុងលោក ?"

គ្រានោះ មហាសត្តគិតថា "បុរសនេះ សួរនូវសំណួរយ៉ាងនេះចំពោះអញ ប៉ុន្តែអញនេះអាចពន្យល់គេថាជាញាតិព្រះរាជាក៏បាន ថាបុគ្គលប្រសើរជាងព្រះរាជាក៏បាន ថាមិនមែនជាអ្វី ៗ របស់ព្រះរាជាក៏បាន, ប៉ុន្តែ ទីពឹងដែលស្មើដោយសច្ចៈក្នុងលោកនេះ មិនមានទេ ការដែលពោលសច្ចៈតែម៉្យាង ប្រសើរជាង" ។ គិតដូច្នេះហើយ វិធុរៈប្រាប់បុណ្ណកៈថា ៖

"ម្នាលមាណព ខ្ញុំជាញាតិរបស់ព្រះរាជា ក៏ទេ, ជាបុគ្គលប្រសើរជាងព្រះរាជា ក៏ទេ, ខ្ញុំគឺជាមនុស្សម្នាក់បណ្តាទាសៈទាំង ៤" ។

រួចលោកបង្ហាញទាសៈទាំង ៤ ថា ៖

"អាមាយទាសាបិ ភវន្តិ ហេកេ, ធនេន កីតាបិ ភវន្តិ ទាសា;

សយម្បិ ហេកេ ឧបយន្តិ ទាសា, ភយា បណុន្នាបិ ភវន្តិ ទាសា។
ឯតេ នរានំ ចតុរោវ ទាសា, អទ្ធា ហិ យោនិតោ អហម្បិ ជាតោ;
ភវោ ច រញ្ញោ អភវោ ច រញ្ញោ, ទាសាហំ ទេវស្ស បរម្បិ គន្ត្វា;
ធម្មេន មំ មាណវ តុយ្ហ ទជ្ជា" ។

*"បុគ្គលពួកខ្លះ ជាទាសៈកើតពីក្នុងផ្ទៃខ្ញុំស្រី ពួកខ្លះជាទាសៈគេលោះ[៥១]ដោយទ្រព្យ ពួកខ្លះជាទាសៈចូលទៅនៅខ្លួនឯង ពួកខ្លះបោះបង់លំនៅព្រោះភ័យ ទៅនៅជាទាសៈគេ ទាសៈរបស់ជនទាំងឡាយ មាន ៤ ពួកនេះឯង ។ ឯយើង ពិតជាទាសៈអំពីកំណើត ព្រះរាជាមានសេចក្ដីចម្រើនក្ដី ព្រះរាជាមានសេចក្ដីមិន*

---

[៥១] (កិ.) *បេញថ្លៃយករបស់ដែលបញ្ចាំឬយកមនុស្សមកធ្វើជាទាសៈឬទាសី* : *លោះរបស់បញ្ចាំ; លោះមនុស្សប្រើ* (មានតែក្នុងសម័យពីដើម) ។ *សងប្រាក់ទៅម្ចាស់បំណុលសុំដកខ្លួនឲ្យរួចអំពីទាសភាព* : *លោះខ្លួនឲ្យរួចជាអ្នកជា ។ ចាញ់* : *លោះកាំភ្លើង, លោះស្នា ។ ស្ដីឲ្យម៉ាំង ៗ ឬខ្លាំង ៗ ឬក៏ជេរពេញទ្រពងមាត់ ឥតក្រែង* : *លោះតែពីរបីម៉ាត់ទៅ បាត់មាត់ដូចគេចុក ។*

(ន.) *ឈ្មោះឈើដំណាំមួយប្រភេទស្លឹកធំ ៗ ស្រដៀងនឹងស្លឹកពង្រ, ផ្លែមូលសំបកក្រាស់ សាច់ជ្រាកមានសរសៃស្វិតជាប់នឹងគ្រាប់ ខ្លះមានរសជូរ ខ្លះជូរអែម, សំបកផ្លែប្រើជាបន្ទៃស្ទម្ពរបាន ។ មានពាក្យតំណាលថា ព្រះបាទសម្ដេចព្រះឧទ័យរាជា (ក្សត្រិយ៍កម្ពុជរដ្ឋ) ទ្រង់សព្វព្រះរាជហឫទ័យ ទ្រង់ប្រោសព្រះរាជទានឈ្មោះឲ្យហៅឈើបំពេញរាជ្យ វិញ, ជាប់ដរាបមកដល់សព្វថ្ងៃនេះ; សៀមហៅ ក:ថន់ ឬ ស:ថន់, ខ្មែរក៏ហៅ កថន ខ្លះដែរ; គួរហៅតាមសម្ដីខ្មែរថា បំពេញរាជ្យ វិញ ។*

ចម្រើនក្តី យើងមិនអាចនឹងពោលកុហកបានទេ យើងបើទុកជាទៅកាន់ទីដទៃ ក៏គង់នៅជាទាសៈ របស់ព្រះសម្មតិទេព ម្នាលមាណព ព្រះរាជាគួរប្រទានយើងដល់អ្នកដោយធម៌" ។

ឮដូច្នោះ បុណ្ណកៈត្រេកអរស្រស់ស្រាយ ទះដៃម្តងទៀត ពោលថា ៖

"អយំ ទុតីយោ វិជយោ មមជ្ជ, បុដ្ឋោ ហិ កត្តា វិវរេត្ថ បញ្ហំ;
អធម្មរូបោ វត រាជសេដ្ឋោ, សុភាសិតំ នានុជានាសិ មយ្ហំ" ។

"នេះឯងជាជ័យជម្នះទី ២ របស់ខ្ញុំ ក្នុងថ្ងៃនេះ ព្រោះថា វិធុរអាមាត្យដែលខ្ញុំសួរហើយ ក៏ញែកប្រស្នាហើយ ឱហ្ន៎ ! ព្រះរាជាដ៏ប្រសើរមិនតាំងនៅក្នុងធម៌ ទ្រង់មិនអនុញ្ញាតឲ្យនូវវិធុរបណ្ឌិតជាអ្នកពោលពាក្យពីរោះ ដល់ខ្ញុំ" ។

ទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ព្រះរាជាមិនសប្បាយព្រះរាជហឫទ័យ ទ្រង់ខ្ញាល់ចំពោះមហាសត្តថា "បណ្ឌិតលែងមើលឃើញអ្នកដែលបានឲ្យយសប្រហែលអញហើយ ឥឡូវនេះ គេមើលឃើញអាក្មេងដែលទើបតែចួបវិញ" រួចទ្រង់ត្រាស់ថា ៖

"ម្នាលមាណព ប្រសិនបើកំហុសនោះ គប្បីមានដល់យើង អ្នកចូរយកគេទៅចុះ"

ហើយទ្រង់បន្តត្រាស់ថា ៖

"ឯវំ ចេ នោ សោ វិវរេត្ថ បញ្ហំ, ទាសោហមស្មិ ន ច ខោស្មិ ញាតិ;
គណ្ហាហិ កច្ចាន ឥមំ ធនានំ, អាទាយ យេនិច្ឆសិ តេន គច្ឆ" ។

"បើវិធុរបណ្ឌិតនោះ ញែកប្រស្នាដល់យើងយ៉ាងនេះថា គេជាទាសៈ មិនមែនជាញាតិរបស់យើងទេ ម្នាលកច្ចានៈ អ្នកចូរយកវិធុរបណ្ឌិត ជាទ្រព្យដ៏ប្រសើរជាងទ្រព្យទាំងឡាយចុះ អ្នកចូរយកទៅតាមពេញចិត្តចុះ" ។

អក្ខកណ្ឌ ចប់ ។

# ជំពូកទី ៣

## វិធុរបណ្ឌិតគោចកន្ទុយសេះ

### ព្រះរាជាអញ្ជើញវិធុរបណ្ឌិតសម្តែងឃរាវាសធម៌

លុះត្រាស់យ៉ាងនេះហើយ ព្រះរាជាទ្រង់ព្រះចិន្តាថា "មាណព មុខតែចាប់លោកបណ្ឌិតទៅតាមការគាប់ចិត្ត កាលបើលោកបណ្ឌិតត្រូវយក្សចាប់បាត់ទៅហើយ ចាប់ពីពេលនេះតទៅ អាត្មាអញខានបានស្តាប់ធម្មកថាដ៏ពីរោះទៀតហើយ បើដូច្នោះ មានតែអាត្មាអញអញ្ជើញបណ្ឌិតនេះ ក្នុងនាមខ្លួនឯងជាស្តេច ឲ្យអង្គុយលើធម្មាសនៈដែលតុបតែងវិចិត្រហើយ អញគប្បីសួរប្រស្នាទាំងឡាយស្តីពីឃរាវាសធម៌[៥២] ទើបទ្រង់ត្រាស់នឹងវិធុរៈយ៉ាងនេះថា ៖

"នែបណ្ឌិត ក្នុងកាលលោកទៅបាត់ហើយ ធម្មកថាដ៏ពីរោះដែលលោកធ្លាប់សម្តែង យើងខានបានស្តាប់ទៀតហើយ ដូច្នោះសូមអញ្ជើញលោកឡើងអង្គុយលើធម្មាសនៈ ដែលតុបតែងដ៏វិចិត្រ ដោយតាំងនៅក្នុងតំណែងខ្លួន ហើយដោះស្រាយប្រស្នាស្តីអំពីឃរាវាស ដល់យើងជាលើកចុងក្រោយផង" ។

[៥២] (ន.) (បា.),(សំ.) (ឃរា--) (គ្ឫហាវាស) ការនៅគ្រប់គ្រងផ្ទះ; អ្នកនៅគ្រប់គ្រងផ្ទះ ។

"ព្រះករុណាថ្លៃវិសេស" វិធុរបណ្ឌិតយល់ព្រម ហើយលោកឡើងអង្គុយលើធម្មាសនៈដ៏វិចិត្រ ព្រះរាជាទ្រង់សួរប្រស្នាអំពីឃរាសធម៌ លោកក៏បានដោះស្រាយយ៉ាងក្បោះក្បាយ ។ ប្រស្នាក្នុងឃរាវាសនោះមានដូចតទៅនេះ ៖

ព្រះបាទកោរព្យរាជ ទ្រង់បានត្រាស់សួរថា ៖

"វិធុរ វសមានស្ស, គហដ្ឋស្ស សកំ ឃរំ;
ខេមា វុត្តិ កថំ អស្ស, កថំ នុ អស្ស សង្គហោ ។
អព្យាពជ្ឈំ កថំ អស្ស, សច្ចវាទី ច មាណវោ;
អស្មា លោកា បរំ លោកំ, កថំ បេច្ច ន សោចតិ" ។

"ម្នាលវិធុរៈ បុគ្គលជាគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះរបស់ខ្លួន តើគួរប្រព្រឹត្តដូចម្ដេច ទើបមានការក្សេមក្សាន្ត[៥៣] ? គួរមានការសង្គ្រោះដូចម្ដេចហ្ន៎ ? តើប្រព្រឹត្តដូចម្ដេច ទើបមិនមានទុក្ខ ? មាណពដែលឈ្មោះថាពោលពាក្យពិត តើដូចម្ដេច ? បុគ្គលជាគ្រហស្ថច្យុត[៥៤]ពីលោកនេះ ទៅកាន់លោកខាងមុខ លុះទៅកាន់លោកខាងមុខហើយ តើធ្វើដូចម្ដេចទើបមិនសោកស្ដាយ ?

---

[៥៣] (គុ.) ដែលមានសេចក្ដីសុខសាន្ត ។

[៥៤] (កិ.) (សំ.),(បា.) (ចុត) ឃ្លាត, របូត, ស្លាប់, ដែលស្លាប់ហើយ; ច្រើននិយាយចំពោះតែទេវតាអស់ជីវិត : ទេវតាច្យុត ។

បន្ទាប់ពីបានស្ដាប់ប្រស្នានោះហើយ វិធុរបណ្ឌិតអ្នកមានញាណគតិ អ្នកមានព្យាយាម មានប្រាជ្ញាយល់អត្ថ យល់ធម៌ទាំងពួង បានឆ្លើយប្រស្នានុ៎ះ ថ្វាយព្រះរាជាក្នុងរោងធម្មសភានោះថា ៖

"ន សាធារណទារស្ស, ន ភុញ្ជេ សាទុមេកកោ;
ន សេវេ លោកាយតិកំ, នេតំ បញ្ញាយ វឌ្ឍនំ។

"គ្រហស្ថគប្បីស្មោះត្រង់ជាមួយនឹងភរិយាតែម្នាក់ មិនគួរបរិភោគអាហារមានរសឆ្ងាញ់តែម្នាក់ឯង មិនគួរប្រព្រឹត្តអំពើពាលា ដែលទាក់ទងនឹងលោក ព្រោះរឿងបែបនុ៎ះ មិនមែនជាគ្រឿងចម្រើនប្រាជ្ញាទេ ។

"សីលវា វត្តសម្បន្នោ, អប្បមត្តោ វិចក្ខណោ;
និវាតវុត្តិ អត្ថទ្ធោ, សុរតោ សខិលោ មុទុ ។
សង្គហេតា ច មិត្តានំ, សំវិភាគី វិធានវា;
តប្បេយ្យ អន្នបានេន, សទា សមណព្រាហ្មណេ ។

គ្រហស្ថគួរជាអ្នកមានសីល បរិបូណ៌ដោយវត្ត[៥៥] មិនធ្វេសប្រហែស មានប្រាជ្ញាវាងវៃ ជាអ្នកប្រព្រឹត្តឱនលំទោន មិនរឹងត្អឹង ជាអ្នកស្លូត

[៥៥] (ន.) (បា.),(សំ.) (វាត់) (វត៌) ប្រព្រឹត្តិ, ការប្រព្រឹត្ត, សេចក្ដីប្រតិបត្តិ; មុខការ, កិច្ចដែលគួរធ្វើ; នាទី; ការកាន់សីលធម៌; សេចក្ដីគោរព; ទំនៀម, សណ្ដាប់ធ្នាប់ : មនុស្ស

បួត មានពាក្យទន់ពីរោះ និងសុភាពរាបសា" ។ ជាអ្នកសង្គ្រោះមិត្រទាំងឡាយ ជាអ្នកចែករំលែកទាន មានការចាត់ចែងដ៏ល្អ ញុំាងសមណព្រាហ្មណ៍ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹកគ្រប់កាល ។

"ធម្មកាមោ សុតាធារោ, ភវេយ្យ បរិបុច្ឆកោ;
សក្កច្ចំ បយិរុបាសេយ្យ, សីលវន្តេ ពហុស្សុតេ ។
ឃរមាវសមានស្ស, គហដ្ឋស្ស សកំ ឃរំ;
ខេមា វុត្តិ សិយា ឯវំ, ឯវំ នុ អស្ស សង្គហោ ។

ជាអ្នកប្រាថ្នាសុចរិតធម៌ ទ្រទ្រង់ការចេះដឹង ជាអ្នកសាកសួរ ឧស្សាហ៍ចូលទៅរកអ្នកមានសីល ជាពហុស្សូតដោយគោរព ។ បុគ្គលជាគ្រហស្ថ ជាអ្នកនៅគ្រប់គ្រងផ្ទះ គួរមានការប្រព្រឹត្តដ៏ក្សេមក្សាន្តយ៉ាងនេះ គួរមានការសង្គ្រោះយ៉ាងនេះ ។

"អព្យាពជ្ឈំ សិយា ឯវំ, សច្ចវាទី ច មាណវោ;
អស្មា លោកា បរំ លោកំ, ឯវំ បេច្ច ន សោចតិ" ។

---

មានវត្តល្អ មនុស្សមានសេចក្តីប្រតិបត្តិល្អ; សិស្សធ្វើវត្ត ឬ យកវត្តគ្រូ សិស្សធ្វើសេចក្តីគោរពចំពោះគ្រូ ។

គ្រហស្ថគួរជាអ្នកមិនមានទុក្ខយ៉ាងនេះ មាណពឈ្មោះថា ពោលពាក្យពិតយ៉ាងនេះ គ្រហស្ថច្យុតពីលោកនេះទៅកាន់លោកខាងមុខ លុះទៅកាន់លោកខាងមុខហើយ រមែងមិនសោកស្ដាយយ៉ាងនេះឯង" ។

មហាសត្វ ដោះស្រាយឃរាវាសបញ្ហាយ៉ាងនេះហើយ លោកចុះអំពីបល្ល័ង្ក ថ្វាយបង្គំព្រះរាជា ។ ចំណែកព្រះរាជា ធ្វើមហាសក្ការៈដល់មហាសត្វរួចហើយ ទ្រង់យាងទៅកាន់និវេសន៍របស់ព្រះអង្គដោយមានស្ដេច ១០១ អង្គជាបរិវារចោមរោម ។

ឃរាវាសបញ្ហា ចប់ ។

## ភាពត្រៀមក្រាំនៃគ្រួសារវិធុរបណ្ឌិត

ចំណែកមហាសត្តវិញ លោកក៏ត្រឡប់វិលវិញដែរ ។ គ្រានោះ បុណ្ណកៈ និយាយនឹងមហាសត្តថា ៖

"លោកចូរមក ឥឡូវនេះព្រះបាទធនញ្ជ័យជាឥស្សរៈបានព្រះរាជទានលោកដល់ខ្ញុំហើយ យើងនឹងទៅពេលនេះតែម្តង សូមលោកប្រតិបត្តិឲ្យជាប្រយោជន៍ដល់ខ្ញុំ នេះជាទំនៀមរបស់អ្នកប្រាជ្ញក្នុងកាលមុន" ។

វិធុរបណ្ឌិតពោលថា ៖

"ម្នាលមាណព ខ្ញុំដឹងថាខ្លួនខ្ញុំនៅក្នុងកណ្តាប់ដៃអ្នកហើយ ព្រោះខ្ញុំត្រូវព្រះបាទធនញ្ជ័យជាឥស្សរៈព្រះរាជទានខ្ញុំដល់អ្នក តែខ្ញុំសូមឲ្យអ្នកនៅក្នុងផ្ទះខ្ញុំរយៈពេល ៣ ថ្ងៃសិន ខ្ញុំសូមពេលប្រៀនប្រដៅកូននិងប្រពន្ធរបស់ខ្ញុំជាមុន ហើយខ្ញុំនឹងទៅជាមួយអ្នក" ។

ឮដូច្នោះហើយ បុណ្ណកៈគិតថា ៖

"លោកបណ្ឌិតនេះជាអ្នកពោលសច្ចៈ បណ្ឌិតនេះ មានឧបការៈច្រើនណាស់ដល់អាត្មាអញ, កុំថាឡើយ ៣ ថ្ងៃ បើគេប្រាប់ឲ្យអញនៅផ្ទះគេសូម្បី ៧ ថ្ងៃ ឬកន្លះខែ ក៏អញអាចទ្រាំនៅបានដែរ" ។

គិតដូច្នេះហើយ បុណ្ណកៈតបថា ៖

"លោកពោលពាក្យណា ពាក្យនោះចូរមានដល់ខ្ញុំ ដោយប្រការដូច្នោះ យើងនឹងនៅផ្ទះរបស់លោកតាមការស្នើ លោកដ៏ចម្រើន ចូរធ្វើកិច្ចក្នុងផ្ទះរបស់លោកក្នុងថ្ងៃនេះចុះ លោកដ៏ចម្រើន ចូរប្រៀនប្រដៅបុត្រនិងភរិយា ក្នុងថ្ងៃនេះចុះ កាលបើលោកចេញទៅ បុត្រនិងភរិយារបស់លោក គួរគប្បីប្រតិបត្តិយ៉ាងណាដើម្បីបានសេចក្ដីសុខ សូមលោកប្រៀនប្រដៅយ៉ាងនោះចុះ" ។

"ប្រពៃណាស់" បុណ្ណកៈឆ្លើយ ហើយក៏ចេញទៅជាមួយនឹងវិធុរបណ្ឌិតដែរ ។ ឯវិធុរបណ្ឌិតជាបុគ្គលប្រសើរថ្លៃថ្លា ចូលទៅកាន់ខាងក្នុងបុរី ដែលបរិបូណ៌ដោយដំរីនិងសេះអាជានេយ្យ ។ មហាសត្តលោកមានប្រាសាទ ៣ ដើម្បីប្រយោជន៍ដល់រដូវទាំង ៣ ។ បណ្ដាប្រាសាទទាំង ៣ នោះ ប្រាសាទដំបូងឈ្មោះថា **កោញ្ចប្រាសាទ** ប្រាសាទទី ២ ឈ្មោះថា **មយូរប្រាសាទ** ប្រាសាទទី ៣ ឈ្មោះថា **បិយកេតប្រាសាទ** ។ ព្រះមហាសត្តនាំបុណ្ណកយក្សចូលទៅកាន់ប្រាសាទជាទីរីករាយក្រៃលែង ជាប្រាសាទមានភក្សាហារច្រើន មានបាយនិងទឹកច្រើន ដូចជាភពមសក្កសារៈនៃព្រះវាសវៈអ៊ីចឹង ។

មហាសត្ត លុះចូលទៅហើយ បានប្រើគេឲ្យចាត់ចែងបន្ទប់ដេកនិងមហាតលដ្ឋាន លើជាន់ទី ៧ នៃប្រាសាទដ៏វិចិត្រ ប្រើឲ្យរៀបចំគ្រែ

ដេកតម្កល់បាយទឹកជាដើមប្លែក ៗ សព្វគ្រប់ប្រការសម្រាប់បុណ្ណកៈ ។ មិនតែប៉ុណ្ណោះ មហាសត្តបានប្រគល់ដល់បុណ្ណកៈនូវស្ត្រីចំនួន ៥០០ នាក់ផងដែរ និងប្រាប់ថា "ស្ត្រីទាំងនេះ ចូរជាប្រពន្ធរបស់អ្នក, ចូរអ្នកនៅទីនេះកុំអផ្សុកឡើយ" លុះប្រាប់ដូច្នេះហើយ ក៏បានទៅលំនៅឋានរបស់ខ្លួនលោកវិញ ។ ក្នុងកាលមហាសត្តចេញទៅបាត់ ស្រី ៗ តាក់តែងខ្លួនដ៏សមរម្យល្អ ចាប់គ្រឿងតូរ្យតន្ត្រីផ្សេង ៗ នាំគ្នាប្រគំលេងរាំច្រៀងរណ្ដំគ្នាដ៏ប្រសើរក្រៃលែងក្នុងប្រាសាទនោះ ដូចស្រីអប្សរក្នុងទេវលោក មកដើម្បីបម្រើបុណ្ណកៈនោះ ។ ចំណែកព្រះមហាសត្តវិញ ក្រោយពីលោករៀបចំបុណ្ណកយក្សឲ្យបរិបូណ៌ដោយពួកនារីជាទីរីករាយផង បម្រើដោយបាយនិងទឹកផង រួចរាល់ហើយ លោករំពឹងជ្រើសរើសតែសេចក្ដីសំខាន់ ៗ ទើបចូលទៅក្នុងសម្នាក់ភរិយាច្បង ។ ក្នុងកាលនោះ មហាសត្ត និយាយនឹងភរិយាច្បង ដែលមានខ្លួនប្រោះព្រំដោយទឹកក្រអូបនៃខ្លឹមចន្ទន៍ មានសម្បុរប្រាកដស្មើដោយត្ពោរមាសជម្ពូនទថា ៖

"ម្នាលនាង មានក្អែកក្រហមដ៏ចម្រើន នាងចូរមក ចូរស្ដាប់ខ្ញុំ ចូរហៅបុត្រនិងធីតារបស់យើងមក" ។

នាងអនោជា បានស្ដាប់ពាក្យរបស់ប្ដីហើយ យំមានមុខពេញដោយទឹកភ្នែក គិតថាការដែលអញទៅហៅបុត្រទាំងឡាយផ្ទាល់ មិន

គួរទេ អញនឹងបញ្ជូនកូនប្រសាស្រីទៅវិញ ដូច្នេះព្រះនាងក៏យាងទៅកាន់លំនៅឋានរបស់កូនប្រសាស្រី បាននិយាយនឹងកូនប្រសាស្រីមានក្រចកក្រហម មានភ្នែកល្អថា ៖

"ម្នាលនាងមានសម្បុរដូចផ្កាពជព្រឹក្ស នាងចូរហៅបុត្រនិងធីតាដែលទ្រទ្រង់ប្រដាប់ទាំងនោះមក" ។

កូនប្រសាស្រី ទទួលស្តាប់ថា "ចាស៎" ហើយនាងដើរចុះចាកប្រាសាទ ទៅខាងណេះទៅខាងណោះ ហៅប្រជុំកូនប្រុសស្រី និងជនជាទីទុកចិត្តទាំងអស់ របស់វិធុរបណ្ឌិត ហើយប្រាប់ថា ៖

"ព្រះបិតារបស់យើងទាំងឡាយ មានបំណងឲ្យឱវាទដល់ពួកយើង ទើបបានជាហៅ និងឮថាការឃើញពួកយើងលើកនេះ ជាគ្រាចុងក្រោយរបស់លោក" ។

កុមារធម្មបាល គ្រាន់តែឮពាក្យនោះភ្លាម ក៏ស្រែកយំហើយដើរដោយមានប្អូន ៗ ប្រុសចោមរោម ឆ្ពោះទៅកាន់សម្នាក់របស់ឪពុក ។ វិធុរបណ្ឌិតជាឪពុក គ្រាន់តែឃើញពួកគេភ្លាម មិនអាចទប់ជំហរខ្លួនបានមាននេត្រាពេញដោយទឹកអស្សុ[៥៦] ឱបថើបក្បាលកូន ៗ ផ្តេកកូនច្បង

---

[៥៦] (ន.) (បា.),(សំ.) (អ័ស-សុ) (អគ្រុ) ទឹកភ្នែក (រ. ស. ព្រះអស្សុ) ។ អស្សុជល (--ជល់) ទឹកភ្នែក (ដែរ) ។ អស្សុជលន័យន៍ ឬ អស្សុជលនេត្ត (--ជៈលៈ--) ភ្នែកដែលទទឹក

ត្រង់ទ្រូងមួយសន្ទុះរួចលោកដកចេញអំពីទ្រូង ដើរចេញអំពីបន្ទប់ ដេកទៅអង្គុយលើបល្ល័ង្ក ក្នុងមហាតលដ្ឋាន ផ្ដល់ឱវាទដល់កូនចំនួន ១០០០ នាក់ហើយ និយាយថា ៖

''តេ អាគតេ មុទ្ធនិ ធម្មចាលោ, ចុម្ពិត្វា បុត្តេ អវិកម្បមានោ;
អាមន្តយិត្វាន អវោច វាក្យំ, ទិន្នាហំ រញ្ញោ ឥធ មាណវស្ស ។
តស្សជ្ជហំ អត្តសុខី វិធេយ្យោ, អាទាយ យេនិច្ឆតិ តេន គច្ឆតិ;
អហញ្ច វោ សាសិតុមាគតោស្មិ, កថំ អហំ អបរិត្តាយ គច្ឆេ ។
សចេ វោ រាជា កុរុរដ្ឋវាសី, ជនសន្ធោ បុច្ឆេយ្យ បហូតកាមោ;
កិមាភិជានាថ បុរេ បុរាណំ, កិំ វោ បិតា បុរត្ថា ។
សមាសនា ហោថ មយាវ សព្វេ កោនីធ រញ្ញោ អព្ភតិកោ មនុស្សោ;
តមញ្ជលិំ ករិយ វទេថ ឯវំ, មា ហេវំ ទេវ ន ហិ ឯស ធម្មោ;
វិយគ្ឃរាជស្ស និហីនជច្ចោ, សមាសនោ ទេវ កថំ ភវេយ្យ'' ។

''ឪពុកត្រូវព្រះរាជាក្នុងក្រុងឥន្ទបត្តនេះ ប្រទានដល់មាណព ហើយ ថ្ងៃនេះ ឪពុកមានសេចក្ដីសុខធម្មតាទេ ប៉ុន្តែ ៣ ថ្ងៃក្រោយទៅ ឪពុកនឹងក្លាយជាអ្នកបម្រើមាណពនោះ មាណពនឹងនាំឪពុកទៅកាន់ទីកន្លែងរបស់គេពុំខានឡើយ ឪពុកមកនេះមានបំណងប្រៀនប្រដៅអ្នកទាំងឡាយ មុននឹងឪពុកចាកចេញទៅ

---

ដោកដោយទឹកភ្នែក) រ. ស. : ស្ដេចទ្រង់ ព្រះកន្សែងខ្លាំង មានព្រះអស្សុជលន័យន៍ប្លែកពីធម្មតា ។ អស្សុធារា ទនៃទឹកភ្នែក គឺទឹកភ្នែកដែលហៀរហូររហាម ។

គ្រាន់នឹងបានជារបាំងសម្រាប់ការពារខ្លួនដល់កូនទាំងឡាយ ។ កូនទាំងឡាយបើព្រះរាជានៅក្នុងដែនកុរុ និងអាមាត្យទាំងឡាយ អ្នកមានភោគៈច្រើន សួរកូនឯងទាំងឡាយថា អ្នកទាំងឡាយ ដឹងច្បាស់នូវដំណើរបុរាណ ក្នុងកាលមុនដែរឬ តើបិតារបស់អ្នកទាំងឡាយបានប្រៀនប្រដៅអ្វីខ្លះ មុននឹងចាកចេញទៅ ? មួយទៀត បើព្រះរាជាទ្រង់រាជានុញ្ញាត ឲ្យអ្នកទាំងអស់គ្នាអង្គុយលើអាសនៈស្មើនឹងព្រះអង្គដោយមានបន្ទូលថា រាជត្រកូលនេះ រកអ្នកឯណាមួយជាអ្នកខ្ពង់ខ្ពស់ឲ្យស្មើនឹងពួកអ្នកមិនមានទេ ពួកកូនឯង គប្បីធ្វើអញ្ជលីទូលព្រះរាជាយ៉ាងនេះថា បពិត្រព្រះសម្មតិទេពសូមព្រះអង្គកុំត្រាស់យ៉ាងនេះ ព្រោះថា នេះមិនមែនជាបវេណីធម៌ទេ បពិត្រព្រះសម្មតិទេព ធម្មតាសត្វចចកមានជាតិថោកទាប គប្បីមានអាសនៈស្មើ នឹងកេសរសីហៈ ដូចម្តេចបាន" ។ កូនប្រុសកូនស្រី ញាតិមិត្រសម្លាញ់ និងទាសកម្មករទាំងឡាយ បានស្តាប់សម្តីរបស់វិធុរបណ្ឌិតនោះដូច្នេះហើយ គ្រប់គ្នាមិនអាចទប់ដំហរខ្លួនបានឡើយ ក៏ស្រែកយំយ៉ាងខ្លាំង ។ ព្រះមហាសត្ត បានពន្យល់ពួកគេ ។

លក្ខណកណ្ឌ ចប់ ។

## វិធុរបណ្ឌិតសម្តែងរាជសេវក[៥៧]ធម៌

*គ្រានោះ បណ្ឌិតចូលទៅរកកូនប្រុសស្រី និងញាតិទាំងឡាយ មើលទៅឃើញពួកគេនៅស្ងៀម លោកបានតាំងផ្តើមនូវរាជវសតិធម៌ ដោយលំនាំនៃព្រះពុទ្ធថា ៖*

*"ហៃអ្នកទាំងឡាយ កុំព្រួយបារម្ភឡើយ ជាធម្មតា សង្ខារទាំងឡាយទាំងពួង មិនទៀងទេ, ដែលហៅថាយស វាតែងមានការវិបត្តិជាទីបំផុត មួយវិញទៀត ខ្ញុំនឹងប្រាប់រាជវសតិដែលជាហេតុនៃការបានយសដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ត្រងត្រាប់ស្តាប់ ដោយចិត្តមូលកុំរវាករវេទៅណាឲ្យសោះ" ។*

*វិធុរបណ្ឌិតនោះ មានសេចក្តីត្រិះរិះដោយចិត្តមិនរួញរា បានពោលពាក្យនេះនឹងបុត្រ អាមាត្យ ញាតិ និងសម្លាញ់ថា ៖*

"ឯថយ្យោ រាជវសតឹ, និសីទិត្វា សុណាថ មេ;
យថា រាជកុលំ បត្តោ, យសំ បោសោ និគច្ឆតិ" ។

[៥៧] (ន.) (សំ.),(បា.) (--វ៉ៈកៈ) *(សេវក) អ្នកបម្រើ, អ្នកចាំទទួលការបម្រើ, អ្នកគាល់បម្រើ; បរិវារ : ពួកសេវ័ក ។ ប្រើស្ត្រីជា សេវិកា ។ សេវកជន មនុស្សអ្នកបម្រើ ។ សេវកបុរស បុរសអ្នកចាំទទួលការបម្រើ (ក្នុងក្រសួងឬក្រុមរាជការនីមួយ) ។*

*"ម្នាលកូនសម្លាញ់ទាំងឡាយ ចូរអ្នកទាំងឡាយមកអង្គុយ ស្ដាប់រាជវសតិធម៌ (ច្បាប់សម្រាប់នៅក្នុងរាជត្រកូល) របស់យើង ដែលជាច្បាប់សម្រាប់បុរសចូលទៅកាន់រាជត្រកូល រមែងបានយស" ។*

"ន ហិ រាជកុលំ បត្តោ, អញ្ញាតោ លភតេ យសំ;
នាសូរោ នាបិ ទុម្មេធោ, នប្បមត្តោ កុទាចនំ។
យទាស្ស សីលំ បញ្ញញ្ច, សោចេយ្យំ ចាធិគច្ឆតិ;
អថ វិស្សសតេ ត្យម្ហិ, គុយ្ហញ្ចស្ស ន រក្ខតិ" ។

*"រាជសេវក:[៥៨] ដែលចូលទៅកាន់រាជត្រកូល (មានគុណសម្បត្តិ) មិនប្រាកដ រមែងមិនបានយសទេ ឯរាជសេវក:មានដូចជា មិនត្រូវជាអ្នកក្លៀវក្លាពេក មិនត្រូវជាអ្នកខ្លាចពេក មិនត្រូវធ្វេសប្រហែស ក្នុងកាលណាឡើយ ។ ព្រះរាជាជ្រាបច្បាស់នូវអាចារសម្បត្តិ[៥៩] និងសេចក្ដីចេះដឹង ព្រមទាំងសេចក្ដីស្អាតរបស់រាជសេវក:នោះ ក្នុងកាលណា ព្រះរាជាក៏រមែងស្និទ្ធស្នាលចំពោះ*

---

[៥៨] (ន.) (បា.) *ខ្ញុំរាជការក្នុងព្រះរាជសម្នាក់ ។*

[៥៩] (ន.) (សំ.),(បា.) (--រ៉:) *អាចារសម្បត្តិ ឬ--សម្ប័ទ, --សម្បទា (--ស័ម-ប៉:--) ការបរិបូណ៌ដោយមារយាទល្អ គឺដំណើរមានមារយាទល្អឬត្រឹមត្រូវ ។ អាចារសម្បន្ន (--សំ-ប័ន) អ្នកដែលបរិបូណ៌ដោយមារយាទល្អ (បើស្ត្រីជា អាចារសម្បន្នា អ. ថ. --ស័ម-ប៉ុន-ន៉ា) ។ អាចារសាស្ត្រ ក្បួននិយាយពីអាចារ:; វិទ្យាសាស្ត្រចែងអំពីចរិយា, ឫកពា, សណ្ដាប់ធ្នាប់របស់មនុស្ស ។*

រាជសេវកៈនោះ ក្នុងកាលណោះ ទាំងមិនលាក់នូវអាថ៌កំបាំង (របស់ព្រះអង្គ) នឹងរាជសេវកៈនោះទេ" ។

"តុលា យថា បគ្គហិតា, សមទណ្ឌា សុធារិតា;
អជ្ឈិដ្ឋោ ន វិកម្បេយ្យ, ស រាជវសតឹ វសេ។
តុលា យថា បគ្គហិតា, សមទណ្ឌា សុធារិតា;
សព្វានិ អភិសម្ភោន្តោ, ស រាជវសតឹ វសេ" ។

"រាជសេវកៈដែលព្រះរាជាត្រាស់ប្រើ ក្នុងរាជកិច្ចណាមួយ មិនគប្បីធ្វើរាជកិច្ចនោះឲ្យកម្រើកល្អៀងទេ ត្រូវធ្វើឲ្យដូចជាជញ្ជីងដែលគេលើកឡើងហើយ មានដងស្មើ ទៀងល្អ ។ រាជសេវកៈធ្វើរាជកិច្ចទាំងពួង ដូចជញ្ជីងដែលគេលើកឡើង ហើយមានដងស្មើទៀងល្អ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"ទិវា វា យទិ វា រត្តិំ, រាជកិច្ចេសុ បណ្ឌិតោ;
អជ្ឈិដ្ឋោ ន វិកម្បេយ្យ, ស រាជវសតឹ វសេ។

"រាជសេវកៈ ជាអ្នកឈ្លាសវៃក្នុងរាជកិច្ចទាំងឡាយដែលព្រះរាជាត្រូវប្រើក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ មិនគប្បីធ្វើរាជកិច្ចនោះឲ្យកម្រើក រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"ទិវា វា យទិ វា រត្តិំ, រាជកិច្ចេសុ បណ្ឌិតោ;

សព្វានិ អភិសម្ភោន្តោ,　　ស រាជវសតឹ វសេ។
យោ ចស្ស សុកតោ មគ្គោ,　រញ្ញោ សុប្បដិយាទិតោ;
ន តេន វុត្តោ គច្ឆេយ្យ,　　ស រាជវសតឹ វសេ” ។

“រាជសេវកៈ ជាអ្នកឈ្លាសវៃក្នុងរាជកិច្ចទាំងឡាយ ធ្វើរាជកិច្ចគ្រប់យ៉ាង ក្នុងវេលាថ្ងៃឬក្នុងវេលាយប់ឲ្យសម្រេចដោយរៀបរយ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ ផ្លូវណាដែលគេធ្វើល្អ ចាត់ចែងល្អសម្រាប់ព្រះរាជា រាជសេវកៈដែលព្រះរាជាត្រាស់ហើយ មិនត្រូវដើរទៅតាមផ្លូវនោះ រាជាសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល” ។

“ន រញ្ញោ សទិសំ ភុញ្ជេ,　　កាមភោគេ កុទាចនំ;
សព្វត្ថ បច្ឆតោ គច្ឆេ,　　ស រាជវសតឹ វសេ។
ន រញ្ញោ សទិសំ វត្ថំ,　　ន មាលំ ន វិលេបនំ;
អាកប្បំ សរកុត្តឹ វា,　　ន រញ្ញោ សទិសមាចរេ;
អញ្ញំ ករេយ្យ អាកប្បំ,　　ស រាជវសតឹ វសេ” ។

“រាជសេវកៈ មិនគួរប្រើប្រាស់កាមភោគៈស្មើនឹងព្រះរាជាក្នុងកាលណាឡើយ ត្រូវដើរខាងក្រោយក្នុងកាមគុណគ្រប់យ៉ាង រាជាសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ មិនត្រូវប្រើប្រាស់សំពត់ មិនត្រូវប្រើប្រាស់ផ្កាកម្រង មិនត្រូវប្រើប្រាស់

គ្រឿងលាប ឲ្យដូចរបស់ព្រះរាជា មិនត្រូវប្រព្រឹត្តកិរិយា ឬការ និយាយស្តី ឲ្យដូចព្រះរាជា ត្រូវធ្វើអាកប្បកិរិយាដទៃវិញ រាជ-សេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"កីឡេ រាជា អមច្ចេហិ, ភរិយាហិ បរិវារិតោ;
នាមច្ចោ រាជភរិយាសុ, ភាវំ កុព្វេថ បណ្ឌិតោ ។
អនុទ្ធតោ អចបលោ, និបកោ សំវុតិន្ទ្រិយោ;
មនោបណិធិសម្បន្នោ, ស រាជវសតិំ វសេ" ។

"ព្រះរាជា ទ្រង់ក្រសាលនឹងរាជសេវកៈ មានស្រីស្នំគាល់បម្រើ អាមាត្យជាបណ្ឌិត មិនត្រូវធ្វើសេចក្តីស្និទ្ធស្នាលចំពោះពួកស្រីស្នំ របស់ព្រះរាជាទេ ។ រាជសេវកៈ ជាអ្នកមិនឆ្មើងឆ្មៃ មិនឃ្នើសឃ្នង ជាអ្នកមានប្រាជ្ញាខ្ជាប់ខ្ជួន សង្រួមឥន្ទ្រិយដ៏ល្អ បរិបូណ៌ដោយការ តម្កល់ចិត្ត រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"នាស្ស ភរិយាហិ កីឡេយ្យ, ន មន្តេយ្យ រហោគតោ;
នាស្ស កោសា ធនំ គណ្ហេ, ស រាជវសតិំ វសេ ។

"រាជសេវកៈ មិនត្រូវប្រលែង មិនត្រូវនៅក្នុងទីស្ងាត់ ប្រឹក្សាជាមួយ នឹងពួកស្រីស្នំរបស់ព្រះរាជា មិនត្រូវលួចយកព្រះរាជទ្រព្យអំពី ឃ្លាំងរបស់ព្រះរាជានោះទេ រាជាសេវកៈនោះ ទើបគួរនៅក្នុង រាជត្រកូល" ។

"ន និទ្ទំ ពហុ មញ្ញេយ្យ,　　ន មទាយ សុរំ បិវេ;
នាស្ស ទាយេ មិគេ ហញ្ញេ,　ស រាជវសតឹ វសេ។

*"រាជសេវកៈ មិនគប្បីដេកច្រើន មិនត្រូវផឹកសុរាឲ្យស្រវឹង មិនត្រូវបៀតបៀនពួកម្រឹគដែលទ្រង់ឲ្យអភ័យ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។*

"នាស្ស បីឋំ ន បល្លង្កំ,　　ន កោច្ឆំ ន នាវំ រថំ;
សម្មតោម្ហីតិ អារូហេ,　　ស រាជវសតឹ វសេ។

*"រាជសេវកៈ មិនត្រូវឡើងកាន់តាំង មិនត្រូវឡើងកាន់បល្ល័ង្ក មិនត្រូវឡើងកាន់កៅអី មិនត្រូវឡើងកាន់នាវា ឬកាន់រថរបស់ព្រះរាជា ដោយគិតថា ខ្លួនអញព្រះរាជាប្រោសប្រាណហើយដូច្នេះទេ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។*

"នាតិទូរេ ភជេ រញ្ញោ,　　នច្ចាសន្នេ វិចក្ខណោ;
សម្មុខញ្ចស្ស តិដ្ឋេយ្យ,　　សន្ទិស្សន្តោ សភត្តុនោ។

*"រាជសេវកៈ ជាអ្នកវាងវៃ ត្រូវគាល់ព្រះរាជាក្នុងទីមិនឆ្ងាយពេក មិនជិតពេក គប្បីឋិតនៅល្មមតែព្រះរាជាទតឃើញ ទាំងខ្លួនឯងក៏មើលឃើញព្រះរាជាជាម្ចាស់" ។*

"ន វេ រាជា សខា ហោតិ,　ន រាជា ហោតិ មេថុនោ;

ខិប្បំ កុជ្ឈន្តិ រាជានោ, សូរោកោ(ន)ក្ខីវ យជ្ជិតំ ។

*"រាជសេវកៈគួរគិតថា ព្រះរាជាមិនមែនជាសម្លាញ់របស់អញទេ ព្រះរាជាមិនមែនជាគូកនរបស់អញទេ ធម្មតា ព្រះរាជាទាំងឡាយ រមែងខ្ញាល់ឆាប់ ដូចភ្នែកដែលត្រូវលម្អង មានកន្ទុយស្រូវជាដើម ប៉ះពាល់" ។*

"ន បូជិតោ មញ្ញមានោ, មេធាវី បណ្ឌិតោ នរោ;
ផរុសំ បតិមន្តេយ្យ, រាជានំ បរិសំគតំ" ។

*"ជនជាបណ្ឌិត អ្នកមានប្រាជ្ញា មិនត្រូវសម្គាល់ថា ព្រះរាជាបូជាអញហើយ ក៏ពិតទូលហេតុអាក្រក់ចំពោះព្រះរាជា ដែលយាងមកកាន់បរិស័ទ" ។*

"លទ្ធទ្វារោ លភេ ទ្វារំ, នេវ រាជូសុ វិស្សសេ;
អគ្គីវ សំយតោ តិដ្ឋេ, ស រាជវសតិំ វសេ ។
បុត្តំ វា ភាតរំ វា សំ, សម្បគ្គណ្ហាតិ ខត្តិយោ;
គាមេហិ និគមេហិ វា, រដ្ឋេហិ ជនបទេហិ វា;
តុណ្ហីភូតោ ឧបេក្ខេយ្យ, ន ភណេ ឆេកបាបកំ" ។

*រាជសេវកៈ ទុកជាបានអនុញ្ញាតទ្វារហើយ ត្រូវបានអនុញ្ញាតទ្វារទៀត សឹមចូល មិនត្រូវទុកចិត្តចំពោះព្រះរាជាទាំងឡាយ គប្បី*

ប្រយ័ត្នដូចភ្លើង រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ ព្រះរាជាជាក្សត្រិយ៍ទ្រង់លើកតម្កើងព្រះរាជបុត្រឬក្សត្រិយ៍ ជាបងប្អូនរបស់ព្រះអង្គ ដោយស្រុកឬនិគម ដោយដែន ឬជនបទ រាជសេវកៈត្រូវនៅស្ងៀម រំពឹងមើល មិនត្រូវនិយាយពីគុណឬទោសឡើយ" ។

"ហត្ថារោហេ អនីកដ្ឋេ, រថិកេ បត្តិការកេ;
តេសំ កម្មាវទានេន, រាជា វឌ្ឍេតិ វេតនំ;
ន តេសំ អន្តរា គច្ឆេ, ស រាជវសតឹ វសេ។

"ព្រះរាជាទ្រង់បន្ថែមបៀវត្សរ៍ដល់ពលដំរី ពលរថ ពលថ្មើរជើងទាំងនោះ ដោយការប្រគល់ឲ្យចំពោះការងារ រាជសេវកៈមិនត្រូវធ្វើឲ្យអន្តរាយលាភរបស់ពលទាំងនោះ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"ចាបោវូនុទរោ ធីរោ, វំសោវាបិ បកម្បយេ;
បដិលោមំ ន វត្តេយ្យ, ស រាជវសតឹ វសេ។
ចាបោវូនុទរោ អស្ស, មច្ឆោវស្ស អជិវ្ហា;
អប្បាសី និបកោ សូរោ, ស រាជវសតឹ វសេ" ។

"រាជសេវកៈជាអ្នកប្រាជ្ញ ត្រូវឱនលំទោន ដូចជាដងធ្នូ ត្រូវញាប់ញ័រដូចជាឫស្សី មិនត្រូវប្រព្រឹត្តទទឹងទាស់ទេ រាជសេវកៈនោះ

ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ ត្រូវមានពោះធូរ ដូចបន្ទោះធ្នូ មិនត្រូវមានអណ្ដាតដូចត្រី ត្រូវស៊ីតិច មានប្រាជ្ញារក្សាខ្លួន ក្លៀវក្លា រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"ន ពាឡ្ហំ ឥត្ថឹ គច្ឆេយ្យ, សម្បស្សំ តេជសង្ខយំ;
កាសំ សាសំ ទរំ ពាល្យំ, ខីណមេធោ និគច្ឆតិ ។
នាតិវេលំ បភាសេយ្យ, ន តុណ្ហី សព្វទា សិយា;
អវិកិណ្ណំ មិតំ វាចំ, បត្តេ កាលេ ឧទីរយេ ។

"រាជសេវកៈ មិនត្រូវប៉ះពាល់គប់ស្រី ជាហេតុឲ្យអស់ តេជះខ្លាំងពេកទេ សេវកៈដែលអស់ប្រាជ្ញា រមែងដល់នូវរោគក្អក ហឺត ទុរន់ទុរា មានកម្លាំងថយ ។ រាជសេវកៈ មិនត្រូវនិយាយហួសកម្រិត មិនត្រូវស្ងៀមគ្រប់កាលទាំងពួងទេ ត្រូវពោលពាក្យ មិនរាយរាយ ល្មមប្រមាណក្នុងកាលដែលត្រូវការ" ។

"អក្កោធនោ អសង្ឃដ្ដោ, សច្ចោ សណ្ហោ អបេសុណោ;
សម្ផំ គិរំ ន ភាសេយ្យ, ស រាជវសតឹ វសេ ។
មាតាបេត្តិភរោ អស្ស,កុលេ ជេដ្ឋាបចាយិកោ;
សណ្ហោ សខិលសម្ភាសោ, ស រាជវសតឹ វសេ" ។

"រាជសេវកៈ គប្បីជាអ្នកមិនក្រោធ មិនបៀតបៀនគេ មានពាក្យសច្ចៈ ផ្អែមល្ហែម មិនញុះញង់ មិននិយាយពាក្យឥតប្រយោជន៍

រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ ត្រូវចិញ្ចឹមមាតាបិតា ត្រូវមានសេចក្ដីគោរពចំពោះបុគ្គលជាធំក្នុងត្រកូល មានវាចាផ្អែមល្ហែម ពោលពាក្យម៉ត់ហ្មង រាជសេវកៈ ទើបគួរនៅក្នុងរាជត្រកូល" ។

"វិនីតោ សិប្បវា ទន្តោ, កតត្តោ និយតោ មុទុ;
អប្បមត្តោ សុចិ ទក្ខោ, ស រាជវសតិំ វសេ។

"រាជសេវកៈ ត្រូវមានសណ្ដាប់ធ្នាប់ មានសិល្បសាស្ត្រ មានឥន្ទ្រិយទូន្មានហើយ មានខ្លួនចេះស្ទាត់ហើយ ជាអ្នកនឹងនួន មានអធ្យាស្រ័យទន់ភ្លន់ មិនធ្វេសប្រហែស ជាអ្នកស្អាត ទាំងឈ្លាសវៃ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"និវាតវុត្តិ វុឌ្ឍេសុ, សប្បតិស្សោ សគារវោ;
សុរតោ សុខសំវាសោ, ស រាជវសតិំ វសេ។

"រាជសេវកៈ ត្រូវមានសេចក្ដីប្រព្រឹត្តឱនលំទោន កោតក្រែងគោរព ចំពោះបុគ្គលចម្រើនដោយវ័យជាដើម ជាអ្នកស្លូតត្រង់ នៅរួមជាសុខ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"អារកា បរិវជ្ជេយ្យ, សហិតុំ បហិតំ ជនំ;
ភត្តារញ្ញេវុទិក្ខេយ្យ, ន ច អញ្ញស្ស រាជិនោ" ។

"រាជសេវកៈ គប្បីវៀរឲ្យឆ្ងាយចាកជនដែលព្រះរាជាជទែបញ្ជូនមកដើម្បីការស្ងាត់កំបាំង គប្បីរំពៃមើលចំពោះព្រះរាជាជាម្ចាស់របស់ខ្លួន មិនត្រូវនិយាយចំពោះព្រះរាជាជទៃទេ" ។

"សមណេ ព្រាហ្មណេ ចាបិ, សីលវន្តេ ពហុស្សុតេ;
សក្កច្ចំ បយិរុបាសេយ្យ, ស រាជវសតឹ វសេ។
សមណេ ព្រាហ្មណេ ចាបិ, សីលវន្តេ ពហុស្សុតេ;
សក្កច្ចំ អនុវាសេយ្យ, ស រាជវសតឹ វសេ។

"រាជសេវកៈ គប្បីគប់រកចំពោះសមណៈនិងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូតដោយគោរព រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ គួរប្រព្រឹត្តតាមពួកសមណៈ និងព្រាហ្មណ៍ អ្នកមានសីលជាពហុស្សូត ដោយគោរព រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"សមណេ ព្រាហ្មណេ ចាបិ, សីលវន្តេ ពហុស្សុតេ;
តប្បេយ្យ អន្នបានេន, ស រាជវសតឹ វសេ។
សមណេ ព្រាហ្មណេ ចាបិ, សីលវន្តេ ពហុស្សុតេ;
អាសជ្ជ បញ្ញេ សេវេថ, អាកង្ខំ វុទ្ធិមត្តនោ" ។

"រាជសេវកៈ គួរញ៉ាំងសមណៈ និងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូតឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក រាជសេវកៈនោះ

*ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ កាលបើប្រាថ្នាសេចក្ដីចម្រើនដល់ខ្លួនគប្បីចូលទៅគប់រកសមណៈនិងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូត ជាបណ្ឌិត" ។*

"ទិន្នបុព្វំ ន ហាបេយ្យ, ទានំ សមណព្រាហ្មណេ;
ន ច កិញ្ចិ និវារេយ្យ, ទានកាលេ វណិព្វកេ ។

*"រាជសេវកៈ មិនត្រូវញ៉ាំងទានដែលព្រះរាជាធ្លាប់ព្រះរាជទានដល់សមណៈនិងព្រាហ្មណ៍ ឲ្យសាបសូន្យ ទាំងមិនគួរឃាត់វត្ថុណាមួយចំពោះពួកស្មូម ក្នុងកាលជាទីព្រះរាជទានឡើយ" ។*

"បញ្ញវា ពុទ្ធិសម្បន្នោ, វិធានវិធិកោវិទោ;
កាលញ្ញូ សមយញ្ញូ ច, ស រាជវសតឹ វសេ។

*"រាជសេវកៈ ជាអ្នកមានប្រាជ្ញាបរិបូណ៌ ដោយឧបាយ ជាអ្នកឆ្លៀវឆ្លាសក្នុងវិធីចាត់ចែង ជាអ្នកដឹងកាលធ្វើបុណ្យ ដឹងសម័យប្រកបការងារ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។*

"ឧដ្ឋាតា កម្មធេយ្យេសុ, អប្បមត្តោ វិចក្ខណោ;
សុសំវិហិតកម្មន្តោ, ស រាជវសតឹ វសេ" ។

*"រាជសេវកៈ ជាអ្នកខ្នះខ្នែង មិនប្រមាទ ឈ្លាសវៃ ចាត់ចែងការងារដ៏ល្អក្នុងក្រសួងការងារទាំងឡាយ ត្រូវមានសេចក្ដីព្យាយាម ចាត់*

ចែងរាជកិច្ចឲ្យប្រព្រឹត្តទៅដោយស្រួល រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល” ។

“ខលំ សាលំ បសុំ ខេត្តំ, គន្តា ចស្ស អភិក្ខណំ;
មិតំ ធញ្ញំ និធាបេយ្យ, មិតំវ បាចយេ ឃរេ។
បុត្តំ វា ភាតរំ វា សំ, សីលេសុ អសមាហិតំ;
អនង្គវា ហិ តេ ពាលា, យថា បេតា តថេវ តេ;
ចោឡញ្ច នេសំ បិណ្ឌញ្ច, អាសីនានំ បទាបយេ។

“រាជសេវកៈ គួរទៅត្រួតត្រាមើលលានស្រូវ រោងចិញ្ចឹមសត្វ និងស្រែចម្ការរបស់ព្រះរាជា ឲ្យរឿយ ៗ គប្បីទុកដាក់ស្រូវដែលវាល់ហើយផង ឲ្យគេចម្អិនអង្ករដែលវាល់ហើយក្នុងផ្ទះផង ។ មិនត្រូវលើកតម្កើងកូន ឬបងប្អូនរបស់ខ្លួន ដែលមិនតាំងនៅក្នុងសីលាចារវត្ត ព្រោះថា ជនទាំងនោះជាមនុស្សពាល មិនឈ្មោះថាជាអវយវៈរបស់ខ្លួនទេ ជនទាំងនោះ ទុកដូចជាមនុស្សស្លាប់ហើយ ។ តែថា ត្រូវឲ្យសំពត់និងដុំបាយដល់ជនទាំងនោះដែលមកអង្គុយជិតហើយ” ។

“ទាសេ កម្មករេ បេស្សេ, សីលេសុ សុសមាហិតេ;
ទក្ខេ ឧដ្ឋានសម្បន្នេ, អាធិបច្ចម្ហិ ឋាបយេ” ។

"គប្បីតម្កល់ពួកបុរសជាទាសកម្មករ ដែលជាអ្នកខ្ជាប់ខ្ជួនល្អ ក្នុងសីលាចារវត្ត ជាអ្នកឈ្លាសវៃ បរិបូណ៌ដោយសេចក្តីឃ្មាតខ្មី ក្នុងទីជាអធិបតីក្នុងការងារ" ។

"សីលវា ច អលោលោ ច, អនុរក្ខោ ច រាជិនោ;
អាវី រហោ ហិតោ តស្ស, ស រាជវសតឹ វសេ។

"រាជសេវកៈត្រូវមានសីល មិនលោភ ជាអ្នកប្រព្រឹត្តតាមព្រះរាជា បូជាគុណដល់ព្រះរាជា ទាំងក្នុងទីចំពោះព្រះភក្ត្រ និងទីកំបាំងព្រះភក្ត្រ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល" ។

"ឆន្ទញ្ញូ រាជិនោ ចស្ស, ចិត្តដ្ឋោ អស្ស រាជិនោ;
អសង្កុសកវុត្តិស្ស, ស រាជវសតឹ វសេ ។
ឧច្ឆាទយេ ច ន្ហាបយេ, ធោវេ បាទេ អធោសិរំ;
អាហតោបិ ន កុប្បេយ្យ, ស រាជវសតឹ វសេ" ។

"រាជសេវកៈ ជាអ្នកស្គាល់បំណងរបស់ព្រះរាជានោះផង តាំងនៅដូចព្រះហឫទ័យរបស់ព្រះរាជានោះផង ជាអ្នកមិនប្រព្រឹត្តទទឹងទាស់នឹងព្រះរាជានោះផង រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ គប្បីឱនក្បាលលាងព្រះបាទរបស់ព្រះរាជា ក្នុងកាលជាទីទ្រង់ព្រះពស្ត្រ ឬក្នុងកាលជាទីស្រង់ព្រះគង្គា សូម្បី

ព្រះរាជាទ្រង់ខ្ញាល់ ក៏មិនគប្បីខឹងតបវិញទេ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល” ។

“កុម្ភម្បញ្ជលិំ កយិរា, ចាជញ្ចាបិ បទក្ខិណំ;
កិមេវ សព្វកាមានំ, ទាតារំ ធីរមុត្តមំ ។

“ប៉ុនអម្បាលបុរសប្រាថ្នាសេចក្តីចម្រើន គង់ធ្វើអញ្ជលីចំពោះក្អមទឹក ឬធ្វើបទក្សិណចំពោះបក្សីក្អែកបាន ទម្រាំព្រះរាជាជាបណ្ឌិតខ្ពង់ខ្ពស់ ព្រះអង្គប្រទានសេចក្តីប្រាថ្នាគ្រប់យ៉ាង បុគ្គលមិនគប្បីនមស្ការ ដូចម្តេចនឹងបាន” ។

“យោ ទេតិ សយនំ វត្ថំ, យានំ អាវសថំ ឃរំ;
បជ្ជុន្នោរិវ ភូតានិ, ភោគេហិ អភិវស្សតិ ។

“ព្រះអង្គប្រទានទីដេក សំពត់ យាន និងផ្ទះសម្រាប់សម្នាក់អាស្រ័យ ទ្រង់បង្អុរភោគសម្បទ ដូចមេឃ បង្អុរភ្លៀងដល់ពួកសត្វ” ។

“ឯសយ្យោ រាជវសតិ, វត្តមានោ យថា នរោ;
អារាធយតិ រាជានំ, បូជំ លភតិ ភត្តុសុ” ។

“ម្នាលកូនសម្លាញ់ទាំងឡាយ នេះជារាជវសតិធម៌ ដែលនរជនគួរគប្បីប្រព្រឹត្តតាមព្រះរាជា រមែងប្រទានការប្រោសប្រាណនឹងរមែងបានការបូជាអំពីចៅហ្វាយនាយទាំងឡាយផង” ។

វិធុរបណ្ឌិត អ្នកមានធុរៈរកបុគ្គលស្មើពុំបាន លោកបានសម្ដែងនូវរាជ-វសតិធម៌ តាមលំនាំព្រះពុទ្ធអង្គ ដោយប្រការយ៉ាងនេះ ។

រាជវសតិកណ្ឌ ចប់ ។

## វិធុរបណ្ឌិតលាព្រះមហាក្សត្រជាគ្រាចុងក្រោយ

កាលដែលវិធុរបណ្ឌិត ប្រៀនប្រដៅនូវកូនប្រពន្ធ ញាតិមិត្រសម្លាញ់យ៉ាងនេះ ថ្ងៃទី ៣ ក៏ឈានមកដល់ ។ គាត់ដឹងគម្រប់ថ្ងៃមកដល់ហើយ គាត់បានងូតទឹកតាំងពីព្រលឹម បរិភោគភោជនមានរសឆ្ងាញ់ផ្សេង ៗ រួចជាស្រេចហើយ ក៏ធ្វើដំណើរដោយមានពួកញាតិជាបរិវារឆ្ពោះទៅកាន់រាជនិវេសន៍[៦០] ក្នុងគោលបំណងក្រាបទូលសូមសេចក្ដីអនុញ្ញាតអំពីព្រះមហាក្សត្រ ន្ទាលនឹង[៦១]ទៅជាមួយនឹងមាណព ។ លុះដល់ហើយ វិធុរបណ្ឌិត អ្នកមានប្រាជ្ញាវាងវៃ ថ្វាយបង្គំព្រះបាទាព្រះមហាក្សត្រដោយត្បូង ធ្វើប្រទក្សិណព្រះអង្គ ផ្គងអញ្ជលីក្រាបបង្គំទូលព្រះរាជាថា ៖

"អយំ មំ មាណវោ នេតិ, កត្តុកាមោ យថាមតិ;
ញាតីនត្ថំ បវក្ខាមិ, តំ សុណោហិ អរិន្ទម។

---

[៦០] (ន.) (បា.) (និវេសន) ទីសម្រាប់នៅអាស្រ័យជានិច្ច; ច្រើនប្រើជា (រ. ស.) : ព្រះរាជនិវេសន៍ គឺព្រះរាជដំណាក់ ។

[៦១] (និ.) ដើម្បីនឹង, ប្រយោជន៍នឹង, នឹងបាន, ប្រញាប់នឹង : នាំគ្នាអាស្រ័យបាយឲ្យឆាប់បន្តិចទៅ, រួចហើយន្ទាលនឹងចាប់ធ្វើការតទៅទៀត; ថ្ងៃកាន់តែល្ងាចណាស់ហើយ, យើងខំប្រឹងបង្ហើយការហ្នឹងឲ្យហើយស្រេចទៅ ន្ទាលនឹងទៅផ្ទះ ។

"បពិត្រព្រះអង្គជាអ្នកបង្ក្រាបសត្រូវ មាណពនេះ មានប្រាថ្នាធ្វើតាមអធ្យាស្រ័យ នឹងនាំខ្ញុំព្រះអង្គទៅ ប៉ុន្តែមុននឹងខ្ញុំព្រះអង្គចាកចេញទៅជាមួយនឹងមាណពនេះ ខ្ញុំព្រះអង្គ សូមរាជានុញ្ញាតនិយាយពាក្យជាប្រយោជន៍ដល់ពួកញាតិ សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យនោះ ដោយព្រះទ័យអនុគ្រោះ" ។

"បុត្តេ ច មេ ឩទិក្ខេសិ, យញ្ច មញ្ញំ ឃរេ ធនំ;
យថា បេច្ច ន ហាយេថ, ញាតិសង្ឃោ មយី គតេ។

"បពិត្រព្រះអង្គ សូមព្រះអង្គទ្រង់ទតមើលនូវកូននិងទ្រព្យទាំងឡាយដទៃក្នុងផ្ទះរបស់ខ្ញុំព្រះអង្គផង កាលបើខ្ញុំព្រះអង្គទៅហើយ សូមកុំឲ្យពួកញាតិវិនាស ក្នុងកាលជាខាងក្រោយឡើយ"។

"យថេវ ខលតី ភូម្យា, ភូម្យាយេវ បតិដ្ឋតិ;
ឯវេតំ ខលិតំ មយ្ហំ, ឯតំ បស្សាមិ អច្ចយំ" ។

"ប្រសិនបើទូលព្រះបង្គំមានសេចក្តីភ្ញាំងភ្លាត់ ទូលព្រះបង្គំ នឹងឃើញកំហុសនោះវិញ ដូចជាបុរសភ្លាត់ដួលលើផែនដី ហើយឈរស៊ប់លើផែនដីវិញ" ។

ទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ព្រះរាជាបំភ្លឺថា ៖

"នៃបណ្ឌិត ដំណើរទៅរបស់អ្នក ធ្វើឲ្យយើងមានការខ្វល់ខ្វាយ

ក្នុងព្រះទ័យណាស់ យើងគប្បីប្រើល្បិចហៅមាណពមកសម្លាប់ហើយបិទបាំងដោយកន្ទេលផែង ទុំះទើបគាប់ចិត្តដល់យើង" ។

រួចទ្រង់បន្តពោលថា ៖

"សក្កា ន គន្តុំ ឥតិ មយ្ហ ហោតិ, ឆេត្វា វធិត្វា ឥធ កាតិយានំ;
ឥធេវ ហោហី ឥតិ មយ្ហ រុច្ចតិ, មា ត្វំ អគា ឧត្តមភូរិបញ្ញា" ។

"ម្នាលមាណព អ្នកមិនគួរទៅទេ ខ្ញុំអនុញ្ញាតឲ្យអ្នកកាប់សម្លាប់មាណពកច្ចាយនៈនៅក្នុងទីនេះចុះ ម្នាលបណ្ឌិតមានប្រាជ្ញាឧត្តមដូចផែនដី អ្នកកុំទៅឡើយ" ។

ព្រះដូច្នោះ មហាសត្តបាននិយាយថា ៖

"បពិត្រព្រះសម្មតិទេព អធ្យាស្រ័យរបស់ព្រះអង្គ មានសភាពបែបនោះ វាជារឿងអយុត្តិធម៌ណាស់ ចំពោះខ្លួនព្រះអង្គ" ។

រួចលោកបានបន្តពោលថា ៖

"មា ហេវធម្មេសុ មនំ បណីទហិ, អត្ថេ ច ធម្មេ ច យុត្តោ ភវស្សុ;
ធិរត្ថុ កម្មំ អកុសលំ អនរិយំ, យំ កត្វា បច្ឆា និរយំ វជេយ្យ។
នេវេស ធម្មោ ន បុនេត កិច្ចំ, អយិរោ ហិ ទាសស្ស ជនិន្ទ ឥស្សរោ;
ឃាតេតុំ ឈាបេតុំ អថោបិ ហន្តុំ, ន ច មយ្ហ កោធត្ថិ វជាមិ ចាហំ"។

"សូមព្រះអង្គកុំតម្កល់ព្រះហឫទ័យ ក្នុងភាពមិនមែនជាធម៌ សូមព្រះអង្គប្រកបក្នុងប្រយោជន៍ផង ក្នុងធម៌ផង ថ្វីយ[៦២]បុគ្គលធ្វើកម្មណា ហើយទៅកាន់នរកក្នុងកាលខាងក្រោយ កម្មនោះជាអំពើអកុសលមិនប្រសើរ ។ បពិត្រព្រះអង្គធំជាងជន ព្រោះថា ធម្មតាម្ចាស់ជាអ្នកធំរបស់ទាសៈ មានចិត្តចង់សម្លាប់ ចង់ដុតរោល បៀតបៀនក៏បាន តែនេះមិនមែនជាធម៌របស់បុរាណបណ្ឌិតទេ ទាំងមិនមែនជាកិច្ចគួរប្រព្រឹត្តឡើយ សេចក្ដីក្រោធនៃខ្ញុំព្រះអង្គចំពោះមាណព សូម្បីតែបន្តិចបន្តួច ក៏មិនមានដែរ តាំងពីកាលព្រះរាជទានដល់គេហើយ គួរណាស់តែព្រះអង្គអត់សង្កត់ព្រះទ័យ នេះទើបជាការត្រឹមត្រូវ ខ្ញុំព្រះអង្គសូមលាព្រះនរិន្ទហើយ" ។

មហាសត្ត លុះបានពោលយ៉ាងនេះ លោកបន្តផ្ដល់នូវដំបូន្មានដល់ពួកស្រីស្នំនឹងព្រះមហាក្សត្រផង ពួកកូនប្រពន្ធខ្លួនឯងផង រាជបរិស័ទផង ។ នាកាលជនទាំងនោះ កំពុងតែយំសោកបោកខ្លួន រងើះរងោះខ្លួនប្រាណ ឈរទប់ខ្លួនមិននឹង មហាសត្តលោកក៏បានចាកចេញអំពីរាជនិវេសន៍ ។ អ្នកនគរទាំងមូល បានប្រឹក្សាគ្នាដូច្នេះ "ឮថា លោកបណ្ឌិត នឹងទៅជាមួយនឹងមាណព តោះយើងទៅមើលគាត់" ។ ដូច្នេះ

[៦២] (ឧ.) សូរចេញពីមាត់តាមក្រោយទឹកមាត់ដែលស្ដោះមកដោយសម្ដែងអាការមើលងាយ, បញ្ឆោះឬតូចចិត្ត, ទាស់ចិត្ត, ស្ដាយក្រោយ : ថ្វីយ ! អញស្អប់មុខណាស់ !; ថ្វីយ ! ខូចការអស់ ។

ហើយ ពួកគេបានទៅមើលមហាសត្តនៅឯព្រះលានហ្លួង ។ នៅគ្រា នោះ មហាសត្តលួងលោមពួកគេ ផ្តល់ឱវាទដល់ពួកគេថា ៖

"អ្នកទាំងឡាយ កុំព្រួយបារម្ភអ្វីឡើយ សង្ខារទាំងឡាយទាំងពួង មិនទៀងទេ សរីរៈមិនឋិតថេរចីរកាលទេ ធម្មតាយសសក្តិ តែង មានការបាត់បង់ជាទីបំផុត មួយវិញទៀតសោត អ្នកទាំងឡាយ ចូរជាបុគ្គលមិនប្រហែសធ្វេស ក្នុងបុណ្យទាំងឡាយ មានទាន ជាដើម" ។

និយាយដូច្នេះរួច ព្រះមហាសត្តប្រាប់ឲ្យពួកគេត្រឡប់ទៅវិញ ហើយ លោកដើរឆ្ពោះមុខទៅគេហដ្ឋានរបស់ខ្លួន ។ ក្នុងខណៈនោះ ធម្មបាល កុមារ គេមានបងប្អូនប្រុសចោមរោមជាបរិវារ ចេញទៅក្នុងគោល បំណងថានឹងធ្វើនូវការស្វាគមន៍ ដល់ឪពុក ក៏ឈរនៅទ្រឹងទល់មុខនឹង ឪពុក ដែលគាត់កំពុងតែចូលមកដែរ ត្រង់ទ្វារនៃនិវេសន៍ ។ ព្រះមហា-សត្តលោតែឃើញកូនធម្មបាលកុមារភ្លាម ទប់ជំហរខ្លួនពុំបានទេ ស្ទុះ យ៉ាងរហ័សចូលទៅផ្តេកផ្តួបកូនជាប់ដើមទ្រូង មានព្រះនេត្រពេញ ដោយទឹកភ្នែក ឱបរឹតធម្មបាលកុមារជាបុត្រច្បង លុះបន្ទោបង់សេចក្តី ក្រវល់ក្រវាយក្នុងហឫទ័យហើយ ទើបលោកចូលទៅកាន់និវេសន៍ ។

ក្នុងផ្ទះរបស់មហាសត្ត មានកូនប្រុស ១.០០០ នាក់ កូនស្រី ១.០០០ នាក់ ភរិយា ១.០០០ នាក់ វណ្ណទាសី ៧០០ នាក់ ក្រៅពីនោះ

សុទ្ធតែទាសី ទាសៈ កម្មករ ញាតិ មិត្រសម្លាញ់ជាដើម ដេកបម្រះ នទៀលក្នុងលំនៅនោះ ដូចជាដើមរាំងត្រូវខ្យល់បក់បោក ។ និវេសន៍ទាំងមូលពេញណែនឥតសល់ចន្លោះ ហាក់ដូចជាព្រៃសាលវ័នត្រូវខ្យល់ផាត់បក់បោក ។ ស្ត្រីជាប្រពន្ធ ១.០០០ នាក់ និងទាសី ៧០០ នាក់ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញ និងពួកព្រាហ្មណ៍ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ពួកអ្នកជនបទ ពួកអ្នកនិគម មកជួបជុំគ្នាផ្គងដៃ ខ្សឹកខ្សួល កន្ទក់កន្ទេញ ក្នុងលំនៅនៃវិធុរបណ្ឌិត ហេតុអ្វីបានជាលោកលះបង់ចោលពួកយើង ។

មហាសត្ត បានលួងលោមមហាជនទាំងនោះ បានធ្វើនូវកិច្ចទាំងឡាយមិនមានសេសសល់ក្នុងផ្ទះ ទូន្មាននូវជនខាងក្នុងផង នូវជនខាងក្រៅផង ប្រាប់នូវការណ៍ទាំងពួងដែលគួរ ប្រាប់នូវទ្រព្យក្នុងផ្ទះ កំណប់ និងការឲ្យបុល រួចទៅកាន់សម្នាក់របស់បុណ្ណកយក្ស ប្រាប់នូវកិច្ចការសម្រេចរបស់ខ្លួនថា ៖

"អវសី តុវំ មយ្ហ តីហំ អគារេ, កតានិ កិច្ចានិ ឃរេសុ មយ្ហំ;
អនុសាសិតា បុត្តទារា មយា ច, ករោម កច្ចាន យថាមតិំ តេ" ។

"អ្នកបានស្នាក់នៅក្នុងផ្ទះរបស់ខ្ញុំអស់ ៣ ថ្ងៃហើយ កិច្ចក្នុងផ្ទះខ្ញុំបានធ្វើហើយ ទាំងបុត្រនិងភរិយា ខ្ញុំក៏បានប្រៀនប្រដៅហើយ អ្នកចូរធ្វើកិច្ចទាំងឡាយ តាមអធ្យាស្រ័យរបស់អ្នកចុះ" ។

បុណ្ណកយក្ស ពោលថា ៖

"សចេ ហិ កត្តេ អនុសាសិតា តេ, បុត្តា ច ទារា អនុជីវិនោ ច;
ហន្ទេហិ ទានី តរមានរូបោ, ធីយោ ហិ អន្ធាបិ អយំ បុរត្ថា។
អជម្ហិតោវ គណ្ហាហិ, អាជានេយ្យស្ស វាលធឹ;
ឥទំ បច្ឆិមកំ តុយ្ហំ, ជីវលោកស្ស ទស្សនំ" ។

"បពិត្រអ្នកជាអាមាត្យ បើអ្នកបានប្រៀនប្រដៅបុត្រ ភរិយា និង ពួកជនអ្នកចិញ្ចឹមជីវិតដោយសារហើយ អើ! អ្នកចូរប្រញាប់ ប្រញាល់ មកក្នុងកាលឥឡូវនេះចុះ ព្រោះថា ផ្លូវខាងមុខនេះជា ផ្លូវដាច់ស្រយាល វែងឆ្ងាយ ។ អ្នកកុំភ័យ ចូរចាប់គោងកន្ទុយសេះ អាជានេយ្យចុះ នេះជាការឃើញនូវជីវលោក ជាទីបំផុតរបស់ អ្នក" ។

គ្រានោះ មហាសត្តនិយាយនឹងបុណ្ណកយក្សថា ៖

"សោហំ កិស្ស នុ ភាយិស្សំ, យស្ស មេ នត្ថិ ទុក្កដំ;
កាយេន វាចា មនសា, យេន គច្ឆេយ្យ ទុគ្គតឹ" ។

"បុគ្គលទៅកាន់ទុគ្គតិដោយអំពើណាដែលកើតអំពីកាយវាចាចិត្ត អំពើអាក្រក់នោះរបស់ខ្ញុំ មិនមានទេ ខ្ញុំនឹងខ្លាចអ្វីចំពោះអំពើនេះ"

មហាសត្វ បានបន្លឺនូវសីហនាទយ៉ាងនេះ លោកមិនតក់ស្លុត ឥត មានភ័យខ្លាច បីដូចកេសរសីហៈ បានតាំងអធិដ្ឋានបារមីជាប្រធានថា ៖

"សូមសាដកនេះ កុំរដោះដោយសារសេចក្ដីមិនគាប់ចិត្តរបស់ អញឡើយ" ។

លោកបានស្លៀកយ៉ាងខ្ជាប់ខ្ជួន ទាញកន្ទុយសេះមកចាប់ ដោយដៃទាំងពីរយ៉ាងមាំ និងយកជើងទាំងពីរកៀវរឹបភ្លៅសេះហើយ ប្រាប់មាណពថា ៖

"នែមាណព ខ្ញុំចាប់កន្ទុយរួចហើយ ចូរអ្នកទៅតាមសេចក្ដីគាប់ ចិត្តចុះ" ។

រំពេចនោះឯង បុណ្ណកយក្សឲ្យសញ្ញាដល់សេះសិន្ធពសម្រេចពី ចិត្ត ។ សេះសិន្ធពនោះ នាំយកលោកបណ្ឌិតស្ទុះហោះទៅឰដ៏អាកាស វេហាស៍ ឥតប៉ះទង្គិចនឹងមែកឈើឬភ្នំអ្វីទេ រួចសេះនោះក៏ចូលទៅកាន់ កាឡាគិរីបព៌ត ដោយឆាប់រហ័ស ។

បានឮថា បុណ្ណកយក្សមានគំនិតថា "អញមិនទៅឆ្ងាយទេ អញ នឹងបោកវិធុរបណ្ឌិតនេះត្រង់ដើមឈើឬត្រង់ភ្នំឲ្យស្លាប់ ក្នុងដែនដីព្រៃ ហិមពាន្តតែម្ដង យកសាច់បេះដូងគេ រួចចោលសាកសពទៅក្នុងចន្លោះ ភ្នំ ទ្អាលនឹងទៅកាន់ភពនាគ" ។ គិតដូច្នេះហើយ បុណ្ណកៈនោះមិន

បានប្រហារលោកត្រង់ដើមឈើឬភ្នំទេ គេបានបំបោលសេះទៅតាមចន្លោះព្រៃឈើ ឬភ្នំនោះវិញ ដើម្បីឲ្យពោធិសត្វបោកក្បាលទង្គិចឈើឬភ្នំស្លាប់ ។ ប៉ុន្តែដោយអានុភាពនៃព្រះមហាសត្វ ឈើផង ភ្នំផង បានថយម្ខាង ១ ហត្ថ ៗ អំពីសរីរៈរបស់ព្រះមហាសត្វ ។ បុណ្ណកៈបែរងាកមើលមុខមហាសត្វ ថាតើវាងាប់ឬអត់ស្រាប់តែឃើញមុខវិធុរបណ្ឌិតថ្លាដូចកញ្ចក់មាស នឹកក្នុងចិត្តថា "យីអើ ! អានេះ វាមិនងាប់យ៉ាងនេះសោះ" ក៏វាយបំផាយសេះឲ្យរត់សព្វព្រៃហិមពាន្ត គ្រវាត់វិធុរបណ្ឌិតត្រង់ដើមឈើនិងភ្នំ ដល់ទៅ ៣ ដងមួយសាទៀត បើទោះបីបោកគ្រវាត់យ៉ាងនេះក៏ដោយ ដើមឈើនិងភ្នំ ថយចេញដូចមុនកាន់តែឆ្ងាយលើសដើម ។ ចំណែកមហាសត្វយើង លោកមានកាយលំបាកដែរ ។ គ្រានោះ បុណ្ណកៈកើតក្រោធថា "អានេះវាមិនងាប់សោះ ឥឡូវនេះអញនឹងធ្វើកម្ទេចវាឲ្យល្អិតជាផេះផង់ ឰដ៏គំនរខ្យល់ម្តង" ហើយគេស្ទុះទៅកាន់គំនរខ្យល់ជាន់ទី ៧ ។ ដោយអានុភាពនៃពោធិសត្វ គំនរខ្យល់បែកជាពីរ ធ្វើឱកាសសម្រាប់ពោធិសត្វ ។ បន្ទាប់មក គេប្រហារដោយខ្យល់វេរម្ភវាត សូម្បីខ្យល់វេរម្ភ[៦៣]វាត មានសូរដូចសូររន្ទះបាញ់ ១០០.០០០ ដង ក៏ឲ្យឱកាសដល់ពោធិសត្វដែរ ។ បុណ្ណកៈនោះ កាលឃើញនូវការ

---

[៦៣] (ន.) (បា.) (--រ័ម-ភៈ--) ខ្យល់វល់គឺខ្យល់ដែលបក់ពីទិសផ្សេង ៗ ប្រសព្វគ្នា; ខ្យល់កំបុតត្បូង ។

មិនមានអន្តរាយចំពោះវិធុរបណ្ឌិត ក៏នាំវិធុរបណ្ឌិតនោះឡើងទៅភ្នំកាឡៈ ។

## ស្តេចធនញ្ជ័យល្បួងលោមមហាជន

ក្នុងកាលបុណ្ណកៈចាប់មហាសត្តយកទៅយ៉ាងនេះ កូននិងប្រពន្ធជាដើមរបស់បណ្ឌិត នាំគ្នាទៅកាន់លំនៅឋានរបស់បុណ្ណកៈ មើលទៅមិនឃើញមហាសត្តនៅទីនោះ ពួកគេម្នាក់ ៗ ហាក់ដូចមនុស្សកំបុតជើង ដួលបម្រះនទៀលទៅមកខ្សឹកខ្សួល ដោយមានសំឡេងខ្លាំង ៗ ។ ស្ត្រីជាប្រពន្ធ ១.០០០ នាក់ និងទាសី ៧០០ នាក់ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញ និងពួកព្រាហ្មណ៍ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ពួកអ្នកជនបទ ពួកអ្នកនិគម មកជួបជុំគ្នា ផ្គងដៃ ខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍ នាំវិធុរបណ្ឌិតទៅហើយ តើវិធុរបណ្ឌិតទៅក្នុងទីណាហ្ន៎ ?

លុះខ្សឹកខ្សួលយ៉ាងនេះហើយ ពួកគេទាំងអស់រួមជាមួយនឹងអ្នកនគរទាំងមូល នាំគ្នាដើរឃំឡោះទៅកាន់ទ្វារព្រះបរមរាជវាំង ។ ព្រះរាជា លោតែឮនូវសំឡេងខ្សឹកខ្សួលដ៏ខ្លាំង ទ្រង់បានបើកសីហបញ្ជរ[៦៤] សួរទៅថា "អ្នកទាំងឡាយ ខ្សឹកខ្សួល ព្រោះហេតុអ្វី ?" គ្រានោះ មនុស្ស

---

[៦៤] (ន.) (សំ.),(បា.) គម្រោង, រាងជ្រៅ, ទ្រង់ទ្រាយ; បង្អួចដែលមានទ្រង់ទ្រាយជារង្វង់;...។ សីហបញ្ជរ បង្អួចដែលមានរង្វង់ស្រដៀងនឹងជំហរនៃសត្វសីហៈ ។

ទាំងឡាយ ក្រាបទូលនូវសេចក្ដីនេះថា "បពិត្រព្រះសម្មតិទេព ពួថា មាណពនោះ មិនមែនជាព្រាហ្មណ៍ទេ គេគឺជាយក្សប្លែងខ្លួនធ្វើជាព្រាហ្មណ៍ មកនាំលោកបណ្ឌិតទៅ, ពួកយើងមិនអាចរស់នៅបានទេប្រសិនណាបើគ្មានលោកបណ្ឌិតនោះ ។ ប្រសិនបើលោកបណ្ឌិត មិនត្រឡប់មកក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃនេះទេ ពួកទូលបង្គំនឹងប្រមូលឧសទាំងរយរទេះ ទាំងពាន់រទេះ បង្កាត់ភ្លើងហើយ ទូលព្រះបង្គំទាំងអស់គ្នានឹងលោតចូលក្នុងភ្លើង ពួកទូលព្រះបង្គំ មិនស្ដាយជីវិតឡើយ ។

## **អំណាត់សម្គាល់**

សូម្បីក្នុងកាលបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ មនុស្សទាំងឡាយអ្នកពោលថា "យើងនឹងចូលភ្លើងស្លាប់" ដូច្នេះ មិនមានឡើយ ។ ឱ! ពោលចំពោះមហាសត្តបានល្អអ្វីម្ល៉េះ អ្នកនគរទាំងឡាយ ។ ព្រះរាជាឮសម្ដីរបស់ពួកគេ ទ្រង់បានលួងលោមថា ៖

"អ្នកទាំងឡាយកុំព្រួយ កុំសោកស្ដាយ, កុំខ្សឹកខ្សួល, បណ្ឌិតសម្ដីពីរោះ នឹងប្រលោមមាណពដោយធម្មកថា ញ៉ាំងគេឲ្យដួលទៀបជើងរបស់ខ្លួន ។ អ្នកទាំងឡាយ ចូរកុំសោកសៅឡើយ ចូរអ្នកទាំងឡាយរីករាយស្រស់ស្រាយឡើងវិញទៅ មិនយូរប៉ុន្មានទេ បណ្ឌិតនឹងមកវិញឆាប់ ៗ " ។

រួចទ្រង់ពោលថា ៖

"បណ្ឌិតជាបុគ្គលឈ្លាសវៃ អាចសម្តែងហេតុជាប្រយោជន៍ និង ហេតុមិនមែនជាប្រយោជន៍ ជាអ្នកមានប្រាជ្ញាឈ្វេងយល់ រមែង ដោះខ្លួនបានដោយឆាប់ អ្នកទាំងឡាយកុំខ្លាចឡើយ បណ្ឌិតនោះ គង់តែនឹងត្រឡប់មកវិញ" ។

អ្នកនគរទាំងឡាយ គ្រាន់តែឮថាវិធុរបណ្ឌិតត្រឡប់មកវិញក្នុង ពេលឆាប់ ៗ ក៏ដកដង្ហើមធូរទ្រូង ក្រាបបង្គំលាព្រះរាជាហើយ ពួកគេ បានចៀសចេញទៅផ្ទះរៀង ៗ ខ្លួន ។

អន្តរបេយ្យាលៈ ចប់ ។

# ជំពូកទី ៤

## វិធុរបណ្ឌិតសម្ដែងសាធុនរធម៌

### បុណ្ណកយក្សបន្លាចវិធុរៈដោយវិធីផ្សេង ៗ

ចំណែកបុណ្ណកយក្ស បានដាក់ព្រះមហាសត្តលើកំពូលភ្នំ ដោយគិតថា "កាលបើវិធុរបណ្ឌិតនេះនៅរស់ សេចក្ដីចម្រើនរបស់អញ នឹងមិនមានឡើយ, អញមិនមានគំនិតសូម្បីបន្តិច ក្នុងការសម្លាប់ជីវិតរបស់វិធុរនេះ ដើម្បីនគរអញឡើយ ប៉ុន្តែអញនឹងសម្លាប់គេយកសាច់បេះដូងទៅកាន់ភពនាគ ថ្វាយដល់ព្រះនាងវិមលាទេវី ហើយអញនឹងយកកូនក្រមុំរបស់ព្រះនាងឈ្មោះឥរន្ទតីទៅកាន់ទេវលោក" ។ បន្ទាប់មកបុណ្ណកៈគិតម្ដងទៀតថា "បើអ៊ីចឹង អញមិនសម្លាប់វិធុរៈនេះ ដោយដៃរបស់ខ្លួនផ្ទាល់ទេ អញនឹងញុំាងគេឲ្យដល់នូវការអស់ជីវិត ដោយការបង្ហាញរូបគួរស្ញើម" គិតដូច្នេះហើយ បុណ្ណកៈបាននិម្មិតនូវរូបយក្សគួរស្ញើម គំរាមព្រះមហាសត្ត មកចាប់ទម្លាក់ព្រះមហាសត្តនោះត្រង់ចន្លោះចង្កូម ធ្វើហាក់ដូចជាចង់ស៊ី ។ រីព្រះមហាសត្ត ពុំមានការព្រឺរោមសូម្បីតែបន្តិចឡើយ ។ បន្ទាប់មក បុណ្ណកៈបានប្លែងខ្លួនធ្វើជាសត្វតោនិងដំរីចុះប្រេងដ៏ធំ ស្ទុះមករកវិធុរបណ្ឌិត ធ្វើដូចជាចង់ត្របាក់ដោយចង្កូមផង ដោយធ្មេញផង ក៏វិធុរៈនោះ មិនមានការភ័យខ្លាចដដែល បុណ្ណកៈនោះ បានប្លែងខ្លួនជាសត្វពស់ដ៏ធំប៉ុនទូកក្ដោងមួយ គ្រាន់តែ

ដកដង្ហើមចេញចូល ក៏លាន់ស្នូរសុសូ ហើយគេមករុំសរីរៈទាំងមូល របស់មហាសត្វ បិតនៅបើកពពារខាងលើ ។ វិធុរបណ្ឌិតនោះ ពុំមាន ការស្រៀវខ្លាចប៉ុនសរសៃសក់ឡើយ ។ តពីនោះ បុណ្ណកៈគិតថា "អញ នឹងដាក់វិធុរៈនេះលើកំពូលភ្នំ ហើយទម្លាក់គេឲ្យខ្ទេចជាល្អងធូលី" គិតដូច្នេះរួច គេបានបណ្ដាលខ្យល់ធំឲ្យក្ដួចឡើងយ៉ាងខ្លាំង ។ ខ្យល់ធំ នោះ ពុំអាចបណ្ដាលសូម្បីត្រឹមតែចុងសក់របស់វិធុរៈឲ្យកក្រើកបន្តិច ឡើយ ។ តពីនោះ បុណ្ណកៈដាក់វិធុរៈលើកំពូលភ្នំទីនោះដដែល គេធ្វើ ជាដំរីឱ្យត្រដុសភ្នំ ឈ្មោះខជ្ជរិក្ខបព៌តឲ្យកក្រើកទៅមក ៗ ។ ដូចគ្នានេះ ដែរ ការនេះពុំអាចញ៉ាំងវិធុរៈឲ្យកក្រើកឃ្លាតចាកទីឈរបានឡើយ ដោយហោចទៅសូម្បីត្រឹមតែចុងសក់ ក៏ឥតកក្រើកផង ។

តពីនោះ បុណ្ណកៈគិតថា "អញនឹងធ្វើឲ្យបេះដូងរបស់វិធុរៈនេះ បែកស្លាប់ ដោយសម្រែកគំហកខ្លាំង" ហើយគេចូលទៅខាងក្នុងភ្នំ ធ្វើ ឲ្យផែនដីនិងមេឃលាន់ស្នូរតែមួយ ទាំងខ្លួនឯងក៏ស្រែកសន្ធាប់យ៉ាង ខ្លាំង ។ ទោះបីជាយ៉ាងនេះក៏ដោយ សេចក្ដីស្រៀវខ្លាចសូម្បីតែបន្តិចពុំ មានដល់វិធុរបណ្ឌិតឡើយ ។ ពិតណាស់ ព្រះមហាសត្វលោកដឹងថា "មនុស្សដែលមកដោយប្លែងភេទជាយក្សក៏ដោយ សីហៈក៏ដោយ ដំរីក៏ ដោយ នាគរាជក៏ដោយ អ្នកបណ្ដាលខ្យល់ធំភ្លៀងខ្លាំងក៏ដោយ អ្នក បណ្ដាលភ្នំឲ្យកក្រើកក៏ដោយ អ្នកដែលចូលទៅខាងក្នុងភ្នំស្រែកគំហក ក៏ដោយ គឺជាមាណពតែមួយ មិនមែនអ្នកផ្សេងទេ" ។ តពីនោះ បុណ្ណកៈ

គិតថា "អញមិនអាចសម្លាប់មាណពនេះ ដោយសេចក្តីព្យាយាមខាងក្រៅបានទេ អញនឹងសម្លាប់គេដោយដៃផ្ទាល់វិញ" ។ គ្រានោះ យក្សបុណ្ណកៈ ដាក់ព្រះមហាសត្តលើកំពូលភ្នំ ហើយគេវិលទៅកាន់ជើងភ្នំជ្រែកខ្លួនចូលទៅក្នុងភ្នំ ប្រៀបដូចជាញាត់អំបោះលឿងទៅក្នុងដុំកែវមណី ហើយគេស្រែកគំរាមសន្ធាប់ឡើងទៅតាមខាងក្នុងភ្នំចាប់ព្រះមហាសត្តត្រង់ជើងយ៉ាងមាំ គ្រវីគ្រវាត់ឲ្យក្បាលចុះក្រោមសំយុងទៅឯអកាស ជាទីដែលស្រឡះល្ហល្ហេវ មិនមានអ្វីឃឹតតោង មិនមានអ្វីប៉ះ ។

វិធុរបណ្ឌិតនោះ ជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ កាលសំយុងចុះទៅក្នុងរណ្តៅជ្រោះ ជាទីមានភ័យដ៏ធំ គួរព្រួចព្រឺរោម ដែលលំបាកនឹងទៅក្រែលែង តែមិនតក់ស្លុត ហើយពោលនឹងបុណ្ណកយក្សយ៉ាងនេះថា ៖

"អរិយាវកាសោសិ អនរិយរូបោ, អសញ្ញតោ សញ្ញតសន្និកាសោ;
អច្ចាហិតំ កម្មំ ករោសិ លុទ្ទំ, ភាវេ ច តេ កុសលំ នត្ថិ កិញ្ចិ ។
យំ មំ បបាតស្មិំ បបាតុមិច្ឆសិ, កោ នុ តវត្ថោ មរណេន មយ្ហំ;
អមានុសស្សេវ តវជ្ជ វណ្ណោ, អាចិក្ខ មេ ត្វំ កតមាសិ ទេវតា ។

"អ្នកជាមនុស្សមិនប្រសើរ តែធ្វើដូចជាប្រសើរ ជាអ្នកមិនសង្រួមតែមានអាការហាក់ដូចជាអ្នកសង្រួម អ្នកធ្វើអំពើអាក្រក់ ឥតប្រយោជន៍ ចំណែកកុសលតិចតួចឥតមានក្នុងចិត្តអ្នកទេ ។

អ្នកចង់ទម្លាក់ខ្ញុំទៅក្នុងរណ្ដៅជ្រោះដោយហេតុណា ប្រយោជន៍ដូចម្ដេចដោយការសម្លាប់ខ្ញុំ នឹងមានដល់អ្នក ដោយហេតុនោះក្នុងថ្ងៃនេះ អ្នកមានភេទដូចជាមិនមែនភេទនៃមនុស្សទេ ចូរអ្នកប្រាប់ខ្ញុំ អ្នកជាទេវតា ឬជាអ្វី ?"

បុណ្ណកៈតបថា ៖

"យទិ តេ សុតោ បុណ្ណកោ នាម យក្ខោ,
រញ្ញោ កុវេរស្ស ហិ សោ សជិព្វោ;
ភូមិន្ធរោ វរុណោ នាម នាគោ, ព្រហា សុចី វណ្ណពលូបបន្នោ។
តស្សានុជំ ធីតរំ កាមយាមិ, ឥរន្ធតី នាម សា នាគកញ្ញា;
តស្សា សុមជ្ឈាយ បិយាយ ហេតុ, បតារយិំ តុយ្ហ វធាយ ធីរ" ។

"ខ្ញុំនេះ ឈ្មោះបុណ្ណកយក្ស ជាអាមាត្យព្រះបាទកុវេរៈ ដែលអ្នកធ្លាប់បានឮហើយ នាគរាជព្រះនាមវរុណៈ ជាអ្នកទ្រទ្រង់ផែនដី មានទំហំនិងកម្ពស់ មានទ្រង់ទ្រាយដ៏ស្អាត បរិបូណ៌ដោយពណ៌និងកម្លាំង ។ ម្នាលអ្នកប្រាជ្ញ ខ្ញុំចង់បានធីតា ជាអនុជាតនៃព្រះបាទវរុណនាគនោះ នាគកញ្ញានោះឈ្មោះឥរន្ទតី ខ្ញុំព្យាយាមសម្លាប់អ្នក ព្រោះហេតុនាងឥរន្ទតី មានចង្កេះល្អ ជាទីស្រឡាញ់នោះ" ។

*ឮដូច្នោះហើយ ព្រះមហាសត្វគិតថា "លោកនេះនឹងវិនាស ដោយការប្រកាន់ខុស ការស្លាប់របស់អញ មានប្រយោជន៍អ្វីដល់បុណ្ណកៈនេះ អ្នកប្រាថ្នានាគមាណវិកា អញនឹងដឹងនូវហេតុតាមពិត" គិតដូច្នេះហើយ វិធុរៈពោលថា ៖*

"មា ហេវ ត្វំ យក្ខ អហោសិ មូឡ្ហោ,
នដ្ឋា ពហូ ទុគ្គហីតេន លោកេ;
កិំ តេ សុមជ្ឈាយ បិយាយ កិច្ចំ,
មរណេន មេ ឥង្ឃ សុណោមិ សព្វំ"។

*"ម្នាលយក្ស សេចក្តីវង្វេងកុំមានដល់អ្នកឡើយ ពួកសត្វលោកជាច្រើនវិនាសហើយ ព្រោះអំពើដែលខ្លួនប្រកាន់ខុស ចុះអ្នកមានកិច្ចអ្វីដោយការសម្លាប់ខ្ញុំ ព្រោះនាគកញ្ញា មានចង្កេះល្អ ជាទីស្រឡាញ់ សូមអញ្ជើញប្រាប់ ខ្ញុំនឹងស្តាប់ការទាំងអស់មើល" ។*

*ឮដូច្នោះ បុណ្ណកៈប្រាប់វិធុរៈដូច្នេះ ៖*

"មហានុភាវស្ស មហោរគស្ស, ធីតុកាមោ ញាតិភតោហមស្មិ;
តំ យាចមានំ សសុរោ អវោច, យថា មមញ្ញិំសុ សុកាមនីតំ។
ទជ្ជេមុ ខោ តេ សុតនុំ សុនេត្តំ, សុចិម្ហិតំ ចន្ទនលិត្តគត្តំ;
សចេ តុវំ ហទយំ បណ្ឌិតស្ស, ធម្មេន លទ្ធា ឥធ មាហរេសិ;
ឯតេន វិត្តេន កុមារិ លព្ភា, នញ្ញំ ធនំ ឧត្តរិ បត្ថយាម។

“ខ្ញុំចង់បានដីតារបស់ព្រះបាទវរុណនាគជាធំ មានអានុភាពច្រើន ខ្ញុំជាអ្នកស៊ីឈ្នួលរបស់ពួកញាតិ ព្រោះហេតុពួកញាតិដឹងខ្ញុំថា ជាអ្នកត្រូវកាមទង់ទាញដោយពិត បានជាឪពុកក្មេកខ្ញុំ និយាយនឹងខ្ញុំដែលសូមនាងឥរន្ទតីនោះថា យើងនឹងឲ្យកូនក្រមុំ មានរាងកាយល្អ មានភ្នែកល្អ មានទ្រង់ទ្រាយឆើតឆាយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ ដល់អ្នក បើអ្នកបានបេះដូងរបស់វិធុរបណ្ឌិត មកដោយធម៌ ហើយនាំមកក្នុងភពនាគនេះ ។ អ្នកនឹងបាននាងកុមារី ដោយទ្រព្យជាទីត្រេកអរនុ៎ះ យើងមិនប្រាថ្នាទ្រព្យដទៃក្រៃលែងទេ” ។

“ឯវំ ន ម្យ្ហោស្មិ សុណោហិ កត្តេ, ន ចាបិ មេ ទុក្ខហិតត្ថិ កិញ្ចិ;
ហទយេន តេ ធម្មលទ្ធេន នាគា, ឥរន្ទតឹ នាគកញ្ញំ ទទន្តិ ។
តស្មា អហំ តុយ្ហំ វធាយ យុត្តោ, ឯវំ មមត្ថោ មរណេន តុយ្ហំ;
ឥធេវ តំ នរកេ បាតយិត្វា, ហន្ត្វាន តំ ហទយមានយិស្សំ” ។

“ម្នាលបណ្ឌិតជាអាមាត្យ ខ្ញុំមិនវង្វេងដូចអ្នកថាទេ អ្នកចូរស្ដាប់ចុះមួយទៀត អំពើតិចតួចដែលខ្ញុំប្រកាន់ខុសមិនមានទេ កាលខ្ញុំបានបេះដូងរបស់អ្នកដោយធម៌ ពួកនាគនឹងឲ្យនាគកញ្ញា ឈ្មោះឥរន្ទតី ។ ព្រោះហេតុនោះ ទើបខ្ញុំលៃលកសម្លាប់អ្នក ខ្ញុំមានសេចក្ដីត្រូវការដោយការសម្លាប់អ្នកយ៉ាងនេះឯង ។ ខ្ញុំនឹងទម្លាក់

អ្នកក្នុងរណ្តៅនេះ សម្លាប់អ្នកហើយ នឹងយកបេះដូងរបស់អ្នកទៅ" ។

## វិធុរបណ្ឌិតសម្តែងសាធុនរធម៌

ព្រះមហាសត្វ ស្តាប់សម្តីរបស់បុណ្ណកៈនោះហើយ ទើបគិតថា "បេះដូងរបស់អញ មិនមែនជារបស់ចាំបាច់បំផុត ចំពោះព្រះនាងវិមលាទេ នាគរាជឈ្មោះវរុណៈ បានស្តាប់នូវធម្មកថារបស់អញហើយ បូជាអញដោយកែវមណី សរសើរអញ ក្នុងកាលអញទៅទីនោះ ។ នៅទីនោះ ព្រះនាងវិមលាប្រាកដជាមានរោគចាញ់កូនចម្លែក ចង់ស្តាប់នូវធម្មកថារបស់អញ ស្តេចវរុណៈយល់ច្រឡំសេចក្តីទើបបង្គាប់បុណ្ណកៈ ទាំងបុណ្ណកៈក៏មានការយល់ច្រឡំ ទើបបានញ៉ាំងអញឲ្យដល់នូវក្តីទុក្ខលំបាកយ៉ាងនេះ ដើម្បីឲ្យអញស្លាប់ ។ ភាពជាបណ្ឌិតរបស់អញមានសមត្ថភាពក្នុងការគិតរកនូវហេតុនៃការកើតឡើងរឿងរ៉ាវ តើនឹងធ្វើប្រយោជន៍ដូចម្តេច កាលបើបុណ្ណកៈនេះសម្លាប់អញ ។ លុះគិតដូច្នេះហើយ វិធុរៈពោលថា ៖

"ម្នាលមាណព ខ្ញុំចេះសាធុនរធម៌ អ្នកចូរឲ្យខ្ញុំអង្គុយលើកំពូលភ្នំ អ្នកចូរស្តាប់សាធុនរធម៌របស់ខ្ញុំសិន ទាន់ពេលដែលខ្ញុំមិនទាន់ស្លាប់ ។ ដល់ពេលស្តាប់រួច អ្នកចង់ធ្វើអ្វី ស្រេចលើអ្នកចុះ" ។

*វិធុរបណ្ឌិតដាក់ជីវិតសរសើរនូវសាធុនរធម៌ ទោះបីលោកកំពុងសំយុង ក្បាលចុះក្រោមនៅឡើយក៏ដោយ ក៏ខំពោលបន្ថែមថា ៖*

"ខិប្បំ មមំ ឧទ្ធរ កាតិយាន, ហានយេន មេ យទិ តេ អត្ថិ កិច្ចំ;
យេ កេចិ មេ សាធុនរស្ស ធម្មា, សព្ពេវ តេ បាតុករោមិ អជ្ជ" ។

*"ម្នាលកច្ចាយនៈ បើអ្នកមានកិច្ចត្រូវការដោយបេះដូងរបស់ខ្ញុំ ចូរអ្នកលើកខ្ញុំឲ្យឆាប់រហ័ស ជ្បិតសាធុនរធម៌របស់ខ្ញុំណាមួយ ខ្ញុំនឹងសម្ដែងសាធុនរធម៌ទាំងអស់នោះ ដល់អ្នក ក្នុងថ្ងៃនេះ" ។*

*ឮដូច្នោះ បុណ្ណកៈគិតថា "ធម៌នេះ បណ្ឌិតមិនដែលសម្ដែងដល់មនុស្ស និងទេវតាទេ អញត្រូវលើកគេឡើងឲ្យរហ័ស ហើយនឹងបានស្ដាប់នូវសាធុនរធម៌" រួចគេលើកព្រះមហាសត្តឡើង ដាក់ឲ្យអង្គុយលើកំពូលភ្នំ កាលឃើញវិធុរបណ្ឌិតជាអាមាត្យមានប្រាជ្ញាមិនថមថយអង្គុយដកដង្ហើមស្រួលហើយ ក៏សាកសួរថា ៖*

"សមុទ្ធដោ មេសិ តុវំ បថាតា, ហានយេន តេ អជ្ជ មមត្ថិ កិច្ចំ;
យេ កេចិ មេ សាធុនរស្ស ធម្មា, សព្ពេវ មេ បាតុករោហិ អជ្ជ"។

*"អ្នក គឺខ្ញុំលើកឡើងចាករណ្ដៅហើយ ក្នុងថ្ងៃនេះខ្ញុំត្រូវការបេះដូងរបស់អ្នក អ្នកចូរសម្ដែងសាធុនរធម៌ទាំងអស់នោះដល់ខ្ញុំក្នុងថ្ងៃនេះ" ។*

ពុទ្ធដូច្នោះហើយ ព្រះមហាសត្វតបថា ៖

"សមុទ្ធដោ ត្យស្មិ អហំ បចាតា, ហានយេន មេ យទិ តេ អត្ថិ កិច្ចំ;
យេ កេចិមេ សាធុនរស្ស ធម្មា, សព្វេវ តេ ចាតុករោមិ អជ្ជ" ។

"ខ្ញុំ គឺអ្នកលើកឡើងចាករណ្ដៅហើយ បើអ្នកត្រូវការបេះដូងរបស់
ខ្ញុំ ខ្ញុំនឹងសម្ដែងសាធុនរធម៌ទាំងអស់នោះដល់អ្នកក្នុងថ្ងៃនេះ" ។

គ្រានោះ មហាសត្វនិយាយនឹងបុណ្ណកៈថា ៖

"ខ្ញុំមានខ្លួនសៅហ្មងណាស់ ចាំខ្ញុំងូតទឹកសិន" ។

យក្សយល់ព្រម រួចបានយកទឹកមកឲ្យវិធុរបណ្ឌិតងូត ។ ក្នុងពេលងូត យក្សបានឲ្យសំពត់ គ្រឿងក្រអូប និងផ្កាកម្រងទិព្វជាដើម ជូនដល់ព្រះមហាសត្វ និងឲ្យភោជនទិព្វ ក្នុងកាលប្រដាប់តុបតែង ។ គ្រានោះ ព្រះមហាសត្វ កាលដែលបរិភោគភោជនហើយ ប្រាប់ឲ្យបុណ្ណកយក្សតុបតែងកំពូលភ្នំកាឡាគិរី ប្រាប់ឲ្យក្រាលអាសនៈរួចហើយ លោកឡើងអង្គុយលើធម្មាសនៈ ដែលតុបតែងនោះ ហើយសម្ដែងនូវសាធុនរធម៌តាមលំនាំព្រះពុទ្ធថា ៖

"យាតានុយាយី ច ភវាហិ មាណវ, អល្លញ្ច ចាណិំ បរិវជ្ជយស្សុ;
មា ចស្សុ មិត្តេសុ កទាចិ ទុព្ភី, មា ច វសំ អសតីនំ និគច្ឆេ" ។

"ម្នាលមាណព អ្នកចូរដើរតាមផ្លូវដែលគេដើរហើយ អ្នកចូរវៀរ គឺកុំដុតបាតដៃទាំងទទឹក អ្នកកុំប្រទូស្តមិត្រ ក្នុងកាលណាមួយ ឡើយ អ្នកកុំលុះអំណាចនៃស្រីដែលប្រកបដោយអសទ្ធម្ម" ។

យក្សមិនអាចយល់ច្បាស់នូវសាធុនរធម៌ទាំង ៤ ដែលសម្តែងដោយ សង្ខេប ក៏សួរនូវសេចក្តីពិស្តារថា ៖

"កថំ នុ យាតំ អនុយាយិ ហោតិ, អល្លញ្ច ចាណិំ ទហតេ កថំ សោ;
អសតី ច កា កោ បន មិត្តទុព្ភោ, អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ" ។

"បុគ្គលដែលឈ្មោះថាដើរទៅកាន់ផ្លូវ ដែលគេដើរហើយ តើដូច ម្តេច ? គេដុតបាតដៃទាំងទទឹក តើដូចម្តេច ? ស្រីដូចម្តេចឈ្មោះ ថា ស្រីប្រកបដោយអសទ្ធម្ម ? នរណាឈ្មោះថាជាអ្នកប្រទូស្ត មិត្រ ? ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ" ។

ព្រះមហាសត្វ ឆ្លើយតបនឹងបុណ្ណកយក្សនោះថា ៖

"អសន្ថុតំ នោបិ ច ទិដ្ឋបុព្វំ, យោ អាសនេនាបិ និមន្តយេយ្យ;
តស្សេវ អត្ថំ បុរិសោ ករេយ្យ, យាតានុយាយីតិ តមាហុ បណ្ឌិតា។

"បុគ្គលណា អញ្ជើញមនុស្សដែលមិនធ្លាប់នៅជាមួយគ្នា ឬមិន ធ្លាប់ឃើញគ្នា សូម្បីដោយអាសនៈ បុរសត្រូវធ្វើប្រយោជន៍តប

*ស្នងដល់បុគ្គលនោះឯង បណ្ឌិតទាំងឡាយពោលថា អ្នកនោះ ឯងជាអ្នកដើរតាមផ្លូវដែលគេដើរហើយ” ។*

“យស្សេករត្តម្បិ ឃរេ វសេយ្យ, យត្ថន្នបានំ បុរិសោ លភេយ្យ;
ន តស្ស បាបំ មនសាបិ ចិន្តយេ, អទុព្ភបាណឹ ទហតេ មិត្តទុព្ភោ។

*“បុរសស្នាក់នៅក្នុងផ្ទះរបស់បុគ្គលណាសូម្បីមួយយប់ ហើយបានបាយនិងទឹកក្នុងសម្នាក់បុគ្គលណា បុរសមិនត្រូវគិតអាក្រក់ចំពោះបុគ្គលនោះ សូម្បីដោយចិត្ត បុគ្គលអ្នកប្រទូស្តមិត្រ ឈ្មោះថាដុតបាតដៃទាំងទទឹក” ។*

“យស្ស រុក្ខស្ស ឆាយាយ, និសីទេយ្យ សយេយ្យ វា;
ន តស្ស សាខំ ភញ្ជេយ្យ, មិត្តទុព្ភោ ហិ បាបកោ។
បុណ្ណម្បិ ចេមំ បថវឹ ធនេន, ទជ្ជិត្ថិយា បុរិសោ សម្មតាយ;
លទ្ធា ខណំ អតិមញ្ញេយ្យ តម្បិ, តាសំ វសំ អសតីនំ ន គច្ឆេ។

*“បុគ្គលអង្គុយឬដេក ក្នុងម្លប់ឈើណា មិនត្រូវកាច់មែកឈើនោះ ព្រោះថា បុគ្គលប្រទូស្តមិត្រ ជាបុគ្គលអាក្រក់ ។ បុរសណាឲ្យផែនដីនេះដែលពេញដោយទ្រព្យ ដល់ស្រីដែលខ្លួនសន្មតថាល្អ ស្រីនោះបានឱកាសក្បត់ចិត្ត ហើយមើលងាយបុរសនោះវិញ បុគ្គលមិនត្រូវលុះអំណាចស្រីដែលប្រកបដោយអសទ្ធម្មនោះទេ” ។*

“ឯវំ ខោ យាតំ អនុយាយិ ហោតិ,

អលព្ភំ ចាណិំ ឧហាតេ ឬនេវ;
អសតី ច សា សោ បន មិត្តទុព្ភោ,
សោ ធម្មិកោ ហោហិ ជហស្សុ អធម្មំ"។

"បុគ្គលឈ្មោះថាដើរទៅកាន់ផ្លូវដែលគេដើរហើយ យ៉ាងនេះ ឈ្មោះថាជុតបាតដៃទាំងទទឹកយ៉ាងនេះ ស្រីនោះឈ្មោះថា ប្រកបដោយអសទ្ធម្ម បុរសនោះឈ្មោះថាជាអ្នកប្រទូស្តមិត្រ ចូរ អ្នកប្រកបដោយធម៌ ចូរលះបង់អំពើមិនមែនធម៌ចេញ" ។

ព្រះមហាសត្វ បានសម្តែងតាមលំនាំព្រះពុទ្ធ នូវសាធុនរធម៌ ៤ ដល់ យក្ស ដោយប្រការយ៉ាងនេះ ។

សាធុនរធម្មកណ្ឌ ចប់ ។

**បុណ្ណកយក្សដោះលែងវិធុរៈ**

*កាលកំពុងតែស្ដាប់នូវសាធុនរធម៌ទាំងនោះ បុណ្ណកៈកំណត់ថា "លោកបណ្ឌិត កំពុងតែសូមនូវជីវិតរបស់ខ្លួនតែម៉្យាង ក្នុងហេតុសូម្បីទាំង ៤ នោះ ។ បណ្ឌិតនេះ បានធ្វើហើយនូវសក្ការៈដល់អាត្មាអញ ដែលជាមនុស្សមិនគួរធ្វើ ក្នុងកាលមុនសោះ ។ អញស្នាក់នៅក្នុងផ្ទះរបស់គាត់ សោយនូវយសដ៏ធំ អស់ ៣ ថ្ងៃ ក្នុងពេលអាត្មាអញកំពុងតែធ្វើនូវបាបកម្ម ព្រោះអាស្រ័យមាតុគ្រាមដោយពិត ឱ ! ខ្លួនអញ ជាមនុស្សប្រទូស្តមិត្រពេញទីទេតើ ។ ប្រសិនបើអញប្រព្រឹត្តខុសចំពោះលោកបណ្ឌិត អញឈ្មោះថាមិនប្រព្រឹត្តតាមនូវសាធុនរធម៌ ព្រោះហេតុនោះ នាគមាណវិកា មានប្រយោជន៍អ្វីដល់អញ អញនឹងញ៉ាំងមុខដោកដោយទឹកភ្នែករបស់អ្នកក្រុងឥន្ទបត្ត ឲ្យញញឹមស្រស់ស្រាយឡើងវិញ អញនឹងនាំវិធុរៈនេះទៅទីនោះជាប្រញាប់ ហើយដាក់ចុះក្នុងធម្មសភាវិញ" គិតឃើញដូច្នេះហើយ បុណ្ណកៈបានពោលថា ៖*

"អវសិំ អហំ តុយ្ហ តីហំ អគារេ, អន្នេន ចានេន ឧបដ្ឋិតោស្មិ;
មិត្តោ មមាសី វិសជ្ជាមហំ តំ, កាមំ ឃរំ ឧត្តមបញ្ញ គច្ឆ"។

*"ខ្ញុំធ្លាប់បានស្នាក់អាស្រ័យក្នុងផ្ទះរបស់អ្នក អស់ ៣ ថ្ងៃ អ្នកក៏បានទំនុកបម្រុងខ្ញុំដោយបាយនិងទឹកផងដែរ អ្នកសូមជាមិត្ររបស់ខ្ញុំ ទាំងខ្ញុំក៏លែងអ្នកដែរ ម្នាលបណ្ឌិតអ្នកមានប្រាជ្ញាខ្ពង់ខ្ពស់ ចូរអ្នក*

*អញ្ជើញទៅកាន់ផ្ទះរបស់អ្នកតាមប្រាថ្នាចុះ ។*

“អបិ ហាយតុ នាគកុលា អត្ថោ, អលម្បិ មេ នាគកញ្ញាយ ហោតុ;
សោ ត្វំ សកេនេវ សុភាសិតេន, មុត្តោសិ មេ អជ្ជ វធាយ បញ្ញា” ។

*“ឯសេចក្តីត្រូវការរបស់ត្រកូលនាគ ក៏សាបសូន្យទៅចុះ ។ អំពើទាំងឡាយ ព្រោះហេតុនៃនាងនាគកញ្ញា ក៏ល្មមដល់ខ្ញុំហើយ ម្នាលអ្នកមានប្រាជ្ញា អ្នកបានរួចចាកការសម្លាប់របស់ខ្ញុំ ក្នុងថ្ងៃនេះ ព្រោះសុភាសិតរបស់អ្នក” ។*

# ជំពូកទី ៥

## វិធុរបណ្ឌិតធ្វើមាតុភូមិនិវត្តន៍

### វិធុរបណ្ឌិតទៅភពនាគ

*គ្រានោះ ព្រះមហាសត្តនិយាយនឹងបុណ្ណកយក្សថា ៖*

> *"នៃមាណព អ្នកកុំបញ្ជូនខ្ញុំទៅផ្ទះខ្លួនវិញឡើយ អ្នកចូរនាំខ្ញុំទៅកាន់ភពនាគឯណោះចុះ" ។*

*រួចបន្តពោលថា ៖*

> "ហន្ទ តុវំ យក្ខ មមម្បិ នេហិ, សសុរំ តេ អត្ថំ មយិ ចរស្សុ;
> មយញ្ច នាគាធិបតឹ វិមានំ, ទក្ខេមុ នាគស្ស អទិដ្ឋបុព្វំ" ។

> *"ម្នាលយក្ស ណ្ហើយ អ្នកចូរនាំខ្ញុំទៅកាន់សម្នាក់ឪពុកក្មេករបស់អ្នកចុះ អ្នកចូរប្រព្រឹត្តឲ្យជាប្រយោជន៍ចំពោះខ្ញុំ ដ្បិតខ្ញុំចង់ឃើញនាគរាជជាអធិបតី និងវិមានរបស់នាគរាជ ដែលខ្ញុំមិនធ្លាប់ឃើញពីមុនមក" ។*

*ឮដូច្នោះ បុណ្ណយក្សតបថា ៖*

> "យំ វេ នរស្ស អហិតាយ អស្ស, ន តំ បញ្ញោ អរហតិ ទស្សនាយ;
> អថ កេន វណ្ណេន អមិត្តគាមំ, តុវមិច្ឆសិ ឧត្តមបញ្ញ គន្តុំ" ។

"របស់ណាដែលប្រព្រឹត្តទៅ មិនជាប្រយោជន៍ដល់នរជន ជនមានប្រាជ្ញា មិនគួរឃើញរបស់នោះទេ ម្នាលបណ្ឌិតមានប្រាជ្ញាខ្ពង់ខ្ពស់ កាលបើដូច្នេះ អ្នកប្រាថ្នាទៅកាន់ស្រុករបស់សត្រូវដោយហេតុដូចម្ដេច ?"

ព្រះមហាសត្តតបនឹងបុណ្ណកៈនោះថា ៖

"ហេតុនុ៎ះខ្ញុំប្រាកដជាដឹង ជនមានប្រាជ្ញាមិនគួរឃើញសត្រូវនោះទេ តែអំពើអាក្រក់ ខ្ញុំមិនដែលបានធ្វើទុកក្នុងទីណាមួយឡើយ ព្រោះហេតុនោះ ខ្ញុំមិនរង្កៀសចំពោះសេចក្ដីស្លាប់ដែលនឹងមកដល់ឡើយ ។ បពិត្រទេវរាជ មួយវិញទៀត អម្បាលយក្សប្រហែលអ្នក កាចឃោរឃៅណាស់ គង់ត្រូវខ្ញុំប្រលោមដោយធម្មកថា ធ្វើឲ្យទន់ភ្លន់បាន មិនត្រឹមតែប៉ុណ្ណោះសោត អ្នកថែមទាំងនិយាយនឹងខ្ញុំថា អ្នកលែងត្រូវការនាគក្រមុំ ហើយបញ្ជូនខ្ញុំឲ្យទៅផ្ទះវិញដូច្នេះ វិធីសាស្ត្រ ធ្វើឲ្យនាគរាជទន់ចិត្ត ទុកជាភារៈរបស់ខ្ញុំចុះ សូមតែអ្នកនាំខ្ញុំឲ្យទៅដល់ទីនោះបានហើយ" ។

ឮសម្ដីរបស់ពោធិសត្វ បុណ្ណកៈមានចិត្តត្រេកអរ ក៏យល់ព្រមហើយពោលថា ៖

"ហន្ទ ច ឋានំ អតុលានុភាវំ, មយា សហ ទក្ខសិ ឯហិ កត្តេ;
យត្ថច្ឆតិ នច្ចគីតេហិ នាគោ, រាជា យថា វេស្សវណោ នឡិញ្ញំ។

ឆំ នាគកញ្ញា ចរិតំ គណេន, និកីឡិតំ និច្ចមហោ ច រត្តិំ;
បហូតមាល្យំ ពហុបុប្ផឆន្នំ, ឱភាសតី វិជ្ជុរិវន្តលិក្ខេ។
អន្នេន បានេន ឧបេតរូបំ, នច្ចេហិ គីតេហិ ច វាទិតេហិ;
បរិបូរំ កញ្ញាហិ អលង្កតាហិ, ឧបសោភតិ វត្ថបិលន្ធនេន"។

*"ម្នាលអ្នកជាអាមាត្យ បើដូច្នោះ អ្នកចូរមកចុះ អ្នកនឹងឃើញឋាន ដែលមានអានុភាពប្រៀបមិនបាន ជាមួយនឹងខ្ញុំ នាគរមែងនៅ ដោយការរាំនិងច្រៀងក្នុងទីណា ដូចជាព្រះបាទវេស្សវណ្ណ នៅក្នុងរាជធានីឈ្មោះនិឡិញ្ញៈ ទីនោះ មានពួកនៃនាងនាគកញ្ញា ត្រាច់ទៅដោយពួក ៗ លេងអស់ថ្ងៃនិងយប់ជានិច្ច ជាទីមានផ្កាកម្រងច្រើន ដេរដាសដោយផ្កាឈើច្រើនបែប ភ្លឺផ្ទេកដូចផ្ទេកបន្ទោរឮដ៏អាកាស ។ ភពនៃនាគនោះ មានភាពសម្បូណ៌ដោយបាយនិងទឹក និងការរាំ ច្រៀង ប្រគំ បរិបូណ៌ដោយពួកនាងនាគកញ្ញា ដែលតាក់តែងខ្លួនដោយសំពត់ និងគ្រឿងប្រដាប់ល្អឆើតឆាយ" ។*

*លុះពោលយ៉ាងនេះហើយ បុណ្ណកៈបានអញ្ជើញវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើរ របស់អ្នកដែនកុរុឲ្យអង្គុយលើអាសនៈអំពីខាងក្រោយខ្នងសេះ បំផាយសេះនាំវិធុរបណ្ឌិត ចូលទៅកាន់ភពនៃនាគរាជ ។*

បានឮមក បុណ្ណកយក្សគិតឃើញថា បើនាគរាជឃើញនូវលោក បណ្ឌិតហើយ មានចិត្តទន់ភ្លន់ ដូច្នេះនុ៎ះ ជាការល្អ ប៉ុន្តែបើមិនដូច្នោះ ទេ អញនឹងបំបោលសេះសិន្ធពដឹកលោកបណ្ឌិតត្រឡប់ទៅវិញភ្លាម មិនឲ្យនាគរាជនោះ ឃើញលោកបណ្ឌិតទាន់ឡើយ ។

អាស្រ័យហេតុនេះហើយ ទើបនាំឲ្យបុណ្ណកយក្សដាក់លោកបណ្ឌិតនៅពីខាងក្រោយ ។ វិធុរបណ្ឌិតជាអាមាត្យ លុះដល់ទីដែលមានអានុភាពប្រៀបមិនបាន ក៏ឈរខាងក្រោយបុណ្ណកយក្ស ចំណែកនាគរាជ គ្រាន់តែក្រឡេកមើលឃើញបុណ្ណកយក្សជាកូនប្រសារបស់ខ្លួន មានសេចក្តីស្មោះសរ ក៏បានត្រាស់នឹងកូនប្រសាមុនដោយផ្ទាល់ថា ៖

"យន្នុ តុវំ អគមា មច្ចលោកំ, អន្វេសមានោ ហទយំ បណ្ឌិតស្ស;
កច្ចិ សមិទ្ធេន ឥធានុបត្តោ, អាទាយ កត្តារមនោមបញ្ញំ" ។

"អ្នកកាលស្វែងរកបេះដូងរបស់បណ្ឌិត បានទៅកាន់មនុស្សលោក ហើយនាំអាមាត្យមានប្រាជ្ញាមិនថោកទាប មកដល់ក្នុងទីនេះ ដោយសួស្តីហើយឬ?"

បុណ្ណកៈ តបថា ៖

"អយញ្ហិ សោ អាគតោ យំ ត្វមិច្ឆសិ, ធម្មេន លទ្ធោ មម ធម្មបាលោ;
តំ បស្សថ សម្មុខា ភាសមានំ, សុខោ ហវេ សប្បុរិសេហិ សង្គមោ" ។

"ព្រះអង្គប្រាថ្នាបណ្ឌិតណា បណ្ឌិតនោះមកដល់ហើយ បណ្ឌិតអ្នករក្សាធម៌ គឺខ្ញុំព្រះអង្គបាននាំមកដោយធម៌ហើយ សូមព្រះអង្គទ្រង់ទតបណ្ឌិតនោះ ដែលកំពុងនិយាយក្នុងទីចំពោះព្រះភក្ត្រនៃព្រះអង្គ ការជួបជុំដោយសប្បុរសទាំងឡាយ ជាហេតុនាំមកនូវសេចក្ដីសុខ ដោយពិត" ។

កាឡាគិរិកណ្ឌ ចប់ ។

## អ្នកទោសមិនថ្វាយបង្គំពេជ្ឈឃាត

គ្រានោះ នាគរាជឃើញនូវព្រះមហាសត្វ ក៏ពោលថា ៖

"អធិជ្ជបុត្តំ ធិស្វាន, មច្ចោ មច្ចុភយដ្ដិតោ;
ព្យម្ហិតោ ធាភិវាទេសិ, ធយិធំ បញ្ញវតាមិវ" ។

"អ្នកជាមនុស្សតក់ស្លុត ព្រោះឃើញភពនាគដែលខ្លួនមិនធ្លាប់បានឃើញ ជាអ្នកមានមច្ចុភ័យគ្របសង្កត់ ទើបមិនថ្វាយបង្គំខ្ញុំ ដំណើរនេះ មិនមែនជាដំណើរបុគ្គលមានប្រាជ្ញាទេ" ។

កាលនាគរាជ កំពុងតែទទូចការថ្វាយបង្គំយ៉ាងនេះ ព្រះមហាសត្វមិននិយាយថា "ព្រះអង្គ គឺទូលបង្គំមិនគប្បីថ្វាយបង្គំទេ" ដូច្នេះឡើយ តែដោយហេតុលោកមានញាណ និងដោយហេតុតែឈ្លាសក្នុងឧបាយកល លោកនិយាយថា ៖

"ធ ចម្ហិ ព្យម្ហិតោ ធាគ, ធ ច មច្ចុភយដ្ដិតោ;
ធ វជ្ឈោ អភិវាទេយ្យ, វជ្ឈំ វា ធាភិវាទយេ ។
កថំ ធោ អភិវាទេយ្យ, អភិវាទាបយេថ វេ;
យំ ធរោ ហន្តុមិច្ឆេយ្យ, តំ កម្មំ ធុបបជ្ជតិ" ។

"ទូលបង្គំមានទោសត្រូវគេសម្លាប់ មិនថ្វាយបង្គំព្រះអង្គទេ ។ បពិត្រនាគ ខ្ញុំព្រះអង្គមិនមែនជាអ្នកតក់ស្លុតទេ មិនមានមច្ចុភ័យ

គ្របសង្កត់ទេ ព្រោះអ្នកទោសដែលត្រូវគេសម្លាប់ មិនគប្បីថ្វាយបង្គំនូវពេជ្ឈឃាត ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណា គប្បីថ្វាយបង្គំអ្នកនោះ ឬឲ្យអ្នកនោះថ្វាយបង្គំខ្លួនដូចម្ដេចកើត កម្មនោះមិនសម្រេចទៅជាអ្វីទេ" ។

ឮដូច្នោះ នាគរាជ ធ្វើនូវការសរសើរចំពោះព្រះមហាសត្វថា ៖

"ឯវមេតំ យថា ព្រូសិ, សច្ចំ ភាសសិ បណ្ឌិត;
ន វជ្ឈោ អភិវាទេយ្យ, វជ្ឈំ វា នាភិវាទយេ ។
កថំ នោ អភិវាទេយ្យ, អភិវាទាបយេថ វេ;
យំ នរោ ហន្តុមិច្ឆេយ្យ, តំ កម្មំ នុបបជ្ជតិ" ។

"ម្នាលបណ្ឌិត ដំណើរនុ៎ះ ដូចអ្នកពោលមែន អ្នកពោលពាក្យពិត អ្នកទោសដែលត្រូវគេសម្លាប់ មិនគប្បីថ្វាយបង្គំពេជ្ឈឃាត ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោស ដែលត្រូវគេសម្លាប់ដែរ ។ នរជនប្រាថ្នាសម្លាប់អ្នកណា គប្បីថ្វាយបង្គំអ្នកនោះ ឬឲ្យអ្នកនោះថ្វាយបង្គំខ្លួនដូចម្ដេចកើត កម្មនោះមិនកើតជាអ្វីទេ"។

តទៅនេះ ព្រះមហាសត្វធ្វើបដិសណ្ឋារៈ ជាមួយនឹងនាគរាជថា ៖

"អសស្សតំ សស្សតំ នុ តវយិទំ, ឥទ្ធី ជុតី ពលវីរិយូបបត្តិ;

បុច្ឆាមិ តំ នាគរាជេតមត្ថំ, កថំ នុ តេ លទ្ធមិទំ វិមានំ ។
អធិច្ចលទ្ធំ បរិណាមជំ តេ, សយំកតំ ឧទាហុ ទេវេហិ ទិន្នំ;
អក្ខាហិ មេ នាគរាជេតមត្ថំ, យថេវ តេ លទ្ធមិទំ វិមានំ" ។

"វិមាននេះ ទាំងឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាម និងការកើតក្នុងភពនាគរបស់ព្រះអង្គ មិនទៀង តែដូចជារបស់ទៀង បពិត្រនាគរាជ ខ្ញុំព្រះអង្គសូមសួរសេចក្តីនុ៎ះ នឹងព្រះអង្គថា វិមាននេះព្រះអង្គបានហើយ ដោយហេតុដូចម្តេច ។ វិមាននេះ ព្រះអង្គបាន ព្រោះអាស្រ័យភពនាគ ឬកើតអំពីរដូវប្រែប្រួល ឬព្រះអង្គកសាងដោយព្រះអង្គឯង ឬមួយទេវតាថ្វាយ បពិត្រនាគរាជ វិមាននេះ ព្រះអង្គបានហើយ ដោយប្រការណា សូមព្រះអង្គ ប្រាប់សេចក្តីនុ៎ះដល់ខ្ញុំព្រះអង្គ ដោយប្រការនោះ" ។

ឮដូច្នោះហើយ នាគរាជឆ្លើយតបថា ៖

"នាធិច្ចលទ្ធំ ន បរិណាមជំ មេ, ន សយំកតំ នាបិ ទេវេហិ ទិន្នំ;
សកេហិ កម្មេហិ អបាបកេហិ, បុញ្ញេហិ មេ លទ្ធមិទំ វិមានំ" ។

"វិមាននេះមិនមែនខ្ញុំបាន ព្រោះអាស្រ័យភពនាគ មិនមែនកើតអំពីរដូវប្រែប្រួល មិនមែនខ្ញុំធ្វើខ្លួនឯង ទាំងមិនមែនទេវតាឲ្យទេ វិមាននេះខ្ញុំបានដោយបុញ្ញកម្មរបស់ខ្លួន" ។

គ្រានោះ ព្រះមហាសត្វពោលថា ៖

"កឹំ តេ វតំ កឹំ បន ព្រហ្មចរិយំ, កិស្ស សុចិណ្ណស្ស អយំ វិបាកោ;
ឥទ្ធី ជុតី ពលវីរិយូបបត្តិ, ឥទញ្ច តេ នាគ មហាវិមានំ" ។

"អ្វីជាវត្តរបស់ព្រះអង្គ អ្វីជាព្រហ្មចរិយៈរបស់ព្រះអង្គ បពិត្រនាគ ឫទ្ធិ សេចក្ដីរុងរឿង កម្លាំងកាយ សេចក្ដីព្យាយាម និងការកើតក្នុងភពនាគ ទាំងវិមានធំរបស់ព្រះអង្គនេះ តើជាផលនៃកម្មដែលព្រះអង្គសន្សំល្អហើយ ដូចម្ដេច" ?

ឮសំណួរនោះហើយ នាគរាជឆ្លើយតបថា ៖

"អហញ្ច ភរិយា ច មនុស្សលោកេ, សទ្ធា ឧភោ ទានបតី អហុម្ហា;
ឱបានភូតំ មេ ឃរំ តទាសិ, សន្តប្បិតា សមណព្រាហ្មណា ច ។
មាលញ្ច គន្ធញ្ច វិលេបនញ្ច, បទីបិយំ សេយ្យមុបស្សយញ្ច;
អច្ឆាទនំ សាយនមន្នបានំ, សក្កច្ច ទានានិ អទម្ហ តត្ថ" ។

"ខ្ញុំនិងភរិយាទាំងពីរនាក់ កាលនៅក្នុងមនុស្សលោក ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំដូចជាអណ្ដូងនៃមហាជន ទាំងពួកសមណៈនិងព្រាហ្មណ៍ ខ្ញុំក៏បានញ៉ាំងឲ្យឆ្អែតស្កប់ស្កល់ ។ ខ្ញុំកាលនៅក្នុងកាលចម្បានគរនោះបានឲ្យទាន

*ដោយគោរព គឺឲ្យកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសម្នាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយ ទឹក" ។*

"តំ មេ វតំ តំ បន ព្រហ្មចរិយំ, តស្ស សុចិណ្ណស្ស អយំ វិបាកោ;
ឥទ្ធី ជុតី ពលវីរិយូបបត្តិ, ឥទញ្ច មេ ធីរ មហាវិមានំ" ។

*"នោះជាវត្ត នោះជាព្រហ្មចរិយៈរបស់ខ្ញុំ នៃអ្នកប្រាជ្ញ ឯឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាម និងការកើតក្នុងភពនាគ ទាំងវិមានធំរបស់ខ្ញុំនេះ ផលនៃកម្មដែលខ្ញុំសន្សំល្អហើយនោះ" ។*

*ព្រះមហាសត្តពោលថា ៖*

"ឯវំ ចេ តេ លទ្ធមិទំ វិមានំ, ជានាសិ បុញ្ញានំ ផលូបបត្តិំ;
តស្មា ហិ ធម្មំ ចរ អប្បមត្តោ, យថា វិមានំ បុន មាវសេសិ" ។

*"បើវិមាននេះ ព្រះអង្គបានហើយយ៉ាងនេះ ឈ្មោះថា ព្រះអង្គជ្រាបកំណើតនៃផលរបស់បុណ្យ ព្រោះហេតុនោះ ព្រះអង្គកុំប្រហែស សូមប្រព្រឹត្តធម៌ ជាហេតុឲ្យបានគ្រប់គ្រងវិមាននេះតទៅទៀត" ។*

*ព្រះដូច្នោះហើយ នាគរាជពោលថា ៖*

"នយិធ សន្តិ សមណាព្រាហ្មណា ច, យេសន្នបានានិ ទទេមុ កាត្តេ;
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ, យថា វិមានំ បុន មាវសេម"។

*"នៃអាមាត្យជាបណ្ឌិត ខ្ញុំគប្បីឲ្យបាយនិងទឹកដល់ពួកសមណៈ និងព្រាហ្មណ៍ណា តែពួកសមណៈនិងព្រាហ្មណ៍នោះ មិនមាន ក្នុងភពនាគនេះទេ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ ដែលជា ហេតុឲ្យខ្ញុំនៅគ្រប់គ្រងវិមានតទៅ" ។*

*ព្រះមហាសត្ត ពោលថា ៖*

"ភោគី ហិ តេ សន្តិ ឥធូបបន្នា, បុត្តា ច ទារា អនុជីវិនោ ច;
តេសុ តុវំ វចសា កម្មុនា ច, អសម្បទុដ្ឋោ ច ភវាហិ និច្ចំ។
ឯវំ តុវំ នាគ អសម្បទោសំ, អនុបាលយ វចសា កម្មុនា ច;
ឋត្វា ឥធ យាវតាយុកំ វិមានេ, ឧទ្ធំ ឥតោ គច្ឆសិ ទេវលោកំ"។

*"ពួកនាគ គឺបុត្រ ភរិយា និងអ្នករស់នៅដោយសារ ដែលចូលមក កើតក្នុងភពនាគនេះ សូមព្រះអង្គជាអ្នកមិនប្រទូស្តក្នុងពួកនាគ នោះ ដោយពាក្យឬដោយការងារ អស់កាលជានិច្ច ។ បពិត្រនាគ សូមព្រះអង្គរក្សានូវសេចក្តីមិនប្រទូស្តដោយពាក្យ ឬដោយការ ងារយ៉ាងនេះចុះ ព្រះអង្គនឹងឋិតនៅក្នុងវិមាននេះ រហូតអស់ព្រះ ជន្ម ហើយនឹងបានទៅកាន់ទេវលោកជាន់ខាងលើ អំពីភពនាគ នេះ" ។*

កាលដែលនាគរាជស្តាប់នូវធម្មកថា របស់ព្រះមហាសត្វ ទ្រង់គិតថា ៖

"លោកបណ្ឌិត មិនអាចដំអក់ឲ្យនៅយឺតយូរខាងក្រៅនេះបានទេ អញគួរតែបង្ហាញដល់នាងវិមលា ឲ្យនាងបានស្តាប់នូវសុភាសិត ដើម្បីរំងាប់បង់នូវរោគចាញ់ ហើយឆ្អាលនឹងបញ្ជូនលោកបណ្ឌិត ទៅស្រុកទេសលោកវិញ ញុំាំងស្តេចធនញ្ជ័យឲ្យញញឹម" ។

គិតដូច្នេះ នាគរាជពោលថា៖

"អទ្ធា ហិ សោ សោចតិ រាជសេដ្ឋោ, តយា វិនា យស្ស តុវំ សជិព្វោ;
ទុក្ខូបនីតោបិ តយា សមេច្ច, វិន្ទេយ្យ ចោសោ សុខមាតុរោបិ។

"អ្នកជាអាមាត្យរបស់ព្រះរាជាណា ព្រះរាជាដ៏ប្រសើរនោះ បើ អត់ពីអ្នកហើយ រមែងសោកស្តាយដោយពិត បុរសសូម្បីត្រូវ សេចក្តីទុកគ្របសង្កត់ ឬសូម្បីមានជំងឺធ្ងន់ បើបានជួបនឹងអ្នក ហើយ ក៏នឹងបានសុខវិញ" ។

ឮដូច្នោះ ព្រះមហាសត្វ លោកបានធ្វើនូវសេចក្តីសរសើរ ដល់នាគរាជ ហើយពោលដូច្នេះ ៖

"អទ្ធា សតំ ភាសសិ ធាតិ ធម្មំ, អនុត្តរំ អត្ថបទំ សុចិណ្ណំ;
ឯតាទិសិយាសុ ហិ អាបទាសុ, បញ្ញាយតេ មាទិសានំ វិសេសោ។

"បពិត្រនាគ ព្រះអង្គពោលធម៌របស់សប្បុរស ជាធម៌ប្រសើរ ជាចំណែកនៃប្រយោជន៍ដែលសន្សំល្អដោយពិត ឯសេចក្ដីវិសេសរបស់បណ្ឌិតទាំងឡាយបែបខ្ញុំព្រះអង្គ រមែងប្រាកដក្នុងអន្តរាយទាំងឡាយបែបនេះ" ។

ឮដូច្នោះ នាគរាជកាន់តែមានសេចក្ដីត្រេកអរ បានសាកសួរអំពីរឿងនោះថា ៖

"អក្ខាហិ នោ តាយំ មុធា នុ លទ្ធោ, អក្ខេហិ នោ តាយំ អជេសិ ជូតេ ធម្មេន លទ្ធោ ឥតិ តាយមាហ, កថំ នុ ត្វំ ហត្ថមិមស្ស មាគតោ។

"អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះ បានអ្នកមកដោយទទេឬ ឬបុណ្ណកយក្សនេះ ឈ្នះអ្នកដោយល្បែងភ្នាល់ បុណ្ណកយក្សបាននិយាយថា បណ្ឌិតខ្ញុំបាននាំមកដោយធម៌ តើអ្នកមកនៅក្នុងកណ្ដាប់ដៃនៃបុណ្ណកយក្សនេះ ដោយប្រការដូចម្ដេច ?"

ព្រះមហាសត្តតបថា ៖

"យោ មិស្សរោ តត្ថ អហោសិ រាជា, តមាយមក្ខេហិ អជេសិ ជូតេ; សោ មំ ជិតោ រាជា ឥមស្សទាសិ, ធម្មេន លទ្ធោស្មិ អសាហសេន"។

"ព្រះរាជារបស់ខ្ញុំព្រះអង្គណា ជាធំក្នុងក្រុងឥន្ទបត្តដែនកុរុនោះ បុណ្ណកយក្សនេះ បានឈ្នះល្បែងស្កានឹងព្រះរាជានោះដោយការ

ភ្ញាល់ ព្រះរាជាដែលបុណ្ណកយក្សឈ្នះហើយនោះ បានប្រទាន ខ្ញុំព្រះអង្គដល់បុណ្ណកយក្សនេះ បុណ្ណកយក្ស ឈ្មោះថាបានខ្ញុំ ព្រះអង្គមកដោយធម៌ មិនមែនដោយការកំហែងទេ" ។

ឮដូច្នោះហើយ នាគរាជ មានហឫទ័យត្រេកអរ រីករាយ ព្រោះបាន ស្ដាប់សុភាសិតនៃវិធុរបណ្ឌិតជាអ្នកប្រាជ្ញ ក៏ចាប់ដៃវិធុរបណ្ឌិតមាន ប្រាជ្ញាមិនអន់ថយ នាំចូលទៅក្នុងសម្នាក់នៃនាងវិមលាជាភរិយាក្នុង កាលនោះហើយ ហៅ ៖

"ម្នាលនាងវិមលា នាងមានសម្បុរលឿងដោយហេតុណា ឬនាង មិនឆ្ងាញ់បាយ ដោយហេតុណា គុណនៃវិធុរៈបែបនេះ មិនមាន ដល់នាង ដោយហេតុនោះទេ វិធុរបណ្ឌិតនេះឯង ជាអ្នកបន្ទោបង់ នូវងងឹត ។ នាងមានសេចក្ដីត្រូវការដោយបេះដូងរបស់វិធុរបណ្ឌិត ណា វិធុរបណ្ឌិតនេះ ជាអ្នកធ្វើពន្លឺ បានមកដល់ហើយ នាងចូរ ផ្ទៀងស្ដាប់ពាក្យរបស់វិធុរបណ្ឌិតនោះចុះ ព្រោះការជួបប្រទះនូវ វិធុរបណ្ឌិតទៀត ជាកិច្ចបានដោយកម្រ" ។

## សេចក្តីសន្ទនារវាងវិធុរៈនិងព្រះនាងវិមលា

ចំណែកព្រះនាងវិមលាទេវី ទតឃើញវិធុរបណ្ឌិត ដែលជាអ្នកមានប្រាជ្ញាគ្រាស់ដូចផែនដី ក៏មានព្រះទ័យត្រេកអរសោមនស្ស[៦៥] ទ្រង់លើកម្រាមដៃទាំង ១០ ផ្គងអញ្ជលី ត្រាស់នឹងវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុយ៉ាងនេះថា ៖

"អ្នកជាមនុស្សមានមច្ចុភ័យគ្របសង្កត់ តក់ស្លុត ព្រោះឃើញភពនាគ ដែលខ្លួនមិនធ្លាប់ឃើញពីមុន ទើបមិនថ្វាយបង្គំយើង ដំណើរនេះ ដូចមិនមែនជាអាការរបស់បុគ្គលមានប្រាជ្ញាទេ" ។

វិធុរបណ្ឌិត ៖

"បពិត្រព្រះនាងនាគី ខ្ញុំព្រះអង្គមិនមែនជាអ្នកតក់ស្លុតទេ មិនមានមច្ចុភ័យគ្របសង្កត់ទេ អ្នកទោសដែលត្រូវគេសម្លាប់ មិនគប្បីថ្វាយបង្គំពេជ្ឈឃាត ឬពេជ្ឈឃាត ក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណា គប្បី

---

[៦៥] (ន.) (បា.),(សំ.) (--ម៉ៈន័ស) (សៅមនស្យ) សេចក្តីសប្បាយចិត្ត, សេចក្តីរីករាយសប្បាយ; អំណរ : មានសោមនស្ស (មិនបាច់ប្រើ សេចក្តី ផង់ជា សេចក្តីសោមនស្សទេ) ។ ពាក្យផ្ទុយ ទោមនស្ស ។ សោមនស្សវេទនា (ម៉ៈ ន័ស-សៈ--) ដំណើរទទួលអារម្មណ៍ជា សោមនស្ស ។ ពាក្យផ្ទុយ ទោមនស្សវេទនា ។ល។

ថ្វាយបង្គំអ្នកនោះ ឬឲ្យអ្នកនោះថ្វាយបង្គំខ្លួនដូចម្ដេចកើត កម្ម នោះ មិនកើតជាអ្វីទេ" ។

វិមលាទេវី ៖

"ម្នាលបណ្ឌិត ដំណើរនុ៎ះដូចអ្នកពោលមែន អ្នកពោលពាក្យពិត អ្នកទោសដែលត្រូវគេសម្លាប់មិនគប្បីថ្វាយបង្គំពេជ្ឈឃាត ឬ ពេជ្ឈឃាត ក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណា គប្បីថ្វាយបង្គំអ្នកនោះ ឬឲ្យអ្នកនោះ ថ្វាយបង្គំខ្លួនដូចម្ដេចកើត កម្មនោះមិនកើតជាអ្វីទេ" ។

វិធុរបណ្ឌិត ៖

"វិមាននេះ ទាំងឫទ្ធិ សេចក្ដីរុងរឿង កម្លាំងកាយ សេចក្ដីព្យាយាម និងការកើតក្នុងភពនាគរបស់ព្រះនាង មិនទៀង តែដូចជា របស់ ទៀង បពិត្រនាគកញ្ញា ខ្ញុំព្រះអង្គសូមសួរសេចក្ដីនុ៎ះ នឹងព្រះនាង ថា វិមាននេះ ព្រះនាងបានហើយដោយប្រការដូចម្ដេច ។ វិមាន នេះព្រះនាងបាន ព្រោះអាស្រ័យភពនាគ ឬកើតអំពីរដូវប្រែប្រួល ឬព្រះនាងកសាងដោយព្រះអង្គឯង ឬមួយទេវតាថ្វាយ បពិត្រ ព្រះនាគី វិមាននេះព្រះនាងបានហើយ ដោយប្រការណា សូម ព្រះនាងប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំព្រះអង្គ ដោយប្រការដូច្នោះ" ។

វិមលាទេវី ៖

"វិមាននេះមិនមែនខ្ញុំបាន ព្រោះអាស្រ័យភពនាគ មិនមែនកើតអំពីរដូវប្រែប្រួល មិនមែនខ្ញុំធ្វើខ្លួនឯង ទាំងមិនមែនទេវតាឲ្យទេ វិមាននេះ ខ្ញុំបានដោយបុញ្ញកម្មមិនអាក្រក់របស់ខ្លួន" ។

វិធុរបណ្ឌិត ៖

"អ្វីជាវត្តរបស់ព្រះនាង ? អ្វីជាព្រហ្មចរិយៈរបស់ព្រះនាង ? បពិត្រនាគី ឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាម និងការកើតក្នុងភពនាគ ទាំងវិមានធំរបស់ព្រះនាងនេះ នេះជាផលនៃកម្មដែលព្រះនាងសន្សំល្អហើយ ដូចម្តេច ?"

វិមលាទេវី ៖

"ខ្ញុំនិងស្វាមី ទាំងពីរនាក់ កាលនៅក្នុងមនុស្សលោក ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំដូចជាអណ្តូងនៃមហាជន ទាំងពួកសមណៈនិងព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ ។ ខ្ញុំកាលនៅក្នុងកាលចម្បានគរនោះ បានឲ្យទានដោយគោរព គឺឲ្យកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសម្នាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាល

ដេក បាយ និងទឹក ។ នោះជាវត្ត នោះជាព្រហ្មចរិយៈរបស់ខ្ញុំ នែអ្នកប្រាជ្ញ ឯឫទ្ធិ សេចក្ដីរុងរឿង កម្លាំងកាយ សេចក្ដីព្យាយាម និងការកើតក្នុងភពនាគ ទាំងវិមានធំរបស់ខ្ញុំនេះ នេះជាផលនៃកម្មដែលខ្ញុំសន្សំល្អហើយនោះ" ។

វិធុរបណ្ឌិត ៖

"បើវិមាននេះ គឺព្រះនាងបានមកដោយបុញ្ញកម្មយ៉ាងនេះ ឈ្មោះថា ព្រះនាងជ្រាបកំណើតនៃផលរបស់បុណ្យ ព្រោះហេតុនោះ សូមព្រះនាងកុំប្រហែស សូមប្រព្រឹត្តធម៌ ជាហេតុឲ្យបានគ្រប់គ្រងវិមាននេះតទៅទៀត" ។

វិមលាទេវី ៖

"នែអាមាត្យជាបណ្ឌិត ខ្ញុំគប្បីឲ្យបាយនិងទឹកដល់ពួកសមណៈ និងព្រាហ្មណ៍ណា ពួកសមណៈនិងព្រាហ្មណ៍នោះ មិនមានក្នុងភពនាគនេះទេ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្ដីនុ៎ះ ដែលជាហេតុឲ្យខ្ញុំនៅគ្រប់គ្រងវិមានតទៅ" ។

វិធុរបណ្ឌិត ៖

"ពួកនាគី គឺបុត្រ ស្វាមី និងអ្នករស់នៅដោយសារ ដែលចូលមកកើតក្នុងភពនាគនេះ សូមព្រះនាងជាអ្នកមិនប្រទូស្ត ក្នុងពួកនាគនោះ ដោយពាក្យឬដោយការងារ អស់កាលជានិច្ច ។ បពិត្រនាគី សូមព្រះនាងរក្សានូវសេចក្តីមិនប្រទូស្តដោយពាក្យ ឬដោយការងារយ៉ាងនេះចុះ ព្រះនាងនឹងឋិតនៅក្នុងវិមាននេះរហូតអស់ព្រះជន្មាយុហើយ នឹងបានទៅកាន់ទេវលោកជាន់ខាងលើ អំពីភពនាគនេះ ។

វិមលាទេវី ៖

"អ្នកជាអាមាត្យរបស់ព្រះរាជាណា ព្រះរាជាដ៏ប្រសើរនោះ បើអត់ពីអ្នកហើយ រមែងសោកស្តាយដោយពិត បុរសសូម្បីត្រូវសេចក្តីទុកគ្របសង្កត់ ឬសូម្បីមានជំងឺធ្ងន់ បើបានជួបនឹងអ្នកហើយ ក៏នឹងបានសុខវិញ" ។

វិធុរបណ្ឌិត ៖

"បពិត្រនាគី ព្រះនាងពោលធម៌របស់សប្បុរស ជាធម៌ប្រសើរ ជាចំណែកនៃប្រយោជន៍ដែលសន្សំល្អដោយពិត ឯសេចក្តីវិសេសរបស់បណ្ឌិតទាំងឡាយបែបខ្ញុំព្រះអង្គ រមែងប្រាកដក្នុងអន្តរាយទាំងឡាយបែបនេះ" ។

វិមលាទេវី ៖

"អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះ បានអ្នកមកដោយទទេឬ អ្នកចូរប្រាប់យើងមកចុះ បុណ្ណយក្សនេះ ឈ្នះអ្នកដោយល្បែងភ្នាល់ឬ បុណ្ណកយក្សនេះបាននិយាយថា វិធុរបណ្ឌិត ខ្ញុំបាននាំមកដោយធម៌ តើអ្នកមកនៅក្នុងកណ្ដាប់ដៃនៃបុណ្ណកយក្សនេះ ដោយប្រការដូចម្ដេច ?" ។

វិធុរបណ្ឌិត ៖

"ព្រះរាជារបស់ខ្ញុំព្រះអង្គណា ជាធំក្នុងក្រុងឥន្ទបត្តដែនកុរុនោះ បុណ្ណកយក្សនេះ បានឈ្នះល្បែងស្កាទឹងព្រះរាជានោះដោយការភ្នាល់ ព្រះរាជាដែលបុណ្ណកយក្សឈ្នះហើយនោះ បានប្រទានខ្ញុំព្រះអង្គដល់បុណ្ណកយក្សនេះ បុណ្ណកយក្សឈ្មោះថាបានខ្ញុំព្រះអង្គមកដោយធម៌ មិនមែនដោយការកំហែងទេ" ។

ក្រោយពេលទ្រង់សណ្ដាប់ពាក្យព្រះមហាសត្តហើយ ព្រះនាងវិមលា បានចាប់ព្រះមហាសត្តឲ្យងូតដោយទឹកក្រអូប ១.០០០ ក្អម ។ កាលងូតហើយ ព្រះនាងបានប្រទាននូវសំពត់ទិព្វ គ្រឿងក្រអូបនិងផ្កាកម្រងទិព្វ ជាដើម ដល់ព្រះមហាសត្ត ។ កាលតុបតែងហើយ ព្រះនាងបានអញ្ជើញឲ្យបរិភោគនូវភោជនទិព្វ ។ ក្រោយពេលបរិភោគហើយ

ព្រះមហាសត្វ បានអង្គុយលើធម្មាសនៈដែលគេក្រាលតុបតែងវិចិត្រ ហើយលោកសម្ដែងនូវព្រះធម៌ ដោយលំនាំព្រះពុទ្ធអង្គ ។

## បុណ្ណកយក្សបាននាងឥរន្ធតី

វរុណនាគ បានសួរប្រស្នានឹងវិធុរបណ្ឌិត យ៉ាងណា ព្រះនាងវិមលា ក៏បានសួរប្រស្នានឹងវិធុរបណ្ឌិតយ៉ាងនោះដែរ ។

វិធុរបណ្ឌិត ជាអ្នកប្រាជ្ញ ដែលវរុណនាគត្រាស់សួរហើយ ក៏បានញុំាំងវរុណនាគឲ្យត្រេកអរ យ៉ាងណា វិធុរបណ្ឌិត ជាអ្នកប្រាជ្ញដែលព្រះនាងវិមលាសួរហើយ ក៏បានញុំាំងព្រះនាង ឲ្យត្រេកអរយ៉ាងនោះដែរ ។

វិធុរបណ្ឌិត ជាអ្នកប្រាជ្ញ លុះដឹងច្បាស់ថានាគរាជដ៏ប្រសើរ និងនាងនាគកញ្ញាទាំងពីរព្រះអង្គនោះ មានព្រះទ័យរីករាយហើយ ក៏មិនតក់ស្លុត មិនខ្លាច មិនព្រឺរោម បានទូលវរុណនាគរាជដូច្នេះថា ៖

"មា រោធយិ នាគ អាយាហមស្មិ, យេន តវត្ថោ ឥធំ សរីរំ;
ហទយេន មំសេន ករោហិ កិច្ចំ, សយំ ករិស្សាមិ យថាមតិ តេ" ។

"បពិត្រនាគ ព្រះអង្គកុំខ្វាល់ឡើយ ទូលព្រះបង្គំនេះហើយ ដែលព្រះអង្គត្រូវការ នេះសរីរៈ សូមព្រះអង្គធ្វើកិច្ចដោយសាច់បេះដូងចុះ ខ្ញុំនឹងធ្វើតាមអធ្យាស្រ័យរបស់ព្រះអង្គដោយខ្លួនឯង" ។

នាគរាជ ត្រាស់ថា ៖

"បញ្ញា ហវេ ហទយំ បណ្ឌិតានំ, តេ ត្យម្ហ បញ្ញាយ មយំ សុតុដ្ឋា;
អនូននាមោ លភតជ្ជ ទារំ, អជ្ជេវ តំ កុរុយោ ចាបយាតុ" ។

"បញ្ញាហ្នឹងឯង ជាបេះដូងរបស់បណ្ឌិតទាំងឡាយ យើងទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយប្រាជ្ញារបស់អ្នក យក្សមានឈ្មោះមិនខ្វះខាត គឺបុណ្ណកៈ ចូរបានភរិយាក្នុងថ្ងៃនេះចុះ ចូរនាំអ្នកឲ្យទៅដល់ដែនកុរុវិញ ក្នុងថ្ងៃនេះចុះ" ។

លុះពេលយ៉ាងនេះហើយ វរុណនាគរាជបានឲ្យកូនក្រមុំឥរន្ទតីដល់បុណ្ណកយក្ស ។ បុណ្ណកៈ បាននាងហើយ មានចិត្តត្រេកអរ រីករាយ ចរចាជាមួយនឹងវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ ដូច្នេះថា ៖

"ភរិយាយ មំ ត្វំ អការិ សមង្គិំ, អហញ្ច តេ វិធុរ ករោមិ កិច្ចំ;
ឥទញ្ច តេ មណិរតនំ ទទាមិ, អជ្ជេវ តំ កុរុយោ ចាបយាមិ"។

"ភរិយាដែលខ្ញុំបានមកនេះ គឺអាស្រ័យដោយអ្នក បពិត្រវិធុរបណ្ឌិត ខ្ញុំសូមធ្វើកិច្ចតបគុណដល់អ្នក ខ្ញុំនឹងឲ្យកែវមណីនេះដល់អ្នក ហើយខ្ញុំនឹងនាំអ្នកត្រឡប់ទៅកាន់ដែនកុរុវិញ ក្នុងថ្ងៃនេះឯង" ។

គ្រានោះ ព្រះមហាសត្វ បានធ្វើសេចក្ដីសរសើរចំពោះបុណ្ណកៈ ៖

"អជេយ្យមេសា តវ ហោតុ មេត្តិ, ភរិយាយ កច្ចាន បិយាយ សទ្ធិំ;
អានន្ទិ វិត្តោ សុមនោ បតីតោ, ទត្វា មណិំ មញ្ច នយិន្ទបត្តំ" ។

"ម្នាលកច្ចានៈ មេត្រីជាគុណជាតិគឺបុគ្គលផ្ចាញ់មិនបាននេះ ចូរមានដល់អ្នក ព្រមទាំងភរិយាជាទីស្រឡាញ់ អ្នកមានចិត្តត្រេកអរទូទៅ មានចិត្តល្អ មានចិត្តរីករាយឲ្យកែវមណីដល់ខ្ញុំហើយ ចូរនាំខ្ញុំទៅកាន់ឥន្ទបត្តនគរចុះ" ។

## បុណ្ណកៈដឹកវិធុរៈទៅមនុស្សលោកវិញ

ឮដូច្នោះ បុណ្ណកៈបានធ្វើតាមយ៉ាងនោះ គេឡើងជិះសេះអាជានេយ្យ មានវណ្ណៈមិនថោកទាប អញ្ជើញវិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់ពួកអ្នកដែនកុរុ ឲ្យអង្គុយលើអាសនៈអំពីខាងមុខ ហោះទៅឰដ៏អាកាសវេហាស៍ ។ ធម្មតាចិត្តរបស់មនុស្ស រមែងស្ទុះទៅកាន់អារម្មណ៍ក្នុងទីឆ្ងាយ យ៉ាងណា រីឯដំណើរសន្ទុះរបស់សេះអាជានេយ្យនោះ ឆាប់រហ័សក្រៃលែង ជាងចិត្តនោះ យ៉ាងនោះទៅទៀត បុណ្ណកៈយក្សនោះ នាំវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ ទៅកាន់ឥន្ទបត្តនគរដែលឃើញច្បាស់ ទាំងព្រៃស្វាយ ក៏ស្រស់គួរជាទីរីករាយ ដោយចំណែក ៗ ។

ក្នុងថ្ងៃនោះឯង ព្រះរាជា ទ្រង់បានយល់សុបិនក្នុងវេលាទៀបភ្លឺ ។ សុបិននោះ មានសភាពបែបនេះ ៖

"នៅទៀបទ្វារព្រះរាជនិវេសន៍[៦៦] មានឈើធំមួយដើម តួដើមគឺប្រាជ្ញា មែកសាខាសម្រេចអំពីសីល ផ្លែរសជាតិឆ្ងាញ់ជាបញ្ចគោរស បិទបាំងដោយដំរី គោ សេះ ដែលតុបតែងខ្លួនវាយ៉ាងស្អាត ។ មហាជន ធ្វើនូវសក្ការៈដល់ដើមឈើនោះ ហើយឈរផ្គងអញ្ជលីនមស្ការ ។ គ្រានោះ ស្រាប់តែមានបុរសខ្មៅម្នាក់ ឫកពារឃោរឃៅ ស្លៀកខោក្រហម ពាក់ក្រវិលផ្កាពណ៌ក្រហម ដៃកាន់អាវុធ រត់តម្រង់ចូលមកកាត់នូវដើមឈើនោះ ព្រមទាំងឫស ។ កាលដែលមហាជនកំពុងតែខ្សឹកខ្សួល បុរសនោះទាញដើមឈើយកទៅ ស្រាប់តែមិនយូរប៉ុន្មាន គេក៏នាំ ដើមឈើនោះមកវិញ តាំងទុកក្នុងទីដើម ហើយចៀសចេញបាត់ទៅ ។ កាលបើទ្រង់ត្រិះរិះគ្រប់ជ្រុងជ្រោយនូវសុបិននោះ រួចហើយ ព្រះរាជាធ្វើសេចក្ដីសន្និដ្ឋានតែមួយអង្គឯងថា ដើមឈើធំ មិនមែនអ្នកដទៃឡើយ គឺលោកវិធុរបណ្ឌិត ។ បុរសខ្មៅកាត់ដើមឈើទាំងឫស ខណៈមហាជនកំពុងតែ ខ្សឹកខ្សួល មិនគឺអ្នកដទៃណាឡើយ គឺមាណពដែលចាប់លោកបណ្ឌិតយកទៅនោះឯង ។ គេនាំឈើមកវិញ ហើយតាំងទុកក្នុងទីដើម គឺមាណពនោះ ប្រាកដជានាំ

[៦៦] (ន.) បា. លំនៅរបស់ព្រះរាជា (ព្រះរាជមន្ទី ឬព្រះរាជវាំង) ។

លោកបណ្ឌិតត្រឡប់មកវិញ ដាក់ត្រង់ទ្វារធម្មសភាហើយ គេនឹងចៀសចេញទៅ ។ ក្នុងថ្ងៃនេះ ពួកយើងទៀងតែឃើញលោកបណ្ឌិតមកវិញពុំខាន" ។

ទ្រង់ធ្វើសេចក្ដីសន្និដ្ឋានដូច្នេះហើយ ទ្រង់មានសោមនស្សចេញបញ្ជាឲ្យគេតុបតែងលម្អទូទៅទាំងនគរ រៀបធម្មសភា ក្រាលធម្មាសនៈ ក្នុងមណ្ឌប[៦៧]កែវដែលល្អឆើតឆាយ ហើយស្ដេចមានព្រះរាជា ១០១ អង្គ គណៈមន្ត្រី អ្នកក្រុង អ្នកជនបទ ចោមរោម ជាបរិវារ ស្ដេចយាងមកលួងលោមមហាជនថា ៖

"ថ្ងៃនេះ អ្នកទាំងឡាយនឹងឃើញលោកបណ្ឌិត កុំសោកស្ដាយអ្វីឡើយ" ។

ហើយព្រះអង្គក៏គង់ប្រថាប់ក្នុងធម្មសភា ទន្ទឹងរង់ចាំមើលនូវដំណើរមកវិញរបស់លោកបណ្ឌិត ។ ចំណែកអស់លោកមន្ត្រីជាដើម ក៏នាំគ្នាអង្គុយដែរ ។ ស្រាប់តែរំពេចនោះ បុណ្ណកៈបន្ទាបសេះឲ្យលោកបណ្ឌិតចុះ ដាក់ត្រង់កណ្ដាលបរិស័ទហ្នឹងឯង ទៀបទ្វារធម្មសភា មិននិយាយ

[៦៧] (ន.) (សំ.),(បា.) (ម័ន-ដប់) បារាំ, តែនតឹ, រោងលាត (សម្រាប់ប្រើការបណ្ដោះអាសន្នមួយដងមួយកាល) ។ ខ្មែរច្រើនហៅចំពោះប្រាសាទតូចៗ ដែលមានដំបូលជាកំពូលរាងច្រឡោ សណ្ឋានមកុដ វិចិត្រដោយក្បាច់រចនាផ្សេងៗ : សង់មណ្ឌប, ប្រាសាទមណ្ឌប ។

អ្វីមួយម៉ាត់ ក៏ប្រញាប់បំផាយសេះ ហោះទៅឰដ៏អាកាសវេហាស៍ ដឹកនាងឥរន្ធតី ហួសទៅដល់ទេវនគរខ្ជួនតែម្ដង ។

**វិធុរៈក្រាបទូលប្រវត្តិដំណើរទៅភពនាគ**

ព្រះរាជា ទតឃើញមហាសត្តនោះហើយ ព្រះអង្គមានព្រះហឫទ័យសោមនស្សដ៏ក្រៃលែង ទ្រង់ក្រោកឡើងយកព្រះហស្តស្រវាឱប ទ្រង់មិនបានឲ្យកម្រើក ហើយអញ្ជើញព្រះមហាសត្តឲ្យអង្គុយលើអាសនៈក្នុងកណ្ដាលធម្មសភា ចំពោះព្រះភក្ត្រព្រះអង្គ ។

គ្រានោះ ព្រះរាជា រីករាយស្រស់ស្រាយជាមួយនឹងវិធុរបណ្ឌិត ទ្រង់ធ្វើនូវបដិសណ្ឋារៈដ៏ផ្អែមល្ហែមថា ៖

"ត្វំ នោ វិនេតាសិ រថំវ នទ្ធំ, នន្ទន្តិ តំ កុរុយោ ទស្សនេន;
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ, កថំ បមោក្ខោ អហុ មាណវស្ស"។

"អ្នកជាអ្នកណែនាំយើង ដូចនាយសារថីនាំយករថដែលបាត់ទៅមកឲ្យអ្នកដែនកុរុទាំងឡាយ ត្រេកអរ ព្រោះបានឃើញអ្នក យើងសួរហើយ អ្នកចូរប្រាប់សេចក្ដីនុ៎ះ អ្នករួចអំពីមាណព ដោយប្រការដូចម្ដេច" ?

ព្រះមហាសត្ត ឆ្លើយតបថា ៖

"យំ មាណវោត្យាភិវទី ជនិន្ទ, ន សោ មនុស្សោ នរវីរសេដ្ឋ;

យទិ តេ សុតោ បុណ្ណកោ នាម យក្ខោ,
រញ្ញោ កុវេរស្ស ហិ សោ សជិព្វោ ។

“បពិត្រព្រះអង្គជាធំជាងជន មានព្យាយាមដ៏ប្រសើរជាងជន ព្រះអង្គត្រាស់ហៅបុរសណាថាមាណព តាមពិតបុរសនោះមិនមែនជាមនុស្សទេ គេគឺជាយក្ស ឈ្មោះថាបុណ្ណកៈ ព្រះអង្គក៏ធ្លាប់បានឮមកហើយ បុណ្ណកយក្សនោះជាអាមាត្យនៃព្រះបាទកុវេរៈ” ។

“ភូមិន្ធរោ វរុណោ នាម នាគោ, ព្រហា សុចី វណ្ណពលូបបន្នោ;
តស្សានុជំ ធីតរំ កាមយានោ, ឥរន្ធតី នាម សា នាគកញ្ញា ។

“មានស្តេចនាគមួយ ឈ្មោះវរុណៈ ទ្រង់គ្រប់គ្រងផែនដី មានទំហំនិងកម្ពស់ស្អាត បរិបូណ៌ដោយពណ៌សម្បុរ និងកម្លាំង ឯបុណ្ណកយក្សនោះ ចង់បានធីតាជាអនុជាត[៦៨]នៃវរុណនាគនោះ ធ្វើជាប្រពន្ធ នាងនាគកញ្ញានោះ ឈ្មោះឥរន្ធតី” ។

“តស្សា សុមជ្ឈាយ បិយាយ ហេតុ, បតារយិត្ថ មរណាយ មយ្ហំ;
សោ ចេវ ភរិយាយ សមង្គិភូតោ, អហញ្ច អនុញ្ញាតោ មណិ ច លទ្ធោ”។

“បុណ្ណកយក្ស ព្យាយាមសម្លាប់ខ្ញុំព្រះអង្គ ព្រោះហេតុនៃនាងឥរន្ធតីនោះ នាងមានចង្កេះល្អគួរជាទីស្រឡាញ់ ឥឡូវនេះ

[៦៨] (ន.) អ្នកកើតក្រោយ, អ្នកកើតបន្ទាប់ ។

បុណ្ណកយក្សនោះ បានទាំងឥរន្ទតីនោះជាភរិយាតាមក្ដីប្រាថ្នា ចំណែកខ្ញុំព្រះអង្គ ក៏បុណ្ណកយក្សនោះ បានបូជាហើយនូវកែវមណី ហើយបានជូនខ្ញុំព្រះអង្គត្រឡប់មកនគរនេះវិញ ក្រាបទូល" ។

វិធុរបណ្ឌិត ក៏បានថ្វាយនូវកែវមណីនោះ ដល់ព្រះមហាក្សត្រ ដោយរៀបរាប់ដូច្នេះថា "បពិត្រមហារាជ ពិតណាស់ នាគរាជនោះជ្រះថ្លានឹងដំណោះស្រាយនូវចតុប្បោសថិកប្រស្នា ហើយបានបូជាទូលបង្គំដោយកែវមណី រួចគេវិលទៅកាន់ភពនាគវិញ ។ ព្រះទេវីឈ្មោះវិមលាកាលមិនឃើញកែវមណីនោះ ក៏បានសួររកថា តើកែវមណីនៅឯណាព្រះសម្មតិទេព ? នាគរាជ បានសរសើរភាពជាធម្មកថិក[៦៩] នៃទូលបង្គំ ។ ស្ដីពីព្រះនាងវិមលាទេវី កាលបើបានស្ដាប់ការរៀបរាប់ហើយ ស្រាប់តែចង់ស្ដាប់នូវធម្មកថារបស់ទូលបង្គំដែរ ក៏ក្លែងពុតធ្វើជាកើតរោគចាញ់កូន ភ្នក[៧០]នឹកចង់សោយបេះដូងទូលបង្គំ ។ នាគរាជជាស្វាមី ហេតុតែមិនយល់ន័យរបស់ភរិយា ក៏ប្រាប់ធីតាឈ្មោះឥរន្ទតីថា ព្រះមាតារបស់

[៦៩] (ន.) (បា.),(សំ.) (ធ័ម-មៈកៈ ថិក) (ធម៌កថិក) អ្នកសំដែងធម៌ ។ ខ្មែរប្រើពាក្យនេះជាងារនៃភិក្ខុអ្នកចេះសំដែងធម៌ ថ្នាក់ជាឋានានុក្រម ជាសហការីនៃព្រះរាជាគណៈជាចៅអធិការវត្តធំ ៗ ក្នុងព្រះរាជធានី ឬជាសហការីនៃមេគណ កាលបើត្រូវការឲ្យមាន : ព្រះធម្មកថិក សហការីនៃ...។

[៧០] (កិ.) ផ្ដួចគំនិតនឹកដល់, ផ្នួកនឹកដល់, ចាប់ភ្ញឹកនឹកដល់ : ភ្នកនឹក ។

បុត្រី កើតចំណង់ប្លែកចង់សោយបេះដូងវិធុរបណ្ឌិត ចូរបុត្រីរកប្តីបែប ណាដែលមានសមត្ថភាពអាចយកបេះដូងរបស់លោកបណ្ឌិតនោះ បាន ។ កាលនាងឥរន្ទតី កំពុងតែស្វែងរក ក៏បានជួបយក្សឈ្មោះ បុណ្ណកៈ ដែលត្រូវជាក្មួយរបស់ស្តេចវេស្សវ័ណ លុះដឹងថាបុណ្ណកៈ ចាប់ចិត្តចំពោះខ្លួន នាងក៏បាននាំគេទៅកាន់សម្នាក់ព្រះបិតា ។ គ្រានោះ ឪពុកនាង ក៏បង្គាប់បុណ្ណកៈថា បើឯងចង់បានឥរន្ទតីកូនយើងជាភរិយា លុះណាតែឯងយកបេះដូងរបស់វិធុរបណ្ឌិត ឲ្យបានមកសិន ។ បុណ្ណកៈ ហេតុតែឈ្លក់ក្នុងអន្ទង់កាមទេព ជាមួយនឹងស្រីមានចង្កេះរៀវ ក៏ទៅ យកកែវមណីជាគ្រឿងប្រើប្រាស់របស់ស្តេចចក្រពត្តិ អំពីភ្នំវេបុល្លបព៌ត មកលេងល្បែងបាស្កាជាមួយនឹងព្រះអង្គ ឈ្នះបានទូលបង្គំទៅ ។ រីឯ ទូលបង្គំបានឲ្យគេស្នាក់នៅក្នុងផ្ទះទូលបង្គំ អស់រយៈពេល ៣ ថ្ងៃ ទាំង បានធ្វើនូវសក្ការៈដ៏ធំ ចំពោះគេផងដែរ ។ គេបានឲ្យទូលបង្គំ ចាប់ កន្ទុយសេះ ហើយគេបំបោលគ្រវាត់ត្រង់ដើមឈើផង ត្រង់ភ្នំផង នៅឯ ព្រៃហិមពាន្ត បំណងដើម្បីឲ្យទូលបង្គំស្លាប់ ។ កាលមិនអាចឲ្យទូលបង្គំ ស្លាប់ គេក៏បោះពួយទៅចំមុខខ្យល់វេរម្ភវាត ដែលជាគំនរខ្យល់ថ្នាក់ទី ៧ ។ ទូលបង្គំនៅតែមិនស្លាប់ទៀត គេក៏ដាក់ទូលបង្គំនៅលើកំពូលភ្នំ កាឡាគិរី កម្ពស់ ៦០ យោជន៍ តាមលំដាប់ ហើយក្លែងធ្វើជារូបនេះផង នោះផង មានរូបតោជាដើម មកបន្ទាចទូលបង្គំឲ្យស្លាប់ ។ កាលមិន អាចសម្លាប់ទូលបង្គំបាន ទូលបង្គំក៏សួររកហេតុដើមទង ដែលគេចង់

សម្លាប់ទូលបង្គំ គេក៏ប្រាប់ ។ គ្រានោះ ទូលបង្គំបានសម្ដែងសាធុនរធម៌ឲ្យគេស្ដាប់ ។ គេស្ដាប់ហើយ មានចិត្តជ្រះថ្លា ចង់នាំទូលបង្គំមកទីនេះវិញឆាប់ ។ ប៉ុន្ដែទូលបង្គំ បានឲ្យគេជូនទៅឲ្យដល់ភពនាគតែម្ដងចុះបំណាច់តែជ្រុលដំណើរទៅហើយ ។ នៅពេលដល់ភពនាគ ទូលបង្គំបានសម្ដែងធម៌ដល់នាគរាជផង ដល់ព្រះនាងវិមលាទេវីផង ។ បន្ទាប់មក នាគរាជនិងព្រះនាងវិមលាទេវី និងនាគបរិស័ទ ក៏ជ្រះថ្លាគ្រប់គ្នា ៗ ។ ក្នុងពេលទូលបង្គំ ស្នាក់នៅភពនាគអស់ ៦ ថ្ងៃ, នាគរាជបានថ្វាយធីតាឥរន្ទតី ដល់បុណ្ណកៈ ។ បុណ្ណកៈ កាលបាននាងហើយ ក៏មានចិត្តជ្រះថ្លាបូជាទូលបង្គំ ដោយកែវមណីនេះ ។ នាគរាជ បង្គាប់ឲ្យគេនាំទូលបង្គំមកវិញ ។ គេបានរៀបសេះសិន្ធពមនោម័យ ជិះគ្នា ៣ នាក់ ខ្លួនគេផ្ទាល់ជិះកណ្ដាល ឲ្យប្រពន្ធគេឥរន្ទតីជិះពីក្រោយ ឲ្យទូលបង្គំជិះពីមុខហើយបរមកទីនេះ ចុះក្នុងកណ្ដាលបរិស័ទ ឥឡូវគេយកនាងឥរន្ទតីប្រពន្ធគេទៅកាន់នគររបស់ខ្លួនហើយ ។ បពិត្រមហារាជ តាមប្រការដូចដែលពោលមកនេះ សឲ្យឃើញថា បុណ្ណកៈនោះហេតុតែសេចក្ដីស្រឡាញ់ធំធេង ចំពោះនាងឥរន្ទតី គេបានព្យាយាមឲ្យទូលបង្គំស្លាប់ ។ ប៉ុន្ដែបើទោះបីជាយ៉ាងនេះក៏ដោយ គេបានរួមរស់នឹងភរិយា ក៏ដោយសារតែទូលបង្គំដែរ ទាំងនាគរាជដែលអនុញ្ញាតឲ្យទូលបង្គំមកវិញនេះក៏ដោយសារតែស្ដាប់ធម្មកថារបស់ទូលបង្គំ ហើយជ្រះថ្លា ។ បពិត្រព្រះអង្គ នេះជាកែវមណីគ្រឿងប្រើប្រាស់របស់ស្ដេចចក្រពត្តិ ដែលឲ្យ

*សម្រេចសេចក្ដីប្រាជ្ញាគ្រប់យ៉ាង ដែលទូលបង្គំបានអំពីសម្នាក់របស់បុណ្ណកៈនោះ សូមព្រះសម្មតិទេពមេត្តាទទួលនូវកែវមណីនេះទុកជាព្រះរាជទ្រព្យ ក្រាបទូល" ។*

## ពិធីអបអរសាទរចំពោះវិធុរបណ្ឌិត

*គ្រានោះ ព្រះរាជាមានបំណងប្រាប់នូវសុបិនដែលខ្លួនទ្រង់បានឃើញនាវេលាទៀបភ្លឺ ដល់អ្នកក្រុងទាំងឡាយ ហើយពោលថា "ហៃអស់លោក ចូរអ្នកនគរស្ដាប់នូវសុបិនដែលយើងបានឃើញ ក្នុងថ្ងៃនេះ" រួចទ្រង់ត្រាស់ថា ៖*

"រុក្ខោ ហិ មយ្ហំ បទ្វារេ សុជាតោ, បញ្ញាក្ខន្ធោ សីលមយស្ស សាខា
អត្ថេ ច ធម្មេ ច ឋិតោ និចាកោ, គវប្ផលោ ហត្ថិគវាស្សឆន្នោ" ។

*"ដើមឈើដុះទៀបទ្វារដំណាក់របស់យើង មានដើមសម្រេចដោយប្រាជ្ញា មែករបស់ឈើនោះសម្រេចដោយសីល ដើមឈើនោះ សម្រេចដោយប្រាជ្ញាខ្ជាប់ខ្ជួន តាំងនៅក្នុងអត្ថនិងធម៌ មានផ្លែជាបញ្ចគោរស ដេរដាសដោយដំរីគោនិងសេះ" ។*

"នច្ចគីតតូរិយាភិនាទិតេ, ឧច្ឆិជ្ជ សេនំ បុរិសោ អហាសិ;
សោ នោ អយំ អាគតោ សន្និកេតំ, រុក្ខស្សិមស្សាបចិតិំ ករោថ។

*“កាលដើមឈើនោះ គឹកកង ដោយការរាំ ការច្រៀង និងតន្ត្រី បុរសខ្មៅម្នាក់ កាត់ដើមឈើនោះ ហើយញ៉ាំងសេនាឲ្យរត់ទៅ បណ្ឌិតនេះទុកដូចជាដើមឈើរបស់យើងនោះ មកកាន់លំនៅរបស់ខ្លួនវិញ ហើយអ្នកទាំងឡាយ ចូរធ្វើសេចក្ដីកោតក្រែងដើមឈើនេះ” ។*

“យេ កេចិ វិត្តា មម បច្ចយេន, សព្វេ តេ បាតុករោន្តុ អជ្ជ;
តិព្វានិ កត្វាន ឧបាយនានិ, រុក្ខស្សិមស្សាបចិតិំ ករោថ ។

*“ជនទាំងឡាយណានីមួយ មានចិត្តត្រេកអរ ដោយយសព្រោះបច្ច័យនៃយើង ពួកជនទាំងអស់នោះចូរធ្វើចិត្តរបស់ខ្លួនឲ្យប្រាកដក្នុងថ្ងៃនេះចុះ អ្នកទាំងឡាយធ្វើបណ្ណាការឲ្យច្រើន ចូរធ្វើសេចក្ដីកោតក្រែង ដល់ដើមឈើនេះចុះ” ។*

“យេ កេចិ ពន្ធា មម អត្ថិ រដ្ឋេ, សព្វេ តេ ពន្ធនា មោចយន្តុ;
យថេវយំ ពន្ធនស្មា បមុត្តោ, ឯវមេតេ មុញ្ចរេ ពន្ធនស្មា ។

*“ពួកសត្វណានីមួយ ដែលគេចងក្នុងដែនរបស់យើង ពួកសត្វទាំងអស់នោះ ចូរឲ្យរួចពីចំណង វិធុរបណ្ឌិតនេះរួចពីចំណង យ៉ាងណា ពួកសត្វទាំងនុ៎ះ គប្បីរួចពីចំណង យ៉ាងនោះ” ។*

“ឧន្នង្គលា មាសមិមំ ករោន្តុ, មំសោទនំ ព្រាហ្មណា ភក្ខយន្តុ;
អមជ្ជបា មជ្ជរហា បិវន្តុ, បុណ្ណាហិ ថាលាហិ បលិស្សុតាហិ ។

"ចូរពួកប្រជាជនទុកដាក់នង្គ័ល ធ្វើមហោស្រព អស់មួយខែនេះចុះ ពួកព្រាហ្មណ៍ ចូរបរិភោគបាយលាយដោយសាច់ ពួកអ្នកមិនផឹកទឹកស្រវឹង គួរផឹកទឹកស្រវឹង ចូរផឹកដោយភាជន៍ដ៏ពេញហូរហៀរ" ។

"មហាបថំ និច្ច សមវ្ហយន្តុ, តិព្ពញ្ច រក្ខំ វិទហន្តុ រដ្ឋេ;
យថាញ្ញមញ្ញំ ន វិហេឋយេយ្យុំ, រុក្ខស្មិមស្សាបចិតិំ ករោថ" ។

"ស្រីពេស្យាទាំងឡាយ អាស្រ័យផ្លូវធំ ចូរហៅរកបុរសអ្នកត្រូវការអស់កាលជានិច្ចចុះ មួយទៀត រាជបុរសទាំងឡាយ ចូរចាត់ចែងការរក្សា ឲ្យមាំមួនក្នុងដែន កុំឲ្យពួកមនុស្សបៀតបៀនគ្នានឹងគ្នា អ្នកទាំងឡាយចូរធ្វើសេចក្ដីកោតក្រែងចំពោះដើមឈើនោះ" ។

ព្រះរាជា មានព្រះរាជឱង្ការយ៉ាងនេះ ៖

"ឱរោធា ច កុមារា ច, វេសិយានា ច ព្រាហ្មណា;
ពហុំ អន្នញ្ច បានញ្ច, បណ្ឌិតស្សាភិហារយុំ។
ហត្ថារោហា អនីកដ្ឋា, រថិកា បត្តិការកា;
ពហុំ អន្នញ្ច បានញ្ច, បណ្ឌិតស្សាភិហារយុំ។

"ពួកស្នំ ពួករាជកុមារ ពួកឈ្មួញនិងពួកព្រាហ្មណ៍ នាំយកបាយនិងទឹកដ៏ច្រើន មកជូនវិធុរបណ្ឌិត ។ ពលដំរី ពលសេះ ពលរថពលថ្មើរជើង នាំយកបាយនិងទឹកដ៏ច្រើន មកជូនវិធុរបណ្ឌិត" ។

"សមាគតា ជានបទា, នេគមា ច សមាគតា;
ពហុំ អន្នញ្ច បានញ្ច, បណ្ឌិតស្សាភិហារយុំ ។
ពហុជនោ បសន្នោសិ, ទិស្វា បណ្ឌិតមាគតេ;
បណ្ឌិតម្ហិ អនុប្បត្តេ, ចេលុក្ខេបោ បវត្តថ" ។

"ពួកអ្នកជនបទមកជួបជុំគ្នា ពួកអ្នកនិគមមកជួបជុំគ្នា នាំយកបាយនិងទឹកដ៏ច្រើន មកជូនវិធុរបណ្ឌិត ។ ប្រជាជនជាច្រើន ជាអ្នកមានចិត្តជ្រះថ្លា ព្រោះឃើញបណ្ឌិត មកដល់ហើយ កាលបណ្ឌិតមកដល់ ការលើកទង់ក៏ប្រព្រឹត្តទៅ" ។

មហោស្រព ប្រព្រឹត្តទៅរហូតពេលមួយខែ ។ គ្រានោះ ព្រះមហាសត្វ សម្តែងនូវធម្មទេសនាដល់មហាជន ហាក់ដូចជាសម្រេចនូវពុទ្ធកិច្ច ។ ដូចគ្នានោះដែរ លោកតែងប្រៀនប្រដៅព្រះមហាក្សត្រ និងធ្វើបុណ្យទាំងឡាយ មានទានជាដើម បិតនៅរហូតអស់កាលកំណត់នៃអាយុរបស់មនុស្សសម័យនោះ ។ លុះដល់ទីអវសាននៃជីវិត លោកបានកើតនៅឯស្ថានសួគ៌ ។ អ្នកក្រុងទាំងឡាយទាំងពួង មានព្រះមហាក្សត្រជាដើម កាលដែលបិតក្នុងឱវាទនៃលោកបណ្ឌិតហើយ ពួក

*គេបានធ្វើបុណ្យទាំងឡាយ មានទានជាដើម ដល់ទីអវសាននៃជីវិត ពួកគេបានកើតនៅឯឋានសួគ៌យ៉ាងកកកុញ" ។*

## **ព្រះសាស្តាប្រជុំជាតក**

*លុះនាំធម្មទេសនានេះមកសម្តែងហើយ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនទើបតែឥឡូវនេះទេ, សូម្បីកាលពីអតីតជាតិ ក៏តថាគតបរិបូណ៌ដោយប្រាជ្ញា ឈ្លាសក្នុងឧបាយកលដែរ" រួចទ្រង់បានប្រជុំជាតកថា ៖*

- តទា បណ្ឌិតស្ស មាតាបិតរោ មហារាជកុលានិ អហេសុំ,
  *ម្តាយឪពុករបស់បណ្ឌិតគ្រានោះ បានមកជាត្រកូលមហារាជ*
- ជេដ្ឋភរិយា រាហុលមាតា,
  *ភរិយាច្បង បានមកជា រាហុលមាតា*
- ជេដ្ឋបុត្តោ រាហុលោ,
  *កូនច្បង បានមកជា រាហុល*
- វិមលា ឧប្បលវណ្ណា,
  *វិមលាទេវី បានមកជា ឧប្បលវណ្ណា*
- វរុណនាគរាជា សារិបុត្តោ,
  *វរុណនាគរាជ បានមកជាសារីបុត្រ*
- សុបណ្ណរាជា មោគ្គល្លានោ,

*សុបណ្ណរាជ បានមកជា មោគ្គល្លាន*

- សក្កោ អនុរុទ្ធោ,

*សក្កទេវរាជ បានមកជា អនុរុទ្ធ*

- ធនញ្ជយកោរព្យរាជា អានន្ទោ,

*ព្រះបាទធនញ្ជយកោរព្យ បានមកជា អានន្ទ*

- បុណ្ណកោ ឆន្នោ,

*បុណ្ណកយក្ស បានមកជាឆន្នៈ*

- បរិសា ពុទ្ធបរិសា,

*បរិស័ទទាំងឡាយ បានមកជា ពុទ្ធបរិស័ទ*

- វិធុរបណ្ឌិតោ បន អហមេវ សម្មាសម្ពុទ្ធោ អហោសិំ" ។

*ឯលោកវិធុរបណ្ឌិត បានមកជាតួអង្គអញតថាគតសម្មាសម្ពុទ្ធ នេះឯង*

*វិធុរជាតក ទី៩ ចប់ ។*



នេះកាលវិធូរបណ្ឌិតសម្តែងសាធុនរធម៌ដល់បុណ្ណកយក្ស

ISBN 9789996341007

PUC Press